**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universite Royale de droit et des Sciences Economies

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ហាន្យ សុជាតា**

កញ្ញា **អេម វ៉ាន់ថន**

ណែនាំដោយ

លោកគ្រូ **ខាត់ ធី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំបញ្ចប់សារណា២០២៤

# **សេចក្ដីថ្លែងអំណរគុណ**

យើងខ្ញុំ **ហង្ស សុជាតា** និង **អេម វ៉ាន់ថង** ជានិស្សិត កម្រិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង សូមបង្អោនកាយ វាចាចិត្ត ប្រកបដោយកតញ្ញូកតវេទិតាធម៌ និងភក្ដីភាពធ្វើនូវសេចក្ដីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ៖

**លោកឪពុក** និង**អ្នកម្ដាយ** បានបង្កើតរូបកាយកូនឱ្យបានឃើញនូវពន្លឺព្រះអាទិត្យ និងខិតខំចិញ្ចឹមបីបាច់ថ្នាក់ថ្នមថែរក្សាពោរពេញដោយសេចក្ដីលំបាកកាយ និងលំបាកចិត្តឥតគណនាស្មានពុំបានប្រមាណពុំត្រូវ ដើម្បីឱ្យកូនមានជីវិតរស់នៅ បានសិក្សារៀនសូត្ររហូតមានថ្ងៃនេះ លោកទាំងពីរមានគុណដ៏មហិមា គឺប្រកបដោយព្រហ្មវិហារធម៌ និងសង្គមធម៌យ៉ាងពិតប្រាកដសម្រាប់រូបកូន។

**ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា** តំណាងរាជរដ្ឋាភិបាលដែលបានអនុញ្ញាតឱ្យបង្កើតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះឡើង។

**ឯកឧត្ដម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាថ្នាក់ដឹកនាំកំពូល ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សារៀនសូត្រតាំងពីឆ្នាំសិក្សាមូលដ្ឋានហូតដល់ពេលសរសេរសារណាបញ្ចប់កម្រិតបរិញ្ញាបត្រនេះ។

**សាកលវិទ្យាធិការរង មន្ត្រី បុគ្គលិក** ជាថ្នាក់ដឹកនាំតាមឋានានុក្រមទាំងអស់ ដែលបានញ៉ាំងសាកលវិទ្យាល័យនេះ ឱ្យមានដំណើរការទៅប្រកបដោយនិរន្តរភាព និងភាពរលូនល្អប្រសើរ ធ្វើឱ្យយើងខ្ញុំអាចទទួលយកនូវចំណេះដឹងតាមកម្រិតបរិញ្ញាបត្រ និងឈានដល់ការបញ្ចប់បរិញ្ញាបត្រនេះប្រកបដោយភាពពេញលេញ។

លោកគ្រូ **ខាត់ ធី** មានចិត្តសណ្ដោសប្រោសប្រណីទទួលនាទីជាសាស្ត្រាចារ្យណែនាំ យើងខ្ញុំក្នុងការសរសេរសារណានេះ ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ជាទីបំផុត។

សាស្ត្រាចារ្យទទួលបន្ទុកថ្នាក់ និងសាស្ត្រាចារ្យគ្រប់រូប ដែលបានផ្ទេរចំណេះដឹងដល់យើងខ្ញុំ ទាំងពីររូបសម្រាប់យកទៅប្រើប្រាស់នៅក្នុងសង្គម ដើម្បីទាញយកនូវផលប្រយោជន៍ផ្ទាល់ខ្លួន សង្គមគ្រួសារ សង្គមជាតិ សង្គមសាសនា តាមសមត្ថភាព និងលទ្ធភាពដែលអាចធ្វើទៅបាន។

ជាទីអវសាន យើងខ្ញុំសូមគោរពជូននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ដល់លោកអ្នកមានគុណទាំងអស់កុំឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ បានសិក្សាអស់រយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កម្រិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ មុននឹងបញ្ចប់ការសិក្សានេះ សាកលវិទ្យាល័យ តម្រូវឱ្យសរសេរសារណាទៅតាមគោលបំណងរបស់ខ្លួន ដើម្បីបញ្ជាក់ពីសមត្ថភាព ចំណេះដឹងក្នុងការសិក្សាស្រាវជ្រាវ។

ផ្អែកលើតម្រូវការរបស់សាកលវិទ្យាល័យ យើងខ្ញុំជ្រើសរើសយកប្រធានបទ "**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**" ដើម្បីសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ប្រធានបទនេះ យើងខ្ញុំចង់ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទៅលើច្បាប់ដែល ពាក់ព័ន្ធទៅនឹងការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំចំណាយពេលវេលា និងខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីពង្រឹងចំណេះដឹងផ្នែកគតិយុត្តឲ្យកាន់តែច្បាស់ថែមទៀត។

យើងខ្ញុំសង្ឃឹមថា សមិទ្ធិដែលប្រសូត្រចេញពី ការខិតខំរបស់យើងខ្ញុំក្នុងការសិក្សាជ្រាវនេះ ជាវិភាគទានចូលរួមចំណែក ក្នុងការផ្តល់ជាចំណេះដឹងដល់និស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវបន្ត ពង្រីកចំណេះ ក៏ដូចជាឯកសារជំនួយ នេះឲ្យបានកាន់តែទូលំទូលាយថែមទៀត ។

ការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំនេះ ពិតណាស់នៅមានការខ្វះខាត ពុំអាចគ្រប់ជ្រុងជ្រោយទេ ទាំងពាក្យពេចន៍ អត្ថន័យ ខ្លឹមសារ ដោយសារតែការសិក្សា និងចំណេះដឹងរបស់យើងខ្ញុំនៅមានកម្រិត ដូច្នេះហើយអ្នកសិក្សាស្រាវជ្រាវទាំងឡាយ មេត្តា ខន្តី អភ័យ បណ្តាកំហុសខុស ឆ្គងដោយអចេតនាណាមួយ ហើយយើងខ្ញុំមានសេចក្តីសោមនស្សរីករាយ ចំពោះការរិះគន់ កែលម្អ ពីមិត្ត អ្នកអាន និងមិត្តអ្នកសិក្សាស្រាវជ្រាវទាំងឡាយនៅក្នុងអត្ថន័យស្ថាបនា ដើម្បីឱ្យសមិទ្ធិនេះកាន់តែមានសុក្រិតភាពថែមទៀត ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ៥

**ជំពូកទី១៖ ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** .................... ៦

**១.១. លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ( PLC )........ ៧

**១.១.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន** ............................................ ៨

១.១.១.១. ការព្រមព្រៀងរបស់សមាជិកភាគហ៊ុន ............................................ ៨

១.១.១.២. សមត្ថភាពរបស់សមាជិកភាគហ៊ុន ............................................ ១០

១.១.១.៣. កម្មវត្ថុ ............................................................ ១២

**១.១.២. លក្ខខណ្ឌទម្រង់នៃការបង្កើតក្រុមហ៊ុន** ............................................ ១២

១.១.២.១.នាមករណ៍ក្រុមហ៊ុន ............................................................ ១៣

១.១.២.២.ភាគទុន ............................................................ ១៣

១.១.២.៣. ការចូលរួមលើលទ្ធផល ............................................................ ១៣

១.១.២.៤. ការផ្សព្វផ្សាយជាសាធារណៈ ............................................................ ១៤

ក. ការផ្សព្វផ្សាយក្នុងផ្សារពត៌មានស្របច្បាប់ ............................................ ១៤

ខ. ការតម្កល់ទុកក្នុងក្រសួងពាណិជ្ជកម្ម ............................................ ១៤

គ. ប្រតិវេទន៍អនុលោមភាព ............................................................ ១៥

១.១.២.៥. ការចុះបញ្ជីក្រុមហ៊ុន ............................................................ ១៦

១.១.២.៦. សញ្ជាតិ ............................................................ ១៩

១.១.២.៧. សមត្ថភាពនិងសិទ្ធិរបស់ក្រុមហ៊ុន ............................................ ១៩

១.១.២.៨. ខ្លឹមសារលក្ខន្តិកៈរបស់ក្រុមហ៊ុន ............................................ ១៩

១.១.២.៨.១. ប្រភេទទូទៅនៃខ្លឹមសារលក្ខន្តិកៈ ....................................................................២១

១.១.២.៨.២. នាមករណ៍ក្រុមហ៊ុន .......................................................................................២១

១.១.២.៨.៣. ចិរវេលាក្រុមហ៊ុននិងសញ្ជាតិក្រុមហ៊ុន ......................................................២១

១.១.២.៨.៤. ទីស្នាក់ការក្រុមហ៊ុន .......................................................................................២២

**១.២.ដើមទុន និងភាគហ៊ុនរបស់ក្រុមហ៊ុន** ..............................................................................២៣

**១.២.១. ដើមទុនរបស់ក្រុមហ៊ុន** ...............................................................................................២៣

**១.២.២. ភាគហ៊ុនរបស់ក្រុមហ៊ុន** ..............................................................................................២៣

ក.ប័ណ្ណភាគហ៊ុនមានមួយប្រភេទ.........................................................................................២៤

ខ.ប័ណ្ណភាគហ៊ុនមានច្រើនជាងមួយប្រភេទ .........................................................................២៤

**ជំពូកទី២៖ ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** .. ២៦

**២.១. ការគ្រប់គ្រងនិងការត្រួតពិនិត្យក្រុមហ៊ុន**.............................................................................២៦

**២.១.១ .អភិបាល** ...................................................................................................................២៦

២.១.១.១.ការបោះឆ្នោតជ្រើសរើស និង អាណត្តិរបស់អភិបាល ..............................................២៦

២.១.១.២. សិទ្ធិ និង តួនាទីរបស់អភិបាល.....................................................................................២៧

២.១.១.៣ ប្រាក់បៀវត្ស និង ប្រាក់លាភការ ....................................................................................២៨

២.១.១.៤. ការទទួលខុសត្រូវរបស់អភិបាល ....................................................................................២៩

២.១.១.៥. ការដកហូត និង ការបញ្ចប់តំណែងអភិបាល .................................................................៣០

**២.១.២. ក្រុមប្រឹក្សាភិបាល**........................................................................................................ ៣១

២.១.២.១.ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាល ...................................................................... ៣១

២.១.២.២. សមាសភាពក្រុមប្រឹក្សាភិបាល....................................................................................... ៣២

២.១.២.៣.គណៈកម្មការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល ..................... ៣២

២.១.២.៤. សិទ្ធិ និងអំណាចរបស់ប្រឹក្សាភិបាល..................... ៣២

២.១.២.៥. ប្រាក់បៀវត្ស និងប្រាក់លាភការ..................... ៣៣

២.១.២.៦. ការបញ្ចប់តួនាទីរបស់ក្រុមប្រឹក្សាភិបាល ..................... ៣៣

ក. ការដល់អាណត្តិ ..................... ៣៤

ខ. ការសុំលាលែងរបស់ក្រុមប្រឹក្សាភិបាល ..................... ៣៤

គ. ការដកហូតមុខតំណែង..................... ៣៤

២.១.២.៧. ការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាល ..................... ៣៥

២.១.២.៨. អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលដោយមហាសន្និបាត..................... ៣៥

ក. សេចក្តីជូនដំណឹងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល..................... ៣៥

ខ. របៀបវារៈ ..................... ៣៦

គ. ទីកន្លែងប្រជុំ ..................... ៣៦

ឃ. កូរ៉ុម..................... ៣៦

២.១.២.៩.អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងអង្គប្រជុំវិសាម ..................... ៣៦

ក. សេចក្តីសម្រេច និងកំណត់ហេតុ ..................... ៣៧

ខ. ការសម្រេចឯកច្ឆ័ន្ទជាលាយលក្ខណ៍អក្សរ ..................... ៣៨

២.១.២.១០. ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល..................... ៣៨

ក. ការទទួលខុសត្រូវរដ្ឋប្បវេណី..................... ៣៨

ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ..................... ៣៨

គ. ការធានាសំណង ..................... ៣៩

ឃ. គណៈកម្មាធិការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល ........ ៣៩
**២.១.៣. សិទ្ធិរបស់ម្ចាស់ហ៊ុន** ........ ៤០
**២.១.៤. មហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន** ........ ៤០
២.១.៤.១. មហាសន្និបាតវិសាមញ្ញនៃម្ចាស់ភាគហ៊ុន ........ ៤១
២.១.៤.២. មហាសន្និបាតប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ........ ៤១
២.១.៤.៣. ការដឹកនាំសន្និបាតរបស់ម្ចាស់ភាគហ៊ុន ........ ៤២
២.១.៤.៤. សេចក្តីសម្រេចដោយម្ចាស់ហ៊ុនក្នុងអង្គប្រជុំពិសេស ........ ៤២
២.១.៤.៥. ការទទួលភាគលាភតាមគោលនយោបាយទូទៅនៃភាគលាភ ........ ៤២
២.១.៤.៦. ការធ្វើវិសោធនកម្មលើលក្ខន្តិកៈរបស់ក្រុមហ៊ុន........ ៤៣
**២.១.៥. ការផ្សព្វផ្សាយជាសាធារណៈ** ........ ៤៤
២.១.៥.១. វិញ្ញាបនបត្រ ........ ៤៤
២.១.៥.២.សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុន........ ៤៤
**២.២.ការរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និង កំណត់ហេតុ** ........ ៤៥
**២.២.១.លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង** ........ ៤៥
**២.២.២. ទីស្នាក់ការចុះបញ្ជី** ........ ៤៦
**២.២.៣. កំណត់ហេតុ** ........ ៤៧
**២.២.៤. របាយការណ៍ហិរញ្ញវត្ថុ** ........ ៤៧
**២.២.៥. អាយុកាលក្រុមហ៊ុន**........ ៤៨
**ជំពូលទី៣៖ ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិត** ........ ៤៨

**៣.១. ការរំលាយក្រុមហ៊ុន** ..... ៤៨
ក.កិច្ចព្រមព្រៀងរំលាយចូលគ្នា ..... ៥០
ខ. កិច្ចប្រជុំម្ចាស់ហ៊ុន ..... ៥០
**៣.២. ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា** ..... ៥១
**៣.២.១. ការបញ្ចប់អត្ថិភាពក្រុមហ៊ុនដើម** ..... ៥៤
**៣.២.២. ការបង្កើតក្រុមហ៊ុនថ្មី** ..... ៥៤
**៣.៣.ការរំលាយ និង បញ្ចប់អត្ថិភាពក្រុមហ៊ុន** ..... ៥៤
**៣.៣.១.ការជ្រើសតាំងអ្នកជម្រះបញ្ជី** ..... ៥៤
**៣.៣.២.សិទ្ធិ និងភាតព្វកិច្ចអ្នកជម្រះបញ្ជី** ..... ៥៥
ក. ការជម្រះបញ្ជីដោយស្ម័គ្រចិត្ត ..... ៥៥
ខ. ការជម្រះបញ្ជីតាមផ្លូវតុលាការ ..... ៥៦
គ.ការទទួលខុសត្រូវរបស់អ្នកជម្រះបញ្ជី ..... ៥៦
ឃ.លទ្ធផលនៃការជម្រះបញ្ជី ..... ៥៧
**៣.៣.៣.ការបញ្ចប់អត្ថិភាពក្រុមហ៊ុន** ..... ៥៧
ក. អត្ថិភាព ..... ៥៧
ខ. ការព្រមព្រៀង ..... ៥៨
គ. ការផ្ទេរផលប្រយោជន៍របស់ខ្លួន ..... ៥៩
**៣.៤.សមត្ថកិច្ចមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន** ..... ៥៩
**៣.៤.១.សមត្ថកិច្ចមន្ត្រីទទួលបន្ទុកក្រុមហ៊ុន** ..... ៥៩
**៣.៤.២.ការប្រកាសជាសាធារណៈចំពោះម្ចាស់បំណុល** ..... ៦១

៣.៤.៣.ការចេញវិញ្ញាបនប័ត្រ ........................................................................................... ៦១

**សេចក្តីសន្និដ្ឋាន** ........................................................................................... ៦២

**អនុសាសន៍** ........................................................................................... ៦៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ស្របពេលដែលព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ហើយមានការរីកចម្រើនលើគ្រប់វិស័យ ការធ្វើអាជីវកម្ម និងការបណ្តាក់ទុននានា ក៏មានការរីកដុះដាលផងដែរ។ ក្នុងនោះវត្តមានរបស់ធនាគារ និងក្រុមហ៊ុនផ្សេងៗត្រូវបានគេមើលឃើញថា មានការរីកចម្រើន និងកើនឡើងយ៉ាងគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។

ការសិក្សាលើវិស័យពាណិជ្ជកម្ម និងវិស័យក្រុមហ៊ុនក៏មានភាពទូលំទូលាយផងដែរ។ បច្ចុប្បន្ននេះដោយឃើញថាកម្ពុជាមានច្បាប់គោលគ្រប់គ្រងក្នុងវិស័យពាណិជ្ជកម្ម គឺច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានស្តីពីពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ថែមទាំងច្បាប់មួយចំនួនទៀតដែលទើបតែអនុម័តថ្មី។ ច្បាប់ទាំងនេះបានចែងអំពីប្រភេទនៃក្រុមហ៊ុនផ្សេងៗជាច្រើនដែលអ្នកវិនិយោទុនអាចជ្រើសរើស ក្នុងការបង្កើតតាមកម្រិតនៃដើមទុរបស់ខ្លួន។ ដោយការសំឡឹងមើលឃើញនូវអត្ថប្រយោជន៍នៃការចូលរួមវិនិយោគ ពីវិស័យឯកជនក្នុងការបង្កើតក្រុមហ៊ុនក្នុងសារណាមួយនេះ នឹងធ្វើការបកស្រាយអំពីប្រភេទក្រុមហ៊ុនមួយ ដែលក្នុងនោះការសិក្សាដែលទាក់ទងនឹងក្រុមហ៊ុនមូលធនត្រូវបានបែងចែកជាពីរគឺ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ពោលអត្ថបទនៃការស្រាវជ្រាវនេះសង្កត់ធ្ងន់ និងស៊ីជម្រៅទៅលើក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត( Public Limited Company ) តែប៉ុណ្ណោះ។

ដើម្បីឱ្យយល់កាន់តែស៊ីជម្រៅអំពីរបៀបវារៈនៃការបង្កើត និងការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ហើយអ្វីដែលសំខាន់នោះគឺប្រតិបត្តិការរបស់ក្រុមហ៊ុនពីការបោះផ្សាយលក់មូលបត្រ កម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលការបោះផ្សាយលក់មូលបត្រនេះកំពុងតែបានដំណើរការក្នុងទីផ្សារមូលបត្រកម្ពុជា ហៅកាត់ថា ផ.ម.ក. និង ដើម្បីបកស្រាយឲ្យកាន់តែបានក្បោះក្បាយទៅលើប្រធានបទមួយនេះ ក្នុងសារណា នេះនឹងធ្វើការបែងចែកជា បីជំពូកធំៗគឺ ជំពូកទី១នឹងធ្វើការនិយាយអំពី ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ជំពូកទី២គឺ ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងជំពូកទី៣ គឺ ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្របពេលដែលនិស្សិតភាគច្រើនមានទំនោរទៅរកការសិក្សាពី ក្រុមហ៊ុនមូលធន ហើយឯកសារមួយចំនួនពុំសូវមានការនិយាយលម្អិតទាក់ទងទៅនឹងប្រភេទនីមួយៗ របស់ក្រុមហ៊ុនមូលធនឡើយ។ ហេតុដូចនេះយើងនឹងធ្វើការពន្លិច ព្រមទាំងបកស្រាយខ្លឹមសារ ឲ្យច្បាស់ពីក្រុមហ៊ុនមួយប្រភេទដែលស្ថិតនៅក្នុងក្រុមហ៊ុនមូលធន ពោលគឺ **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។** ដូច្នេះហើយប្រធានបទថ្មីមួយនេះ នឹងលើក

ឡើងពីការបង្កើត ការប្រព្រឹត្តទៅ ការរំលាយ និងការជម្រះបញ្ជីរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ថាទៅតាមគោលការណ៍គតិយុត្តដែរឬទេ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវខាងលើនេះ យើងខ្ញុំបានស្រាវជ្រាវយកមកសរសេរចងក្រងឡើង ដោយមានគោលបំណងផ្តោតសំខាន់ទៅលើ៖

- ការស្វែងយល់អំពីមូលហេតុនៃរឿងរ៉ាវ និងទ្រឹស្តីច្បាប់ ស្តីពីកិច្ចនៃនីតិវិធីនៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។
- ការស្វែងយល់អំពីស្ថាប័នសិទ្ធ និងការទទួលខុសត្រូវរបស់សមាជិកហ៊ុន ក្នុងការដំណើរការ និងការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។
- ការលើកឡើងពីការជ្រើសតាំង ការបញ្ចប់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាអភិបាល។
- ការលើកឡើងពីសិទ្ធិអំណាចរបស់អភិបាល និងអភិបាលក្រុមហ៊ុន
- ស្វែងយល់អំពីដំណាក់កាល នៃការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវសារណានេះ យើងខ្ញុំបានធ្វើការបែងចែកជាបីជំពូកសំខាន់ៗ ដើម្បីឲ្យកាន់តែច្បាស់លាស់ក្នុងខ្លឹមសារនៃសារណា ដែលជំពូកទាំងនោះរួមមានដូចជា៖ ជំពូកទី១ ការបង្កើតក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិត ជំពូកទី២ ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងជំពូកទី៣ ការរំលាយ និង ការជម្រះបញ្ជីរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទណាមួយ គឺពិតជាមានភាពស្មុគស្មាញ និងលំបាកព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ក្នុងការស្វែងយល់ខ្លឹមសារ អត្ថន័យ ឯកសារ ចំណាយកម្លាំងចិត្ត រួមទាំងថវិកាជាដើម។ ម្យ៉ាងវិញទៀត គឺត្រូវមានចំណង់ចំណូលចិត្តទៅលើប្រធានបទដែលខ្លួនធ្វើ និងការខិតខំព្យាយាមបន្ថែមទើបការសិក្សាស្រាវជ្រាវរបស់យើង ទទួលបានជោគជ័យព្រមទាំងទទួលបានលទ្ធផលល្អ។

យ៉ាងណាមិញ ទោះបីជាវាមានការលំបាក ជួបឧសគ្គខ្លះៗក៏ពិតមែន ក៏យើងខ្ញុំទាំងពីរនាក់នៅតែខិតខំជម្នះ រាល់ការលំបាកនេះឲ្យទាល់តែបាន ពីព្រោះថាការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំង ណាស់សម្រាប់យើងខ្ញុំទាំងពីរនាក់ ដែលក្នុងនោះរួមមានដូចជា៖

- ទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀតពីលើប្រធានបទសារណាមួយនេះ ដែលពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ
- ទទួលបានប្រភពឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទ ដែលបានសិក្សាស្រាវជ្រាវ
- ចេះធ្វើការប្រៀបធៀបពីភាពដូចគ្នា និងភាពខុសគ្នា
- យល់កាន់តែច្បាស់បន្ថែមទៀត អំពីការរៀបប្រយោគ ឃ្លោងឃ្លា អក្ខរាវិរុទ្ធ
- ទទួលបានបទពិសោធន៍ល្អៗ ពីអ្នកមានចំណេះដឹង និងព្រមទាំងអ្នកមានបទពិសោធន៍
- ជាពិសេស គឺបានបន្សល់ស្នាដៃទុកសម្រាប់សិស្ស និស្សិតជំនាន់ក្រោយៗ បានសិក្សាស្រាវជ្រាវបន្ត។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងដំណើរការនៃការសិក្សាប្រធានបទមួយនេះ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ត្រូវបានយកមកធ្វើជាមូលដ្ឋាននៅក្នុងការសិក្សាពិចារណា។ បន្ទាប់មកដោយសារតែចំណុចខ្លះ ច្បាប់មិនបានកំណត់ឲ្យបានច្បាស់ ហើយទុកចន្លោះឲ្យលក្ខន្តិកៈរបស់ក្រុមហ៊ុននីមួយៗ ជាអ្នកបំពេញបន្ថែមដោយខ្លួនឯងនោះ ពួកយើងក៏សម្រេចលើកយកនូវលក្ខន្តិកៈរបស់ក្រុមហ៊ុនមួយ គឺលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA Bank. PLC) ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មកធ្វើការពិចារណាបន្ថែមទៀត។ ក្រៅពីនេះទៅ ពួកយើងបានដកស្រង់នូវគំនិតមួយចំនួនពី សៀវភៅណែនាំ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និង ការប្រកបអាជីវកម្មអនុលោម តាមច្បាប់របស់ក្រសួងពាណិជ្ជកម្មផងដែរ។ មិនតែប៉ុណ្ណោះ ពួកយើងបានធ្វើការពិភាក្សា និង ពិគ្រោះយោបល់ជាមួយនឹងលោកសាស្ត្រាចារ្យ ខាត់ ធី ដែលជាសាស្ត្រាចារ្យណែនាំបន្ថែមទៀតផងដែរ ដើម្បីធ្វើឲ្យប្រាកដថាការសិក្សាមួយនេះ មានលក្ខណៈសមស្របតាមនិយមគតិយុត្តស្តីពីសហគ្រាសពាណិជ្ជកម្ម។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ស្របតាមកម្មវត្ថុ និងដែនកំណត់ខាងលើ ប្រធានបទមួយនេះ នឹងធ្វើការបែងចែកជា ៣ ជំពូក ដោយក្នុងនោះ ជំពូកទី១ ៖ និយាយពីការបង្កើតក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ជំពូកទី២ ៖ ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ហើយ ជំពូកទី ៣៖ ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលផ្ដោតការយកចិត្តទុកដាក់ទាំងស្រុងទៅលើ ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជីក្រុមហ៊ុន។

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅលើសកលលោកទូទាំងប្រទេសយើងនេះសេដ្ឋកិច្ចគឺកំពុងតែដំណើរការ ទៅមុខឥតឈប់ឈរទៅតាមប្រទេស ដែលធ្វើឱ្យមានការប្រកួតប្រជែងយ៉ាងខ្លាំងនៅក្នុងទីផ្សារពិភពលោក។ សេដ្ឋកិច្ចរបស់ប្រទេសនីមួយៗអាចរីកចម្រើន អភិវឌ្ឍន៍ ទៅមុខបាន គឺដោយមានការចូលរួមពីវិស័យឯកជនជួយជ្រុំជ្រែង។

យ៉ាងណាមិញព្រះរាជាណាចក្រកម្ពុជាក៏មិនខុសពីបណ្តាប្រទេសនានាលើពិភពលោកដែរ បន្ទាប់ពីបានងើបឡើងពីរបបសង្គ្រាមដែលអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ប្រទេសនេះបានធ្វើការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់។ ដោយមានការដឹកនាំដ៏ឆ្លាតវៃពីសំណាក់រាជរដ្ឋាភិបាល បានធ្វើឱ្យប្រទេសកម្ពុជាយើងទទួលបានការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសគឺវិស័យសេដ្ឋកិច្ចនេះតែម្តង ហើយវិស័យមួយចំនួនទៀតក៏កំពុងតែអភិវឌ្ឍន៍រួមជាមួយគ្នាដែរ។ ក្រោយពីរាជរដ្ឋាភិបាលធ្វើការផ្លាស់ប្តូរនូវរបបសេដ្ឋកិច្ចបែបផែនការឱ្យក្លាយជារបបសេដ្ឋកិច្ចទីផ្សារសេរីតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជានេះបាននាំឱ្យមានលំហូរចូលយ៉ាងច្រើនពីបណ្តាក្រុមហ៊ុនពាណិជ្ជកម្មមិនថាទាំងក្នុង និងក្រៅប្រទេសទេបានមកចូលរួមវិនិយោគក្នុងប្រទេសនេះ។

ជាក់ស្តែងក្រោយពីប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ាននិងអង្គការពាណិជ្ជកម្មពិភពលោក (WTO) មកការរត់ប្រណាំងខាងផ្នែកវិស័យសេដ្ឋកិច្ចជាកត្តាចម្បង និងជះឥទ្ធិពលយ៉ាងធំធេងមកលើកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ការទាក់ទាញវិនិយោគិនមកបណ្តាក់ទុន និង បង្កើតក្រុមហ៊ុនពាណិជ្ជកម្ម គឺជាចំណុចសំខាន់បំផុតសម្រាប់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ហើយវិធីសាស្ត្រដែលរាជរដ្ឋាភិបាលខិតខំទាក់ទាញនូវវិនិយោគិនធំៗទាំងក្នុង និងក្រៅប្រទេសនោះ គឺការកែប្រែហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន រួមមានការរៀបចំនិងកសាងនូវប្រភពថាមពលផ្លូវ ថ្នល់ និងមូលដ្ឋានច្បាប់ដូចជា ច្បាប់បន្ធូរបន្ថយពន្ធដារ ដើម្បីលើកទឹកចិត្តវិនិយោគិន ព្រមទាំងតាមដាន នូវការលំបាករបស់វិនិយោគិន និងជួយស្វែងរកដំណោះស្រាយ។

បច្ចុប្បន្ននេះ ដោយឃើញថាកម្ពុជាមានច្បាប់គោលគ្រប់គ្រងក្នុងវិស័យពាណិជ្ជកម្ម គឺច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានស្តីពីពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ថែមទាំងច្បាប់មួយចំនួនទៀតដែលទើបតែអនុម័តថ្មី។ ច្បាប់ទាំងនេះបានចែងអំពីប្រភេទនៃក្រុមហ៊ុនផ្សេងៗជាច្រើនដែលអ្នកវិនិយោគទុនអាចជ្រើសរើសក្នុងការបង្កើតតាមកម្រិតនៃដើមទុនរបស់ខ្លួន។ ដោយការសំឡឹងមើលឃើញនូវអត្ថប្រយោជន៍នៃការចូលរួមវិនិយោគពីវិស័យឯកជនក្នុងការបង្កើតក្រុមហ៊ុនក្នុងសារណានេះ នឹងធ្វើការបកស្រាយអំពីប្រភេទក្រុមហ៊ុនមួយដែលកំពុងទទួលបានការចាប់អារម្មណ៍ ក៏ដូចជាមានការបណ្តាក់ទុនពីវិនិយោគិនជាច្រើននោះគឺ **"ក្រុមហ៊ុនមហាជនទទួលត្រូវមានកម្រិត"** (Public Limited Company) ។

# ជំពូកទី១

## ជំពូកទី១៖ ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានកំណត់ថាក្រុមហ៊ុនមូលធនមាន ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និង ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។[1] ដូច្នេះហើយការបង្កើតក្រុមហ៊ុនទាំងពីរនេះ ក៏តែងតែមាន លក្ខខណ្ឌមួយចំនួនដូចគ្នា និង មួយចំនួនទៀតមិនដូចគ្នានោះទេ។ ប៉ុន្តែទោះជាយ៉ាងណាគេសង្កេតឃើញថា ការបង្កើតក្រុមហ៊ុនទាំងពីរកើតចេញពីឆន្ទៈ និងគំនិតផ្តួចផ្តើមរបស់ស្ថាបនិក[2] ឬសមាជិកហ៊ុនដែលមានភាគហ៊ុនច្រើនជាងគេដូចគ្នា។ ហើយដំណើរការ ក៏ដូចជាលក្ខខណ្ឌលំអិត នៃការបង្កើតក្រុមហ៊ុនទាំងពីរ ក៏មានលក្ខណៈដូចគ្នាច្រើនផងដែរ។

បើយើងសង្កេតទៅមើល ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញ ក្រុមហ៊ុននេះគឺ ជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធន ហេតុនេះការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គ្មានអ្វីខុសប្លែកពីការ ប្រព្រឹត្តទៅរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនោះទេ។ បញ្ហាប្លែកនោះគឺ អ្នករៀបរៀងធ្វើការអធិប្បាយខ្លឹមសារវែងនិងមានលក្ខណៈពិស្តារជាងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតែប៉ុណ្ណោះ។

ជាការពិតណាស់ ដើម្បីធ្វើឱ្យក្រុមហ៊ុនមួយមានដំណើរការទៅបាន គឺត្រូវឆ្លងកាត់ការបង្កើតលក្ខខណ្ឌទម្រង់ជាមុនសិន។ ការបង្កើតលក្ខខណ្ឌទម្រង់នេះគឺត្រូវធ្វើឡើងតាមរយៈស្ថាបនិកនៃក្រុមហ៊ុនរបស់ខ្លួនជាអ្នកស្វែងរក និងផ្តួចផ្តើមគំនិតក្នុងការបង្កើត ដោយផ្អែកទៅតាមគោលការណ៍សេរី និងសាមគ្គីគ្នារវាងស្ថាបនិកទាំងអស់ដែលជាសមាជិកនៃក្រុមហ៊ុនទោះ ច្បាប់មិនបានកំណត់លើរបៀបវារៈលើលក្ខខណ្ឌគ្រឹះនៃក្រុមហ៊ុនក៏ដោយ ប៉ុន្តែការធ្វើបែបនេះបានក្លាយជាការអនុវត្តមួយ ដោយធ្វើការពិភាក្សាក្នុងគោលបំណងបង្កើតឱ្យចេញជាប្រការ ឬខសំខាន់ៗនៃក្រុមហ៊ុន។ ប្រការ ឬខសំខាន់ៗនេះមានការចាំបាច់ណាស់ ហើយវាក៏ជាផ្លូវនាំឆ្ពោះទៅរកការបង្កើតលក្ខន្តិកៈ ដែលជាលក្ខខណ្ឌទម្រង់និង ត្រូវតែធ្វើឱ្យស្របទៅនឹងច្បាប់ជាដាច់ខាត។

តើក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (Public Limited Company) មានអត្ថន័យដូចម្តេច?

**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសារធាណៈបាន។[3]

---

[1] មាត្រា១ វាក្យខណ្ឌទី៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[2] មាត្រា៨៨ ចំណុចទី៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[3] មាត្រា៨៧ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

- ក្រុមហ៊ុនអាចមានសមាជិកហ៊ុនចាប់ពី០២នាក់ រហូតដល់ ៣០នាក់។[4]
- នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវដាក់ពាក្យថា " **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ** Public Limited Company "។ ដោយឡែក ពាក្យថា "**ភីអិលស៊ី (Plc.) ឬ ម.ក**" គឺជាអក្សរកាត់នៃពាក្យ "**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ Public Limited Company**" ដែលទម្រង់នៃក្រុមហ៊ុននេះត្រូវបានប្រើប្រាស់ជាទូទៅចំពោះ ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យធនាគារ ធានារ៉ាប់ ឬប្រតិបត្តិការឥណទានជាអាទិ៍។ ហើយយើងតែងតែសង្កេតឃើញថា ផ្នែកខាងចុងនៃនាមករណ៍របស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុភាគច្រើននៅកម្ពុជាបានសរសេរនូវអក្សរកាត់ "**ភីអិលស៊ី (Plc.) ឬ ម.ក** ។[5]

ឧទាហរណ៍ : ធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA Bank Plc.) ធនាគារ កាណាឌីយ៉ា ម.ក (Canadia Bank Plc.) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី (Ly Hour Microfinance Institution Plc.)។

## ១.១. លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (PLC)

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធន ត្រូវបានអនុញ្ញាតដោយ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលការបង្កើតក្រុមហ៊ុនប្រភេទនេះ ចាំបាច់ត្រូវតែឆ្លងកាត់នូវដំណាក់កាលតាមផ្លូវច្បាប់ ដើម្បីឲ្យក្រុមហ៊ុនទទួលបាននូវបុគ្គលភាពគតិយុត្ត (សិទ្ធិ និង កាតព្វកិច្ច) ត្រឹមត្រូវតាមផ្លូវច្បាប់។ ច្បាប់នេះមិន បានចែងលម្អិតដោយឡែកពីការបង្កើតក្រុមហ៊ុននេះទេ។

ក្រុមហ៊ុនត្រូវបង្កើតឡើងតាមរយៈដំណើរការមួយដែលតម្រូវឲ្យដាក់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនទៅកាន់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ ម្ចាស់ហ៊ុនទទួលខុសត្រូវត្រឹមកម្រិតនៃចំនួនទឹកប្រាក់ដែលនៅសល់នៃតម្លៃចារឹកលើប័ណ្ណនៃភាគហ៊ុនរបស់គេ[6]។

យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមាត្រា៩១ ចែងថា៖ នីតិបុគ្គល ឬរូបវន្តបុគ្គល ឬច្រើនដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។

---

[4] មាត្រា ៨៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[5] ម.ក ឬ PLC គឺជាអក្សរកាត់នៃពាក្យ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ PUBLIC LIMITED COMPANY

[6] ខាត់ ធី , នីតិសហគ្រាសពាណិជ្ជកម្ម ( ភ្នំពេញ ឆ្នាំ២០២៣ ) ទំព័រ៧៤

ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវតែគោរពទៅតាមលក្ខខណ្ឌដូច ដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ និងនៅជាធរមាន។

ជាពិសេសនោះកិច្ចសន្យាបង្កើតក្រុមហ៊ុន ត្រូវបានគេយកមកធ្វើជាមូលដ្ឋាននៅក្នុងការបង្កើតក្រុមហ៊ុន ហើយកិច្ចសន្យាបង្កើតក្រុមហ៊ុននេះទៀតសោត ក៏ដូចជាកិច្ចសន្យាផ្សេងទៀតផងដែរ គឺថាការបង្កើតកិច្ចសន្យាប្រភេទនេះ ត្រូវគោរពនូវវិធានទូទៅនៃកិច្ចសន្យា ពោលគឺលក្ខខណ្ឌចម្បងពីរ ដើម្បីធ្វើឲ្យកិច្ចសន្យានេះមានសុពលភាពត្រឹមត្រូវតាមផ្លូវច្បាប់ គឺលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់។

### ១.១.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន

ដើម្បីសម្រេចឱ្យបាននូវជំហានដំបូងនៃការបង្កើតក្រុមហ៊ុន ត្រូវមានការព្រមព្រៀងពីសមាជិកភាគហ៊ុនដែលមានឆន្ទៈក្នុងការបង្កើត និងសមាជិកដែលចូលរួមត្រូវមានសមត្ថភាពគ្រប់គ្រាន់ ហើយត្រូវតែមានកម្មវត្ថុនៃការបង្កើតត្រឹមត្រូវស្របទៅតាមច្បាប់កំណត់។

នៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ លក្ខខណ្ឌគ្រឹះគឺជា លក្ខខណ្ឌចម្បងមួយ ដែលតម្រូវឲ្យសមាជិកភាគហ៊ុនទាំងអស់ត្រូវតែបំពេញឲ្យបានដោយសុចរិត តាមគោលការណ៍ស្មោះត្រង់ ។

ដើម្បីធ្វើឲ្យកិច្ចសន្យាបង្កើតក្រុមហ៊ុនមានសុពលភាពត្រឹមត្រូវតាមផ្លូវច្បាប់កិច្ចសន្យា បង្កើតក្រុមហ៊ុននោះត្រូវតែបង្កើតឡើងដោយមានការព្រមព្រៀងពីសមាជិកភាគហ៊ុនដែលមានឆន្ទៈក្នុងការបង្កើតស្របពេលដែលសមាជិកចូលរួមទាំងអស់ត្រូវតែមានសមត្ថភាពតាមផ្លូវច្បាប់ និងកម្មវត្ថុរបស់ក្រុមហ៊ុន ទៀតសោតត្រូវតែស្របទៅនឹងអ្វីដែលច្បាប់បានកំណត់ ដែលចំណុចទាំងបីនេះ (ការព្រមព្រៀង សមត្ថភាព និង កម្មវត្ថុ) នឹងក្លាយទៅជាលក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យាបង្កើតក្រុមហ៊ុន។

#### ១.១.១.១. ការព្រមព្រៀងរបស់សមាជិកភាគហ៊ុន

ក្រុមហ៊ុនអាចកើតឡើងស្របច្បាប់ ឬត្រូវតាមផ្លូវគតិយុត្ត លុះត្រាតែឈរលើគោលការណ៍នៃការព្រមព្រៀងរបស់សមាជិកភាគហ៊ុនជាមុនសិន។ ការព្រមព្រៀងជាកត្តាមួយដ៏សំខាន់ណាស់ ព្រោះមុននឹងឈានដល់ការព្រមព្រៀងនេះ សមាជិកភាគហ៊ុននីមួយៗ ត្រូវឆ្លងកាត់ការចរចា និងពិភាក្សានៅចំពោះមុខគ្នាទៅវិញទៅមកស្វែងយល់ពីខ្លឹមសារនៃអត្ថបទ និងបែបបទព្រមទាំងក្របខណ្ឌនៃការបង្កើតនីតិបុគ្គលក្រុមហ៊ុននោះ។កិច្ចសន្យានៃការព្រមព្រៀងរបស់សមាជិកភាគហ៊ុននីមួយៗ ត្រូវតែធ្វើឡើងប្រកបដោយភាពយុត្តិធម៌ និងសមធម៌រវាងគ្នា

នឹងគ្នា ជៀសវាងការភាន់ច្រឡំ) ការឆបោកការបង្ខិតបង្ខំ ការគម្រាម កំហែង អំពើកេងយកចំណេញហួសហេតុ ដែលជាហេតុនាំឱ្យមានវិការៈដល់កិច្ចសន្យា។

គោលការណ៍នៃការព្រមព្រៀងដោយពិតប្រាកដ និង សេរី របស់សមាជិកភាគហ៊ុន ត្រូវបានយកមកធ្វើជាគោលការណ៍មូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យាបង្កើតក្រុមហ៊ុន និងការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ការព្រមព្រៀងដោយពិតប្រាកដមានន័យថា ជាការព្រមព្រៀងដែលធ្វើឡើងនៅក្នុងលក្ខខណ្ឌនៃភាពដឹងខុសត្រូវ និងមិនមែនស្ថិតនៅក្នុងស្ថានភាពស្រវឹង ភាពខឹងច្រឡោតឆេវឆាវ ភាពវង្វេងស្មារតី ដោយស្ថិតនៅក្នុងអំណាចនៃថ្នាំសណ្តំឡើយ។ ហើយចំណែកឯការព្រមព្រៀងដោយសេរី សំដៅទៅលើការព្រមព្រៀងដែលធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ ការគំរាមកំហែង និងការភាន់ច្រឡំ ឬ ការបន្លំបោកប្រាស់ពីសំណាក់ ភាគីណាឡើយ ពោលគឺជាការព្រមព្រៀងដែលគ្មានវិការៈ។

**មូលហេតុដែលបង្កឱ្យមានវិការៈមានដូចខាងក្រោម[7]៖**

**ការភាន់ច្រឡំ៖** ក្នុងករណីដែលភាគីមានការភាន់ច្រឡំ អំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាព ដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញ ឆន្ទៈនោះមានវិការៈ។

**ក្នុងករណីកិច្ចសន្យាក្រុមហ៊ុនការភាន់ច្រឡំអាចកើតមានតាមពីររបៀបគឺ៖[8]**

- **ការភាន់ច្រឡំលើកម្មវត្ថុ ៖** គឺអាចកើតមានលើប្រភេទកិច្ចសន្យាដែលធ្វើដោយភាគីទាំងឡាយដែលភាគីខ្លះគិតថាជាកិច្ចសន្យាក្រុមហ៊ុន ហើយភាគីម្ខាងទៀតថាជាកិច្ចសន្យាខ្ចីប្រាក់ ឬកិច្ចសន្យាការងារដែលចូលរួមក្នុងកម្រៃ។
- **ការភាន់ច្រឡំលើបុគ្គល ៖** ជាការវាយតម្លៃខុសលើអត្តសញ្ញាណនៃបុគ្គលជាសមាជិក ឬគុណភាពពិតប្រាកដរបស់គេ ដូចជាសមត្ថភាពការងារ។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញថាវាមានលក្ខណៈ ពិសេស និង ជាករណីលើកលែងចំពោះការភាន់ច្រឡំលើបុគ្គល ដោយសារ

[7] មាត្រា៣៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[8] មាត្រា៣៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ថា ការភាន់ច្រឡំលើបុគ្គលនេះមិនអាចក្លាយជាមូលហេតុ ដែលធ្វើអោយកិច្ចសន្យាអសុពលភាព ហើយវាក៏មិនអាចធ្វើជាមូលហេតុនៃការលុបចោលកិច្ចសន្យានោះដែរ។

**ការឆបោក ៖** បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈ អាចលុបចោលនូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹងឬ អាចដឹងអំពីការឆបោកនោះ[9]។ ជាករណីដែលភាគីណាមួយនៃកិច្ចសន្យាបានប្រើឧបាយកលអ្វីមួយ ដើម្បីឱ្យបុគ្គលម្នាក់ទៀតចុះកិច្ចសន្យាព្រមព្រៀងដោយមានការភាន់ច្រឡំ ហើយដោយសារការភាន់ច្រឡំនេះ ទើបនាំឱ្យមានវិការៈ។

**ហិង្សា ៖** គឺជាករណីនៃការបង្ខំលើឆន្ទៈនៃបុគ្គលណាម្នាក់ ដើម្បីឱ្យគេព្រមចូលហ៊ុន។ គេមិនជួបប្រទះករណីនេះក្នុងកិច្ចសន្យាក្រុមហ៊ុនឡើយ ប៉ុន្តែគេអាចប្រទះឃើញអំពើនេះក្រោមរូបភាពដូចជាក្នុងករណីប្រធានសក្តិដែលបង្ខំជនណាម្នាក់ឱ្យព្រមព្រៀងធ្វើកិច្ចសន្យាក្រុមហ៊ុនហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។ គ្រប់សាជីវកម្មដែលកំពុងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាសុទ្ធតែត្រូវបញ្ចេញឆន្ទៈប្រកប ដោយភាពសុចរិតរបស់សមាជិកភាគហ៊ុននីមួយៗ ទើបក្រុមហ៊ុននោះត្រូវបានច្បាប់ទទួលស្គាល់ និងមានភាពត្រឹមត្រូវពិតប្រាកដទៅតាមគោលការណ៍គ្រឹះនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន។

**ការគម្រាមកំហែង ៖** បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជនអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[10]។

ជារួមមកសមាជិកភាគហ៊ុនទាំងអស់ត្រូវតែឈរលើគោលការណ៍គ្រឹះមួយគឺកាព្រមព្រៀងរវាងគ្នានឹងគ្នាប្រកបដោយឆន្ទៈយ៉ាងពិតប្រាកដ ហើយមិនត្រូវមានវិការៈណាមួយកើតឡើងឡើយក្នុងកិច្ចសន្យានៃការព្រមព្រៀង បើពុំដូច្នោះទេ ក្រុមហ៊ុននឹងពុំអាចដំណើរការធ្វើពាណិជ្ជកិច្ចរបស់ខ្លួនឡើយ។

### ១.១.១.២. សមត្ថភាពរបស់សមាជិកភាគហ៊ុន

សមាជិករបស់ក្រុមហ៊ុនត្រូវតែជាបុគ្គលដែលមាន បុគ្គលិកលក្ខណៈសម្បត្តិរឹងមាំ អាចយល់ដឹងនូវពត៌មានទូទៅ និងចេះស្វែងយល់នូវកិច្ចការរាក់ជ្រៅមិនមែនជាបុគ្គលអសមត្ថភាពក្នុងការស្វែងយល់នូវពត៌មាននានា ឬការងារនានាឡើយ។

[9] មាត្រា៣៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[10] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងក្រមរដ្ឋប្បវេណី២០០៧ បានកំណត់នូវរូបវន្តបុគ្គល ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក្នុងការចូលរួមបង្កើតនូវនីតិបុគ្គលក្រុមហ៊ុន ឬប្រកបពាណិជ្ជកម្ម លុះត្រាតែបុគ្គលនោះមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ លើកលែងតែអនីតិជនដែលរួចផុតពីអាណាព្យាបាល[11]។

សមត្ថភាពបុគ្គល គឺជារឿងសំខាន់ ព្រោះប្រសិនបើក្រុមហ៊ុនត្រូវបានគ្រប់គ្រងដោយបុគ្គល ដែលគ្មានសមត្ថភាពតាមផ្លូវច្បាប់ទេ នោះក្រុមហ៊ុនក៏មិនអាចបង្កើត និងដំណើរការបានយូរនោះដែរ។ ហេតុដូចនេះហើយ ទើបបានជាច្បាប់កំណត់ថាសមាជិកភាគហ៊ុនដែលត្រូវចូលរួមបង្កើតក្រុមហ៊ុនទាំងអស់ ត្រូវតែមានសមត្ថភាពពេញលេញ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់។

សមាជិកទាំងអស់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មិនចាំបាច់មានលក្ខណៈសម្បត្តិជាពាណិជ្ជករនោះទេ ឲ្យតែមានសមត្ថភាពបំពេញកិច្ចស៊ីវិលជាការគ្រប់គ្រាន់ហើយ។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចមានសមាជិកជា ៖[12]

- ✓ អនីតិជនមានអត្តាធីនភាព
- ✓ ស្វាមីភរិយា តាមរបបទ្រព្យសម្បត្តិ
- ✓ ជនបរទេស ប៉ុន្តែមិនចាំបាច់មានអត្តសញ្ញាណប័ណ្ណជាពាណិជ្ជករនោះទេ
- ✓ ចំពោះមន្រ្តីរាជការ មិនមានបទបញ្ញត្តិណាមួយកំណត់ពីការហាមឃាត់ និង វិសមិតភាពចំពោះការចុះឈ្មោះចូលក្រុមហ៊ុននោះឡើយ លើកលែងតែជាតួនាទីដឹកនាំ (**បកស្រាយលំអិតនៅចំណុចបន្ទាប់**)។
- ✓ នីតិជនសមត្ថជន ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។

យោងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មកម្ពុជាបានបញ្ញត្តិ នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើនដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ អាចបង្កើតក្រុមហ៊ុនមូលធនបានដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឲ្យមន្រ្តីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។[13]

[11] មាត្រា២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[12] គង់ សាផន , នីតិពាណិជ្ជកម្ម ( ភ្នំពេញ ឆ្នាំ២០១២ ) ទំព័រ២៦៩

[13] មាត្រា៩១ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

សរុបសេចក្តីមក ច្បាប់ចាត់ទុករូបវន្តបុគ្គលដែលមានសមត្ថភាពក្នុងការចូលរួមជាសមាជិក ភាគហ៊ុនក្នុងការបង្កើតនីតិបុគ្គលក្រុមហ៊ុន និងប្រកបពាណិជ្ជកម្មបាន លុះត្រាតែរូបវន្តបុគ្គលនោះមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ឬអនីតិជនដែលរួចផុតពីអាព្យាបាល និងមានបុគ្គលិកលក្ខណៈមិនផ្ទុយច្បាប់ ។

#### **១.១.១.៣. កម្មវត្ថុ**

កិច្ចសន្យាបង្កើតក្រុមហ៊ុន មានកម្មវត្ថុស្វែករកប្រាក់ចំណេញដូចបានកំណត់ នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនកម្មវត្ថុអាជីវកម្មក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ ( ក្រុមហ៊ុនមូលធន ) ត្រូវតែស្របទៅនឹងច្បាប់ សណ្តាប់ធ្នាប់សាធារណៈ ប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ និងផលប្រយោជន៍របស់សមាជិកហ៊ុន។ ប្រសិនបើកម្មវត្ថុនៃការបង្កើតក្រុមហ៊ុនផ្ទុយទៅនឹងលក្ខខណ្ឌណាមួយខាងលើ ដែលច្បាប់បានហាមការបង្កើតក្រុមហ៊ុននេះ អាចនឹងត្រូវបដិសេធការសុំចុះបញ្ជីដោយមន្ត្រីចុះបញ្ជីក្រសួងពាណិជ្ជកម្ម។

ឧទាហរណ៍ ៖ ក្រុមហ៊ុនដែលបង្កើតឡើងក្នុងគោលបំណងធ្វើការជួញដូរមនុស្ស ឬ ជួញដូរ គ្រឿងញៀនជាដើម មិនត្រូវបានអនុញ្ញាតឲ្យបង្កើតឡើងនោះទេ ដោយសារតែកម្មត្ថុរបស់ក្រុមហ៊ុន គឺធ្វើការជួញដូរមនុស្ស និង គ្រឿងញៀនដែលកម្មវត្ថុបែបនេះ ត្រូវបានច្បាប់ធ្វើការហាមឃាត់ហើយវាក៏មិនស្របទៅនឹងប្រពៃណីទំនៀមទម្លាប់របស់ខ្មែរផងដែរ។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាត ឲ្យបោះលក់មូលបត្រជាសាធារណៈ។[14]

### **១.១.២. លក្ខខណ្ឌទម្រង់នៃការបង្កើតក្រុមហ៊ុន**

កិច្ចសន្យាបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើឡើងដោយលាយលក្ខណ៍អក្សរដែលជា លក្ខខណ្ឌចាំបាច់ ប្រសិនបើកិច្ចសន្យានេះ មិនបានបំពេញនូវលក្ខខណ្ឌទម្រង់ ឬ បំពេញដែរ ប៉ុន្តែមិនបានត្រឹមត្រូវ នាំឲ្យកិច្ចសន្យាបង្កើតក្រុមហ៊ុននោះនឹងត្រូវបានចាត់ទុកជាមោឃៈ ឬចាត់ទុកថាមិនបានបង្កើតឡើងត្រឹមត្រូវតាមផ្លូវច្បាប់។

លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមូលធន ជាឯកសារសំខាន់ដែលក្រុមហ៊ុនត្រូវរៀបចំឲ្យមានជាចាំបាច់។ រាល់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតទាំងអស់ ត្រូវ

[14]មាត្រា៨៧ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ចុះហត្ថលេខាដោយសមាជិកភាគហ៊ុនដែលមាន អាទិភាព និងត្រូវតម្កល់ទុកនៅនឹងមន្ត្រីចុះបញ្ជីក្រសួងពាណិជ្ជកម្ម និងនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនផងដែរ។

ដូច្នេះកិច្ចសន្យាបង្កើតក្រុមហ៊ុននេះ មានសុពលភាពអាចអនុវត្តបាន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានការចុះហត្ថលេខាយល់ព្រមពីសមាជិកទាំងអស់ទៀតផង។

### ១.១.២.១.នាមករណ៍ក្រុមហ៊ុន

ក្រុមហ៊ុននេះត្រូវដាក់ពាក្យ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនៅខាងចុង ឬខាងក្រោម។ មន្ត្រីចុះបញ្ជីមានសិទ្ធិបដិសេធមិនចុះបញ្ជីចំពោះឈ្មោះស្រដៀង និងធ្វើឱ្យមានការភ័ន្តច្រឡំជាមួយនាមករណ៍ណាមួយ ដែលបានចុះបញ្ជីពីមុន ឬផ្ទុយនឹងវប្បធម៌ ឬប្រពៃណីកម្ពុជា ឬមានលក្ខណៈអាសអាភាស អាស្រូវ ឬមិនសមរម្យ។

### ១.១.២.២.ភាគទុន

សម្រាប់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដើមទុនរបស់ក្រុមហ៊ុន តម្រូវឱ្យមានចាប់ពី ៤លានរៀលឡើងទៅ។ ដោយនៅក្នុងនោះភាគទុន អាចមានជាសាច់ប្រាក់ ឬជាវត្ថុ។ ដោយឡែកចំណេះ ជំនាញ និងបទពិសោធន៍ច្បាប់មិនអនុញ្ញាតឱ្យកំណត់ជាភាគទុននៅក្នុង ក្រុមហ៊ុនប្រទេសនេះបានឡើយ ដោយហេតុថាក្រុមហ៊ុនប្រភេទតម្រូវឱ្យសមាជិកទាំងអស់រួមចំណែកទៅលើបំណុលរបស់ក្រុមហ៊ុននិងមិនអាចដកហ៊ុនដែលខ្លួនបានដាក់។ ហើយការទទួលខុសត្រូវរបស់សមាជិកក្រុមហ៊ុនត្រឹមកម្រិតភាគហ៊ុនដែលខ្លួនបានដាក់ប៉ុណ្ណោះ។ សម្រាប់តម្លៃដើម (តម្លៃចារិកនៃភាគហ៊ុន) ក្នុងមួយប័ណ្ណមិនអាចមានតម្លៃក្រោយ ៤០០០រៀលបានឡើយ។ ការបោះពុម្ពភាគហ៊ុន និងការលក់ភាគហ៊ុននៅលើផ្សាហ៊ុនធ្វើឡើងលុះត្រាតែក្រុមហ៊ុនទទួលបាននូវនីតិបុគ្គលិកលក្ខណៈ ក្នុងនាមជាក្រុមហ៊ុន។ ភាគទុនជាវត្ថុប្រសិនបើ ភាគទុនជាវត្ថុគឺត្រូវវាយតម្លៃជាចំនួនសាច់ប្រាក់ ហើយអភិបាលទាំងឡាយជាអ្នក កំណត់ពីតម្លៃនៃវត្ថុនោះ សេចក្តីសម្រេចរបស់អភិបាលទាំងឡាយនោះចាត់ទុកជាបានការ បើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ។ តែបើមិនដូច្នោះទេ ភាគទុនជាវត្ថុនោះ ត្រូវមានការវាយតម្លៃចេញជាសាច់ប្រាក់ដោយសវនករ ហើយសវនករ ត្រូវជ្រើសរើសដោយក្រុមប្រឹក្សាភិបាលនៅក្នុងមហាសន្និបាតដំបូង ឬត្រូវបានជ្រើសរើសដោយតុលាការ។ ភាគទុនជាវត្ថុត្រូវតែធ្វើការផ្ទេរទាំងស្រុង។

### ១.១.២.៣. ការចូលរួមលើលទ្ធផល

ការចូលរួមលើលទ្ធផល សមាជិកនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតទទួលបានភាគលាភប្រាក់ចំណេញ ដោយសមាមាត្រទៅ តាមភាគហ៊ុនដែលខ្លួនបានដាក់ ឬតាមខដែលបានកំណត់នៅក្នុងកិច្ច

សន្យាក្រុមហ៊ុន។ ដោយឡែកការខាតបង់ក៏ដូចគ្នាដែលសមាជិកម្នាក់ៗ ត្រូវទទួលការខាតបង់លើអំពីចំនួនភាគហ៊ុនដែលបានចូលរួម ឬត្រឹមហ៊ុនដែលខ្លួនបានដាក់ដោយមិនប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនឡើយ។

### ១.១.២.៤. ការផ្សព្វផ្សាយជាសាធារណៈ

ការផ្សព្វផ្សាយជាសាធារណៈ ជាលក្ខខណ្ឌទម្រង់ត្រូវអនុវត្តជាដាច់ខាត តាមរយៈសារពត៌មានស្របច្បាប់ ការតម្កល់ទុកនៅក្នុងក្រសួងពាណិជ្ជកម្ម ប្រតិវេទន៍អនុលោមភាព និងការចុះបញ្ជីពាណិជ្ជកម្ម។

#### ក. ការផ្សព្វផ្សាយក្នុងផ្សារពត៌មានស្របច្បាប់

ការចុះផ្សាយនេះ ជាសាធារណៈត្រូវធ្វើឡើងដោយស្ថាបនិក ឬអភិបាល ឬអាណត្តិជនណាម្នាក់ដែលក្រុមហ៊ុនបានប្រគល់សិទ្ធិឱ្យ។ អភិបាលក្រុមហ៊ុន ឬសមាជិកក្រុមហ៊ុន ឬអាណត្តិជនមួយរូប ដែលបានទទួលអាណត្តិពិសេសត្រូវបំពេញពាក្យសុំចុះផ្សាយសេចក្តីប្រកាសស្តីពីការបង្កើតក្រុមហ៊ុន ត្រូវចុះផ្សាយក្នុងរាជកិច្ចព្រឹត្តប័ត្ររបស់ក្រសួងពាណិជ្ជកម្ម ឬសារពត៌មានស្របច្បាប់។ ស្ថាបនិក ឬអភិបាលម្នាក់ៗគឺជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តនូវការផ្សព្វផ្សាយ ដែលតម្រូវដោយច្បាប់។[15]

នៅក្នុងការប្រកាសផ្សាយ ត្រូវមានចុះនូវនិទ្ទេសសំខាន់ៗដូចជា ទ្រង់ទ្រាយក្រុមហ៊ុន កម្មវត្ថុ ចិរវេលា ដើមទុនក្រុមហ៊ុនជាទឹកប្រាក់ នាមករណ៍ក្រុមហ៊ុន ឈ្មោះ និងអាស័យដ្ឋាននៃសមាជិកក្រុមហ៊ុនដែលជាអ្នកទទួលខុសត្រូវផ្ទាល់។ពាក្យសុំចុះផ្សាយសេចក្តីប្រកាសនេះ ដែលមានការបញ្ជាក់យល់ព្រមទទួលចុះផ្សាយជាសាធារណៈ ត្រូវរក្សាទុកយ៉ាងតិចពីរច្បាប់សម្រាប់ភ្ជាប់ បំពេញសំណុំលិខិតពេលដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម។

ក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជូនច្បាប់ចម្លងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និងរាល់ឯកសារដែលពាក់ព័ន្ធដល់ការចុះបញ្ជីពាណិជ្ជកម្មដើមមួយច្បាប់ជូនទៅតុលាការពាណិជ្ជកម្មដើម្បីតម្កល់ឯកសារសម្រាប់យុត្តាធិការពាណិជ្ជកម្ម។

#### ខ. ការតម្កល់ទុកក្នុងក្រសួងពាណិជ្ជកម្ម

រាល់ទម្រង់លិខិត និងឯកសារទាំងអស់ដែលទាក់ទងទៅនឹងការបង្កើតក្រុមហ៊ុន ត្រូវយកទៅតម្កល់ទុកនៅនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ដោយស្ថាបនិកក្រុមហ៊ុននៅពេលដែលដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ ក្រោយពីបានយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងសោហ៊ុយនៃការតម្កល់នោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញលិខិតបញ្ជាក់មួយជាសម្គាល់។ ប្រការដែលមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មតម្កល់ទុកឯកសាររបស់ក្រុមហ៊ុន ឬប្រការដែល

[15] មាត្រា៩០ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ឯកសារសម្រាប់ធ្វើអធិការកិច្ច ដែលថតចម្លងទុកនៅក្នុងការិយាល័យក្រុមហ៊ុនមិនត្រូវបានចាត់ទុកថាធ្វើឱ្យប៉ះពាល់ ទៅលើបុគ្គលណាមួយ ឬជាការជូនដំណឹងដល់បុគ្គលណាមួយឡើយ[16]។

### គ. ប្រតិវេទន៍អនុលោមភាព

ប្រតិវេទន៍អនុលោមភាព[17] គឺជាបែបបទនៃសំណុំលិខិតដែលមានទម្រង់លក្ខណៈជាសេចក្តីប្រកាស ដែលធ្វើឡើងដោយសមាជិកហ៊ុនទាំងអស់គ្នាដែលធានាបញ្ជាក់អះអាងថា បានប្រតិបត្តិដោយត្រឹមត្រូវនូវទម្រង់នៃការបង្កើតក្រុមហ៊ុន នឹងសមស្របទៅតាមតម្រូវការនៃបទប្បញ្ញត្តិទាំងឡាយនៃច្បាប់។

ប្រតិវេទន៍អនុលោមភាពត្រូវបានតាក់តែងឡើងជាឯកសារសម្រាប់ភ្ជាប់បំពេញ សំណុំលិខិតនៅពេលដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម។ ការដែលខ្វះប្រតិវេទន៍នេះ ឬផ្នែកណាមួយដែលមិនត្រឹមត្រូវតាមគំរូ នឹងធ្វើឱ្យការចុះបញ្ជីពាណិជ្ជកម្មមិនអាចត្រូវបានទទួលស្គាល់ឡើយ។

ប្រតិវេទន៍នេះត្រូវធ្វើឡើងចំនួនបីច្បាប់យ៉ាងតិច និងត្រូវមានការចុះហត្ថលេខារបស់សាមីខ្លួនអ្នកសុំ ដូចជាស្ថាបនិក អភិបាល ឬ សមាជិកក្រុមហ៊ុន។ ប្រតិវេទន៍មួយច្បាប់ត្រូវបានរក្សាទុកនៅទីស្នាក់ការក្រុមហ៊ុន និងពីរច្បាប់ទៀតភ្ជាប់ទៅជាមួយពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម[18]។ ក្នុងករណីមានការកែប្រែលក្ខន្តិកៈ ត្រូវធ្វើជាថ្មីនូវប្រតិវេទន៍អនុលោមភាពតែប្រតិវេទន៍ថ្មីនេះត្រូវចុះហត្ថលេខាដោយអភិបាលតែម្នាក់គត់គឺ គ្រប់គ្រាន់។

ប្រតិវេទន៍នេះត្រូវមាននិទ្ទេសទាក់ទងនឹងបុគ្គល (នាមរបស់ពាណិជ្ជករ ឬរបស់សមាជិកក្រុមហ៊ុន សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងរឿងពាណិជ្ជកម្ម សញ្ជាតិ ស្ថានភាព គ្រួសារ និងគ្រឹះស្ថាន (ពាណិជ្ជនាម របស់នាម អាស័យដ្ឋាន ផ្លាកសញ្ញាក្រុមហ៊ុន កម្មវត្ថុរបស់ក្រុមហ៊ុន ពាណិជ្ជកម្មពោលគឺព័ត៌មានដែលទាក់ទងនឹងមូលនីធិពាណិជ្ជកម្ម) ។

ប្រតិវេទន៍ធ្វើឡើងដោយ៣ច្បាប់ចំពោះក្រុមហ៊ុនដែលត្រូវយកទៅដាក់ដោយអ្នកស្នើសុំ ឬអាណត្តិតាហកដែលមានលិខិតប្រគល់សិទ្ធិអំណាច ហើយលិខិតនេះត្រូវតម្កល់ទុកនៅកន្លែងទទួលពាក្យសុំចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

[16] មាត្រា១០៥ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[17] មាត្រា ១៤ កថាខណ្ឌ៤ ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម

[18] មាត្រា ២១ ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្ម ឆ្នាំ១០៩៥

បើប្រតិវេទន៍យកទៅដាក់ដោយផ្ទាល់ ដោយអ្នកស្នើរសុំ មន្ត្រីចុះឈ្មោះពាណិជ្ជកម្ម និងធ្វើការផ្ទៀងផ្ទាត់ ក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន អំពីបែបបទទាំងឡាយតាមបញ្ញត្តិច្បាប់ដូចជា ត្រូវចុះនៅលើផ្នែកខាងលើនៃប្រតិវេទន៍នៅនីតិវិធីដូចតទៅៈ

- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការកំណត់ និងទីកន្លែង
- លេខរៀងប្រតិវេទន៍តាមលំដាប់ជាបន្តបន្ទាប់
- អត្តលេខសំគាល់តាមប្រភេទនៃសកម្មភាពរបស់ពាណិជ្ជកម្មដែលត្រូវចុះបញ្ជីវិភាព (តារាងធ្វើវិភាគលើស្ថានភាពក្រុមហ៊ុនដើមទុន) ។

ចំពោះអ្នកធ្វើប្រតិវេទន៍ដែលមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ការចុះបញ្ជី និងត្រូវបានអនុញ្ញាតពិសេសចំនួន ១៥ថ្ងៃ បន្ថែមទៀត ។ បន្ទាប់ពីបានពិនិត្យ ប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងឯកសារតម្កល់រួចរាល់ ហើយមន្ត្រីចុះបញ្ជី នឹងផ្តល់នូវវិញ្ញាបនបត្រចុះបញ្ជីដែលហៅថា**សំរង់** ដែលមានចុះអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាណបនបត្រនេះ ត្រូវបិតនៅក្នុងលក្ខណៈបណ្តោះអាសន្នក្នុងរយៈពេល ១ ខែ គត់ គិតចាប់តាំងពីថ្ងៃដែលបានផ្តល់ជូន ក្នុងចិរវេលានេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មអាចជំទាស់បាននូវការចុះបញ្ជីនេះ និងលុបចោលអត្តលេខសំគាល់ដែលមានចុះ ក្នុងបញ្ជីហើយ។ ច្បាប់ពុំបានកំណត់ច្បាស់លាស់ នូវរយៈពេលនៃការចេញវិញ្ញាបនបត្របណ្តោះអាសន្ននោះទេ។ ការបើនិទ្ទេសដែលមាននៅក្នុងប្រតិវេទន៍ ត្រូវបានកត់ត្រាទុកក្នុងបញ្ជីវិភាពមន្ត្រីចុះបញ្ជីត្រូវប្រគល់ជូនអ្នកដែលយកមកតម្កល់នៅប្រតិវេទន៍មួយច្បាប់ដែល មានហត្ថលេខាត្រឹមត្រូវសម្រាប់ប្រើប្រាស់ជាវិញ្ញាណបនបត្រចុះឈ្មោះប៉ុណ្ណោះ ។ លើសពីនេះទៅទៀត នៅក្នុងលិខិតប្រតិវេទន៍នោះ គេរៀបរាប់ចំណុចសំខាន់ៗ មួយចំនួនដូចជា នាមករណ៍ អាស័យដ្ឋានស្នាក់ការចុះបញ្ជី សមាសភាពម្ចាស់ភាគហ៊ុន និងការកែប្រែ សមាសភាពក្រុមប្រឹក្សាភិបាល និងការប្រែប្រួល កម្មវត្ថុ លេខកូដចុះបញ្ជី សញ្ជាតិ ទ្រង់ទ្រាយក្រុមហ៊ុន និងសាខា គោលការណ៍របស់ក្រសួងពាណិជ្ជកម្ម គោលការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគោលការណ៍ផ្សេងៗទៀត។

### ១.១.២.៥. ការចុះបញ្ជីក្រុមហ៊ុន

ពាណិជ្ជករត្រូវចុះឈ្មោះ ក្នុងបញ្ជីពាណិជ្ជកម្មនាកន្លែងដែលខ្លួនធ្វើអាជីវកម្ម យ៉ាងតិចបំផុត១៥ថ្ងៃ មុនពេលចាប់ផ្តើមធ្វើពាណិជ្ជកម្មរបស់ខ្លួន។

គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើត និងចិរវេលារបស់ក្រុមហ៊ុន ទាំងនោះមានលក្ខណៈបែបណាក៏ដោយ។ ក្រុមហ៊ុន

ទទួលបានបុគ្គលិកលក្ខណៈ គឺគិតពីកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម[19]។ ការចុះបញ្ជីឈ្មោះនេះត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃក្រុមហ៊ុននៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងដប់ប្រាំថ្ងៃ(១៥ថ្ងៃ) មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម[20]។

អ្នកស្នើសុំចុះឈ្មោះ ត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវ ប្រតិវេទន៍ចំនួន២ច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង។ ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះត្រូវចែងអំពីនាមត្រកូល និងនាមខ្លួន រហស្សនាម របស់សមាជិកក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ។

1. ផ្លាកសញ្ញារបស់ក្រុមហ៊ុន
2. កម្មវត្ថុនៃក្រុមហ៊ុន
3. ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើមមានសាខាឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា
4. នាមនៃសមាជិក ឬតតិយជន ដែលមានការអនុញ្ញាតឲ្យគ្រប់គ្រងចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនោះ
5. ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ ឬវត្ថុមានតម្លៃដែលផ្តល់ដោយសមាជិកភាគហ៊ុន
6. ថ្ងៃខែ ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើមនិងបញ្ចប់
7. ទ្រង់ទ្រាយក្រុមហ៊ុន
8. ហត្ថលេខាគំរូរបស់សមាជិកឬតតិយជនដូចមានចែងនៅចំណុចលេខ៥ និងស្នាមត្រាគំរូរបស់ក្រុមហ៊ុន
9. លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ
10. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌឡើយ។[21]

[19] មាត្រា ៩៨ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[20] មាត្រា ១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ១៩៩៩

[21] មាត្រា ១៧ នៃច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ១៩៩៩

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ការចុះបញ្ជីពាណិជ្ជកម្មពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន ព្រោះថាក្រុមហ៊ុនដែលមាននីតិបុគ្គលិកលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើសកម្មភាពពាណិជ្ជកម្មបាន គឺគិតចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម[22]។ រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ និងរាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក័យប័ត្រ លិខិតស្នាម កំណត់បញ្ជាទិញ តារាងតម្លៃ និង ឯកសារ ផ្សព្វផ្សាយអំពីទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មដែលខ្លួនបានចុះ ឈ្មោះ និង លេខ ដែលខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្មច្បាប់ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំម៉ឺន(៥០.០០០) រៀល ទៅប្រាំសែន (៥០០.០០០) រៀល[23]។

**ឯកសារតម្រូវ និងកម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីក្រុមហ៊ុនមានដូចខាងក្រោម៖**

**+ ឯកសារ**

- ពាក្យស្នើសុំ គំរូ ក[24] ៖ ៣ ច្បាប់ (២ ច្បាប់ដើម ១ ច្បាប់ថតចម្លង)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ ដោយមានចុះហត្ថលេខា ឬស្នាមមេដៃផង ៖ ៣ សន្លឹកសម្រាប់ម្ចាស់ហ៊ុន និងអភិបាល ម្នាក់ៗ
- រូបថត (4x6 cm) របស់ម្ចាស់ហ៊ុន និងអភិបាលម្នាក់ៗ ៖ ៣ សន្លឹក
- លិខិតធានាពីធនាគារដែលបញ្ជាក់ថាមានតម្កល់ប្រាក់យ៉ាងតិចស្មើនឹងដើមទុនអប្បបរមា ចំនួន ៤លានរៀល ៖ ១ ច្បាប់ដើម
- លក្ខន្តិកៈ ៖ ៣ ច្បាប់

**+ កម្រៃ**

- កម្រៃរដ្ឋបាលចុះបញ្ជីជាផ្លូវការ 25៖ ៤២០.០០០ រៀល

**បើសិនម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនគឺជានីតិបុគ្គលនោះតម្រូវឱ្យមានឯកសារបន្ថែមដូចខាងក្រោមនេះ៖**

[22] មាត្រា ៩៨ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[23] មាត្រា ៤០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ១៩៩៩

[24] ឧបសម្ព័ន្ធទី២ ពាក្យសុំគំរូ ក

[25] មាត្រា ៣ នៃច្បាប់ស្តីពី សារពើពន្ធ ឆ្នាំ២០០៤

**+ ឯកសារ**

- លក្ខន្តិកៈក្រុមហ៊ុនដោយមានការបញ្ជាក់ថាមានការថតចម្លងត្រឹមត្រូវ ៖ ១ ច្បាប់ថតចម្លង
- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនដោយមានការបញ្ជាក់ថាថតចម្លងត្រឹមត្រូវ ៖ ១ ច្បាប់ថតចម្លង
- លិខិតតែងតាំងអ្នកតំណាងនៅក្នុងក្រុមហ៊ុនថ្មីរបស់ម្ចាស់ហ៊ុនសាជីវកម្មនីមួយៗ ៖ ១ ច្បាប់ដើម
- រូបថតរបស់អ្នកតំណាងម្ចាស់ហ៊ុនសាជីវកម្ម ៖ ៣ សន្លឹក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់អ្នកតំណាងម្ចាស់ហ៊ុន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ ៖ ៣ ច្បាប់។

**១.១.២.៦. សញ្ជាតិ**

ក្រុមហ៊ុនមូលធនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរទៅបានលុះត្រា ៖

១. ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។

**១.១.២.៧. សមត្ថភាពនិងសិទ្ធិរបស់ក្រុមហ៊ុន**

ក្រោយពីបានតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងការបង់កម្រៃរដ្ឋបាល មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន នៃក្រសួងពាណិជ្ជកម្មត្រូវចេញជាលិខិតបញ្ជាក់មួយជាសម្គាល់។

បន្ទាប់ពីការចុះបញ្ជីមានសិទ្ធិ កាតព្វកិច្ច និងមានសមត្ថភាព ធ្វើសកម្មភាពក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ដូចរូបវន្តបុគ្គលដែរ។ ការទទួលបាននីតិបុគ្គលិកលក្ខណៈ នេះនាំឲ្យក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចបានទូទាំងព្រះរាជាណាចក្រកម្ពុជា[26] ហើយថែមទាំងមានសិទ្ធិអាចធ្វើពាណិជ្ជកិច្ចក្រៅប្រទេសបានថែមទៀតប្រសិនបើប្រទេសនោះផ្តល់ការអនុញ្ញាត។

**១.១.២.៨. ខ្លឹមសារលក្ខន្តិកៈរបស់ក្រុមហ៊ុន**

លក្ខន្តិកៈក្រុមហ៊ុនក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបំពេញលក្ខខណ្ឌក្នុងលក្ខន្តិកៈដូចតទៅ៖

[26] មាត្រា ៩៩ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

1. នាមករណ៍របស់ក្រុមហ៊ុន
2. ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា
3. កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះធ្វើពាណិជ្ជកិច្ច។ ក្រុមហ៊ុនអាចមានកម្មវត្ថុអាជីវកម្មមួយឬច្រើនប្រភេទដែលមិនផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់។
4. ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ។
5. ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឲ្យបោះចេញដោយក្រុមហ៊ុននោះ។
6. ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឲ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយ ប្រភេទហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗ នៃប័ណ្ណភាគហ៊ុននោះ។
7. ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាស៊េរី លក្ខន្តិកៈក្រុមហ៊ុននោះត្រូវ អនុញ្ញាតឲ្យអភិបាលកំណត់ចំនួនភាគហ៊ុនជាស៊េរីនីមួយៗ ដើម្បីកំណត់ប្តូរប់បែងចែកស៊េរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងស៊េរីនីមួយៗនោះ។
8. ក្នុងករណីបោះចេញការផ្ទេរ ឬការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធភាព និងមានរបាយការណ៍ពីការកម្រិតនោះ។
9. ឈ្មោះនិងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ។
10. ចំនួនអភិបាល ឬចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ។

លក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតរវាងឯកជន ឬជាលិខិតសារការី។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខាសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ ឬហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ[27]។

[27] មាត្រា ៩៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

### ១.១.២.៨.១. ប្រភេទទូទៅនៃខ្លឹមសារលក្ខន្តិកៈ

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធន ដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន[28]។

### ១.១.២.៨.២. នាមករណ៍ក្រុមហ៊ុន

នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវដាក់ពាក្យថា " **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** " ឬសរសេរពាក្យកាត់ **ម.ក** ដោយដាក់ខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន[29]។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យនូវនាមករណ៍ដែលបានស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធនូវនាមករណ៍ណាដែល ប្រហាក់ប្រហែលគ្នាធ្វើឲ្យមានការភាន់ច្រឡំទៅនឹងនាមករណ៍ក្រុមហ៊ុនផ្សេងទៀត ដែលបានចុះបញ្ជីមុនរួចហើយ ឬនាមករណ៍មួយដែលផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ដែលមានឈ្មោះអាស្រូវ ឬដែលមិនសមរម្យ[30]។

សេចក្តីសម្រេចរបស់មន្ត្រី ទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដែលពាក់ព័ន្ធទៅនឹងនាមករណ៍របស់ក្រុមហ៊ុនគឺជាសេចក្តីសម្រេចចុងក្រោយ។

### ១.១.២.៨.៣. ចិរវេលាក្រុមហ៊ុននិងសញ្ជាតិក្រុមហ៊ុន

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវបានកំណត់ថាមានដំណើរការនៅក្នុង អំឡុងពេល ៩៩ ឆ្នាំ និងអាចចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញបាន។ ប៉ុន្តែក្រុមហ៊ុនអាចនឹងត្រូវ រំលាយមុនការកំណត់មកដល់ ឬពន្យាតាមលក្ខខណ្ឌដែលបានគ្រោងទុកនៅក្នុងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។ ស្របពេលជាមួយគ្នានោះដែរចិរវេលានេះ អាចត្រូវបានពន្យាពេលបន្ថែមទៀត ប្រសិនបើមានការសំរេចជាឯកច្ឆ័ន្ទពីសមាជិកហ៊ុនទាំងអស់[31]។

ចិរវេលារបស់ក្រុមហ៊ុន គឺជាដែនកំណត់អាយុមួយរបស់ក្រុមហ៊ុនទៅតាមលក្ខខណ្ឌគតិយុត្ត ហើយក្រុមហ៊ុននីមួយៗ អាចជ្រើសរើសចិរវេលារបស់ខ្លួនតាមពេលវេលាមួយជាក់លាក់នៃប្រភេទរបស់ក្រុមហ៊ុននីមួយៗ ដោយរយៈពេលខ្លី និងវែងមាន ២០, ៣០ និង៩០ឆ្នាំ។ ការសម្រេចជ្រើសរើសចិរវេលានេះគឺជាសិទ្ធិសេរីភាពរបស់ក្រុមហ៊ុន ព្រោះបើការដំណើរការប្រព្រឹត្តិទៅនៃអាជីវកម្ម របស់ក្រុមហ៊ុនទទួលជោគជ័យ ក្រុមហ៊ុននឹងមិន

---

[28] មាត្រា ៨៧ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[29] សារាចរណែនាំស្តីពីការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម លេខ ៣៦០ ពកប/សរណន, ០៣ ធ្នូ ឆ្នាំ១៩៩៧។

[30] មាត្រា ៩២ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[31] គង់ សាជន , នីតិពាណិជ្ជកម្ម (ភ្នំពេញ ឆ្នាំ២០០២) ទំព័រ២៧០

សម្រេចជ្រើសរើសរយៈពេលខ្លីឡើយ។ ជាទូទៅក្រុមហ៊ុនភាគច្រើនរើសយករយៈពេលមួយយូរគឺ៩៩ឆ្នាំ សម្រាប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ហើយអាចសុំពន្យារចិរវេលាទៀតបានដោយធ្វើការជូនដំណឹងទៅក្រសួងពាណិជ្ជកម្ម។

តាមគោលការណ៍ ក្រុមហ៊ុនត្រូវតែមានសញ្ជាតិមួយច្បាស់លាស់ ដែលជាការភ្ជាប់ទំនាក់ទំនង រវាងរដ្ឋ និងក្រុមហ៊ុន។ សញ្ជាតិក្រុមហ៊ុននេះបានផ្ដល់នូវសិទ្ធិ និងកាតព្វកិច្ចជាច្រើនក្នុងការអនុវត្តដែលច្បាប់បានផ្ដល់ឱ្យ និងទទួលបានការការពារពីរដ្ឋដែលខ្លួនមានសញ្ជាតិដូចជា សញ្ជាតិរបស់ រូបវន្តបុគ្គលផងដែរ។

ក្រុមហ៊ុនដែលមានសញ្ជាតិជាខ្មែរអាចប្រកបពាណិជ្ជកិច្ចក្នុងដែនកំណត់របស់ខ្លួនដែលច្បាប់ បានកំណត់។ ការកំណត់ផ្ដល់សញ្ជាតិដល់ក្រុមហ៊ុន គឺជាសិទ្ធិរបស់រដ្ឋដោយក្រុមហ៊ុននោះមានទីស្នាក់ការចុះបញ្ជីក្នុងប្រទេសនោះ។ ក្រុមហ៊ុនដែលត្រូវចាត់ថាជាក្រុមហ៊ុនមានសញ្ជាតិខ្មែរលុះត្រាៈ

១- ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១ (ហាសិប មួយ) ភាគរយត្រូវ បានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ។

### ១.១.២.៨.៤. ទីស្នាក់ការក្រុមហ៊ុន

ទីស្នាក់ការក្រុមហ៊ុន គឺជាអាស័យដ្ឋានការិយាល័យដើមរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងអាស័យដ្ឋានរបស់ភ្នាក់ងារជាអចិន្ត្រៃយ៍ចុះបញ្ជីផងដែរ។

ទីស្នាក់ការកណ្ដាលរបស់ក្រុមហ៊ុនជាទីតាំងសំខាន់មួយរបស់ក្រុមហ៊ុនក្នុងការអនុវត្តការងារផ្នែករដ្ឋបាលផងដែរ ហើយភាគច្រើនជាទីតាំងស្ថិតនៅកន្លែងប្រមូលផ្ដុំ ទៅដោយសកម្មភាពអាជីវកម្មពាណិជ្ជកម្ម និងឧស្សាហកម្ម។ ក្នុងការផ្លាស់ប្ដូរទីស្នាក់ការ ក្រុមហ៊ុនត្រូវផ្ដល់ដល់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវសេចក្ដីជូនដំណឹងអំពីទីតាំងទីស្នាក់ការចុះបញ្ជី ជាមួយគ្នានិងលក្ខន្តិកៈដែលស្ដីពីទីតាំងឬពីការផ្លាស់ប្ដូរទីតាំងស្នាក់ការចុះបញ្ជីនោះ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្ដូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជីត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្ដូរនោះ[32]។

[32] មាត្រា១០៨ ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

## ១.២.ដើមទុន និងភាគហ៊ុនរបស់ក្រុមហ៊ុន

ដើមទុនគឺជាមូលធនសំខាន់បំផុតក្នុងការបង្កើត និងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។ ការបង់ភាគទុន ជាវត្ថុអាចរួមបញ្ចូលពាណិជ្ជសញ្ញា សិទ្ធិអ្នកនិពន្ធ ប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិប្រើប្រាស់ទ្រព្យអរូបិយ ឬសិទ្ធិប្រើប្រាស់លិខិតអនុញ្ញាតពាណិជ្ជកម្ម។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមិនអនុញ្ញាតឲ្យមានភាគទុនជាសេវាកម្មនោះទេ ។

### ១.២.១. ដើមទុនរបស់ក្រុមហ៊ុន

ដើមទុនរបស់ក្រុមហ៊ុនគឺ ជាការដាក់សាច់ប្រាក់ ឬទ្រព្យសម្បិត្តិរបស់សមាជិកនីមួយៗរួមបញ្ចូលគ្នា ដើម្បីធានាដល់ការធ្វើប្រតិបត្តិការស្វែងរកប្រាក់ចំណេញ និងបោះមូលបត្ររបស់ក្រុមហ៊ុន។ ដើមទុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ។

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មិនទទួលយកលុយភាគទុនជំនាញបទពិសោធន៍ ឬសេវានោះទេ ។ ភាគទុនជាសាច់ប្រាក់ គឺជាភាគទុន ដែលមានលក្ខណៈទូទៅបំផុត ហើយសកម្មភាពនេះអាចបង់ជាដំណាក់ៗ ឬត្រូវបង់ទាំងស្រុងទៅតាមការកំណត់ក្នុងកិច្ចសន្យា។ ប្រសិនបើបង់ជាដំណាក់ៗសមាជិកនោះនឹងក្លាយទៅជាកូនបំណុលចំពោះទឹកប្រាក់ដែលជំពាក់ និងការប្រាក់ ត្រូវបង់ចូលក្រុមហ៊ុនតាមពេលកំណត់ ។ ការកំណត់ពីការបង់ការប្រាក់ គឺជាតួនាទីរបស់ក្រុមប្រឹក្សាភិបាល ហើយចំពោះការបង់បង្គ្រប់មិនត្រូវឱ្យលើសពី បីឆ្នាំឡើយ បន្ទាប់ពីការចុះបញ្ជីពាណិជ្ជកម្ម។

### ១.២.២. ភាគហ៊ុនរបស់ក្រុមហ៊ុន

ភាគហ៊ុន គឺជាប្រភេទនៃមូលបត្រដែលអាចលក់ដូរបានក្នុងទីផ្សារភាគហ៊ុន ដែលមានទៅតាមប្រភេទ ឬសេរី។ ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់។ ប័ណ្ណភាគហ៊ុននីមួយៗត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើប័ណ្ណនោះទេ។ សិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់ នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនត្រូវមានរចនាសម្ព័ន្ធសម្រាប់ការផ្តល់ហិរញ្ញវត្ថុដល់ប្រតិបត្តិការទាំងអស់ត្រូវបង់ឲ្យក្រុមហ៊ុននូវភាគហ៊ុនរបស់ខ្លួនដែលជាទម្រង់នៃមូលបត្រហ៊ុន។

ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់។ ភាគហ៊ុននីមួយៗត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណាមួយដែលមានតម្លៃចារឹកតិចជាង ចារឹកលើប័ណ្ណនោះទេ និងលក្ខខណ្ឌទាំងឡាយ ។ សិទ្ធិឯកសិទ្ធិការរឹតត្បិត ទាំងឡាយរបស់ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទដ៏ មួយៗត្រូវបាន កំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន[33]។

ក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនក្រុមហ៊ុនបោះលក់ចេញយ៉ាងតិចបំផុត១០០០ភាគហ៊ុនដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាង៤០០០រៀលក្នុងមួយហ៊ុន[34](៤ ០០០ ០០០៛)។

### ក.ប័ណ្ណភាគហ៊ុនមានមួយប្រភេទ

ប្រសិនបើលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេ នោះក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុនទាំងនោះគឺស្មើគ្នានិងរួមបញ្ចូលនូវសិទ្ធិ៖

- ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន
- ក្នុងការទទួលនូវរាល់ភាគលាភដែលបានប្រកាស់ដោយក្រុមហ៊ុន
- ក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុនមានការរំលាយក្រុមហ៊ុន[35]។

### ខ.ប័ណ្ណភាគហ៊ុនមានច្រើនជាងមួយប្រភេទ

លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចចែងមានភាគហ៊ុនច្រើនជាងមួយប្រភេទក្នុងករណីនេះ សិទ្ធិនៃប្រភេទរបស់ប័ណ្ណភាគហ៊ុននីមួយៗ អាចមានលក្ខណៈដាច់ខាតលក្ខណៈធៀប។ សិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹង ប្រភេទភាគហ៊ុននីមួយៗ ត្រូវកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ។ សិទ្ធិដែលបាន កំណត់(ប័ណ្ណភាគហ៊ុនមួយប្រភេទ) ខាងលើ ត្រូវភ្ជាប់មកដោយឡែក ឬទាំងស្រុងទៅនឹងភាគហ៊ុនមួយប្រភេទណាមួយ សិទ្ធិទាំងនោះរួមមាន៖

១). ភាពដែលអាចផ្ទេរបាន ឬភាពដែលអាចផ្លាស់ប្តូរបានក្នុងប្រភេទ ភាគហ៊ុនមួយផ្សេងទៀត ឬមូលបត្រផ្សេងទៀតនៃក្រុមហ៊ុនមូលធន ឬ ក្រុមហ៊ុនផ្សេងទៀតអាស្រ័យទៅលើជម្រើសរបស់ក្រុមហ៊ុន ឬអាស្រ័យទៅលើជម្រើសរបស់ម្ចាស់ហ៊ុន ឬអាស្រ័យទៅលើការកើតឡើងនៃ ព្រឹត្តិការណ៍ជាក់លាក់ណាមួយ។

[33] មាត្រា១៤៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[34] មាត្រា១៤៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[35] មាត្រា១៤៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

២). អាទិភាពនៃការទទួលយកទ្រព្យសម្បត្តិ ដែលសល់ពីការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុនមូលធន។

៣). ការលោះមកវិញ ការទិញឡើងវិញរបស់ក្រុមហ៊ុន ឬទៅតាមជម្រើសរបស់អ្នកកាន់កាប់ភាគហ៊ុន។

៤). ការរឹតត្បិតទៅលើភាពដែលអាចផ្ទេរបាន[36]។

ផ្អែកទៅតាមលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងរាល់សិទ្ធិដែលអាចទិញមុនគេរបស់ម្ចាស់ហ៊ុនភាគហ៊ុន និងមូលបត្រ អាចអនុញ្ញាតឲ្យបោះចេញទៅតាមពេលវេលា និងចំពោះបុគ្គលទាំងឡាយដែលអភិបាលក្រុមហ៊ុនកំណត់ឲ្យ។

អភិបាលត្រូវកំណត់តម្លៃរបស់ប័ណ្ណភាគហ៊ុន និងតម្លៃមូលបត្រដែលត្រូវលក់តម្លៃភាគហ៊ុនមិនត្រូវបោះចេញទេរហូតដល់ការបង់ថ្លៃសម្រាប់ភាគហ៊ុនត្រូវ បានបំពេញចប់សព្វគ្រប់ជាសាច់ប្រាក់។ ការបង់ភាគហ៊ុនជាវត្ថុបត្រតក្កកម្មជាវត្ថុ ឬជាសេវាពីមុនទៅក្នុងក្រុមហ៊ុន។

[36] ខាត់ ធី , នីតិសហគ្រាសពាណិជ្ជកម្ម ( ភ្នំពេញ ឆ្នាំ២០២៣ ) ទំព័រ៨២

# ជំពូកទី២

## ជំពូកទី២៖ ការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រោយពីរៀបចំ ចុះបញ្ជីនៅនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្មដោយតម្កល់ទុកនូវលក្ខន្តិកៈរបស់ក្រុមហ៊ុនរួចហើយ ក្រុមហ៊ុននឹងចាប់ផ្តើមដំណើរការអាជីវកម្មរបស់ខ្លួន ក្រោយកាលបរិច្ឆេទចុះបញ្ជីរយៈពេល ១៥ថ្ងៃ។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលដំណើរការទៅបានយ៉ាងរលូន ត្រូវតែមានក្បាលម៉ាស៊ីន ដឹកនាំពីថ្នាក់ដឹកនាំដែលមានអភិបាលដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលជ្រើសតាំងដោយម្ចាស់ភាគហ៊ុនជាអ្នកដឹកនាំគ្រប់គ្រងទៅលើរាល់ដំណើរការទាំងអស់នៃការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុន។

### ២.១. ការគ្រប់គ្រងនិងការត្រួតពិនិត្យក្រុមហ៊ុន

ដើម្បីធានាឱ្យបាននូវការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវមានអង្គការសំខាន់ៗសម្រាប់ត្រួតពិនិត្យ និងគ្រប់គ្រងលើរាល់ដំណើរការនៃការប្រព្រឹត្តិទៅនេះ ។

#### ២.១.១ .អភិបាល

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានឲ្យនិយមន័យនៃពាក្យ អភិបាល ថាជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។[37] លើសពីនេះទៅទៀត ច្បាប់ដដែលក៏បានបញ្ជាក់ផងដែរថា រាល់រូបវ័ន្តបុគ្គលដែលមានសមត្ថភាពមានអាយុលើសពី ១៨ (ដប់ប្រាំបី) ឆ្នាំ អាចបម្រើការងារជា អភិបាល ឬ ជាអ្នកគ្រប់គ្រងការងាររបស់ក្រុមហ៊ុនបាន។ អភិបាល មិនចាំបាច់ជាម្ចាស់ហ៊ុនទេ ឬ មិនចាំបាច់តម្រូវឲ្យមានលក្ខណៈសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុន តម្រូវឲ្យមានលក្ខខណ្ឌផ្សេងពីនេះ។[38] ជាទូទៅក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវ មានអភិបាលយ៉ាងតិច ០៣ (បី) រូប ហើយម្ចាស់ហ៊ុន ត្រូវបោះឆ្នោតជ្រើសរើសអភិបាលតាមរយៈ សេចក្តីសម្រេចសាមញ្ញនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត។[39]

##### ២.១.១.១.ការបោះឆ្នោតជ្រើសរើស និង អាណត្តិរបស់អភិបាល

ម្ចាស់ហ៊ុន ត្រូវបោះឆ្នោតជ្រើសរើសអភិបាល តាមរយៈសេចក្តីសម្រេចសាមញ្ញ ( ជាសេចក្តីសម្រេចមួយដែលត្រូវបានធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើនដាច់ខាត ដែលបានចូលរួមក្នុងការបោះឆ្នោត ) នៃម្ចាស់ហ៊ុន

[37] មាត្រា ៨៨ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[38] មាត្រា ១២០ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[39] មាត្រា ១១៨ វាក្យខណ្ឌ២-៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ដែលមានសិទ្ធិបោះឆ្នោត។[40] លក្ខន្តិកៈរបស់ក្រុមហ៊ុន អាចចែងបានផងដែរពី សិទ្ធិរបស់អ្នកកាន់ប័ណ្ណភាគហ៊ុននៃប្រភេទនីមួយៗ ដើម្បីបោះឆ្នោតជ្រើសរើសអភិបាល មួយ ឬ ច្រើន ដែលអភិបាលនោះនឹងបម្រើអាណត្តិ និងមានសិទ្ធិចាត់ចែងការងារផ្សេងៗដូចដែល បានចែងក្នុងលក្ខន្តិកៈ។ អាណត្តិនៃមុខតំណែង និងសិទ្ធិនៃការបោះឆ្នោតរបស់អភិបាលប្រភេទ មួយអាចច្រើនជាង ឬ តិចជាងអភិបាលប្រភេទមួយផ្សេងទៀតបាន។[41]

ជាទូទៅលក្ខន្តិកៈរបស់ក្រុមហ៊ុន នឹងធ្វើការកំណត់ពីអាណត្តិរបស់អភិបាល ថាតើអភិបាល នឹងបម្រើការងារប៉ុន្មានឆ្នាំក្នុងមួយអាណត្តិ។ ប៉ុន្តែបើសិនក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបាន កំណត់ពីអាណត្តិទេ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានកំណត់ឲ្យអភិបាលម្នាក់ៗ ត្រូវមាន អាណត្តិ ០២ (ពីរ) ឆ្នាំ ហើយអាចត្រូវបោះឆ្នោតឲ្យជាប់សារជាថ្មីទៀតបាន។[42] អាណត្តិរបស់អភិបាលអាចត្រូវកំណត់ជាដំណាក់ៗ តែអាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំជាមួយគ្នាបានឡើយ។[43]ក្នុងនោះអភិបាលដំបូងត្រូវកាន់តំណែងចាប់ពីការបរិច្ឆេទនៃការបង្កើត ក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកទី ១។[44]

### ២.១.១.២. សិទ្ធិ និង តួនាទីរបស់អភិបាល

ច្បាប់បានកំណត់ថា អភិបាល អាចធ្វើសកម្មភាពបានតាមរយៈការទាក់ទងគ្នាជាលិខិត លើកលែងតែលក្ខន្តិកៈក្រុមហ៊ុនចែងផ្សេងពីនេះ។[45] ស្របពេលដែលប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញអភិបាលដើម្បីប្រជុំបាន អភិបាលក៏មានសិទ្ធិកោះប្រជុំក្រុមប្រឹក្សាភិបាលបានដូចគ្នាផងដែរ ដូចដែលច្បាប់បានកំណត់ថា ក្រោយពីចេញវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ស្ថាបនិកម្នាក់ ឬ អភិបាលម្នាក់ អាចកោះប្រជុំក្រុមប្រឹក្សាភិបាលបាន ដោយផ្តល់ការជូនដំណឹងយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃ តាមរយៈលិខិតទៅគ្រប់អភិបាល ដោយលិខិតជូនដំណឹងនោះមានបញ្ជាក់ ពីពេលវេលា និង ទីកន្លែងប្រជុំផង។[46]

ក្រៅពីសិទ្ធិក្នុងការកោះប្រជុំក្រុមប្រឹក្សាភិបាលហើយ ច្បាប់បានផ្តល់សិទ្ធិក្នុងការបោះឆ្នោត ឲ្យអភិបាលទៀតផង។ ប៉ុន្តែអភិបាលម្នាក់ ត្រូវមានសំលេងឆ្នោតតែមួយតែប៉ុណ្ណោះ។

[40] មាត្រា ១១៨ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[41] មាត្រា ១២៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[42] មាត្រា ១២១ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[43] មាត្រា ១២២ ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[44] មាត្រា ១១៦ វាក្យខណ្ឌ៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[45] មាត្រា ១៣០ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[46] មាត្រា ១១៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

លើសពីនេះទៅទៀត អភិបាល ក៏មានសិទ្ធិធ្វើជាអាណត្តិគាហកៈឲ្យអភិបាលមួយរូបផ្សេងទៀតបានផងដែរ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាដោយអភិបាលដែលខ្លួនធ្វើតំណាងឲ្យ។[47]

បន្ថែមពីនេះទៅទៀត អភិបាលនៅមានសិទ្ធិទទួលបានការសងការចំណាយ ដែលខ្លួនបានចំណាយទៀតផង។ ច្បាប់បានកំណត់យ៉ាងច្បាស់ថា ក្រុមហ៊ុនអាចចេញសងការចំណាយដល់អភិបាលបច្ចុប្បន្ន ឬអភិបាលពីមុន អ្នកគ្រប់គ្រង ឬ បុគ្គលិករបស់ក្រុមហ៊ុនក្នុងការបំពេញភារកិច្ច ដែលបានអនុវត្តដោយស្មោះត្រង់ និងសមហេតុសមផល ដោយការចេញសងត្រូវធ្វើឡើងនៅពេលដែលអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិក បានសំអាងក្នុងឆន្ទៈល្អនៅលើកំណត់ហេតុ ឬ សៀវភៅបញ្ជី ដែលមានភាពត្រឹមត្រូវរបស់ក្រុមហ៊ុន ឬនៅលើព័ត៌មានមតិយោបល់ របាយការណ៍ ផ្សេងៗ ឬរបាយការណ៍ដែលបង្ហាញដោយអ្នកគ្រប់គ្រងណាម្នាក់របស់ក្រុមហ៊ុននោះ ឬជនណាម្នាក់ផ្សេងអំពីបុគ្គលទាំងនោះ។ ប៉ុន្តែច្បាប់បានកម្រិតថា ការចេញសងត្រូវបានអនុវត្តចំពោះតែការចំណាយ ឬការខូតខាតសមហេតុសមផលដែលទទួលរងដោយអភិបាល អ្នកគ្រប់គ្រង ឬបុគ្គលិកនៅពេលបម្រើការងារឲ្យក្រុមហ៊ុនតែប៉ុណ្ណោះ។[48]

ស្របពេលដែលទទួលបានសិទ្ធិតាមច្បាប់ អភិបាលក៏មានតួនាទីដែលត្រូវបំពេញដែរ។ អភិបាលមានតួនាទីបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ។[49] លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អាចមានចែងឲ្យអភិបាលធ្វើការគ្រប់គ្រង ការិយាល័យណាមួយរបស់ក្រុមហ៊ុន នឹងតួនាទីផ្សេងៗទៀតផងដែរ។[50]

### ២.១.១.៣ ប្រាក់បៀវត្ស និង ប្រាក់លាភការ

អភិបាល មានសិទ្ធិនឹងទទួលបានប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដូចដែលច្បាប់បានកំណត់។[51] ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់អភិបាលទាំងឡាយនឹងត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ។ លើសពីនេះទៅទៀត អភិបាលក៏ទទួលបាននូវ ប្រាក់ លាភការបន្ថែមផងដែរ។

[47] មាត្រា ១៣២ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[48] មាត្រា ១៣៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[49] មាត្រា ២២៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[50] មាត្រា ១៣៨ ចំណុច គ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[51] មាត្រា ១១៩ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

### ២.១.១.៤. ការទទួលខុសត្រូវរបស់អភិបាល

អភិបាលដែលបោះឆ្នោតឲ្យ ឬយល់ព្រមក្នុងការធ្វើសេចក្ដីសម្រេចលើការអនុញ្ញាតឲ្យចេញ ប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូលដែលមិនមែនជាសាច់ប្រាក់ទេ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះក្រុមហ៊ុនទៅតាមចំនួនតម្លៃសមមូលដែលបានទទួលដែលតិចជាងតម្លៃត្រឹមត្រូវ ជាសាច់ប្រាក់ដែលក្រុមហ៊ុនបានទទួល ប្រសិនបើប័ណ្ណភាគហ៊ុនដែលបានបោះចេញ នោះសម្រាប់លក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្ដីសម្រេច។ ប៉ុន្តែអភិបាល មិនទទួលខុសត្រូវទេប្រសិនបើអភិបាលនោះបង្ហាញថាមិនបានដឹងថាភាគហ៊ុនដែលបោះចេញសម្រាប់តម្លៃសម មូលដែលតិចជាងសាច់ប្រាក់ដែលក្រុមហ៊ុនអាចនឹងទទួល ប្រសិនបើប័ណ្ណភាគហ៊ុននោះ ដែលបាន បោះចេញសម្រាប់លក់យកជាប្រាក់។[52] អ្វីដែលគួរឲ្យកត់សម្គាល់គឺថាសកម្មភាពក្នុងការអនុវត្តនូវការទទួលខុសត្រូវបំណុល ដែលតម្រូវដោយច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មចំពោះចំណុចនេះមិនអាចចាប់ផ្ដើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំបានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្ដីសម្រេចរបស់អភិបាលនោះ។

អភិបាលដែលបានបោះឆ្នោតឲ្យ ឬ យល់ព្រមចំពោះសេចក្ដីសម្រេចដែលអនុញ្ញាតឲ្យមាន ការទិញមកវិញនូវភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានលក់កន្លងមក ឬ ធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬធ្វើការបែងចែកភាគលាភ ដែលផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់ដែលបានកំណត់ជាដើមត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នា នូវរាល់ចំនួនដែលបានបែងចែក ឬបានបង់ហើយដើម្បីស្ដារក្រុមហ៊ុនឡើងវិញ។[53] ដូចគ្នានឹងចំនុចខាងលើដែរ សកម្មភាពក្នុងការអនុវត្តនូវការទទួលខុសត្រូវដែលតម្រូវដោយចំណុចនេះ មិនអាចចាប់ផ្ដើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំបានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្ដីសម្រេចរបស់អភិបាលនោះ។

ដើម្បីឲ្យមានភាពងាយស្រួលក្នុងការកំណត់ ថាតើអភិបាលណាខ្លះយល់ព្រម ហើយណាខ្លះ មិនយល់ព្រមចំពោះសេចក្ដីសម្រេចដែលបានអនុម័តនោះ ក៏ដូចជាកំណត់ថាតើអភិបាលណាខ្លះ ត្រូវទទួលខុសត្រូវចំពោះបញ្ហាដែលបានកើតឡើង ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម បានកំណត់ថា អភិបាលម្នាក់ដែលមានវត្តមាននៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលត្រូវចាត់ទុកថាបានយល់ព្រមនូវរាល់សេចក្ដីសម្រេចដែលបានអនុម័ត ឬសកម្មភាពដែលបានធ្វើឡើងនៅក្នុង មហាសន្និបាតលើកលែងតែ ៖[54]

- អភិបាលនោះមានការជំទាស់ ដែលស្នើដាក់ចូលក្នុងកំណត់ហេតុអង្គប្រជុំនៃមហាសន្និបាតនោះ។

[52] មាត្រា ១៤០ ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[53] មាត្រា ១៤១ ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[54] មាត្រា ១៤២ ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

- អភិបាលនោះផ្ញើគំនិតជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅលេខាធិការរបស់មហាសន្និបាតមុនពេលបិទមហាសន្និបាតនោះ។

ម្យ៉ាងទៀត អភិបាលដែលអវត្តមាននៅក្នុងមហាសន្និបាត នៅពេលសេចក្តីសម្រេចដែលត្រូវអនុម័ត ឬសកម្មភាពដែលបានធ្វើឡើងរួចមកហើយ គឺចាត់ទុកថាបានយល់ព្រមលើកលែងតែ ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពីបានដឹងសេចក្តីសម្រេចនោះអភិបាលនោះបាន ៖

- បង្ហាញមូលហេតុនៃការជំទាស់របស់គាត់ ដែលបានបញ្ចូលទៅក្នុងកំណត់ហេតុនៃ មហាសន្និបាត។
- ផ្ញើគំនិតជំទាស់របស់ខ្លួនតាមរយៈលិខិតអនុសិទ្ធិឬយកទៅប្រគល់ផ្ទាល់នៅឯការិយាល័យរបស់ក្រុមហ៊ុន។

ជារួមមក អភិបាលរបស់ក្រុមហ៊ុន ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាទៅតាមការខូចខាតដែលបានកើតឡើងចំពោះក្រុមហ៊ុន ដែលការទទួលខុសត្រូវនេះអាចមានទាំងការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីនិង ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

ការទទួលខុសត្រូវទាំងអស់នោះ មានដូចជា ៖[55]

- ការទទួលខុសត្រូវរដ្ឋប្បវេណី
    - រំលោភបំពានលើលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។
    - កំហុសក្នុងការគ្រប់គ្រងក្រុមហ៊ុនជាដើម។
- ការទទួលខុសត្រូវព្រហ្មទណ្ឌ
    - បទឆបោក (ចំពោះទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន)
    - បទរំលោភលើទំនុកចិត្ត និង បទល្មើសព្រហ្មទណ្ឌផ្សេងៗទៀតជាអាទិ៍។

### ២.១.១.៥. ការដកហូត និង ការបញ្ចប់តំណែងអភិបាល

ចំពោះការដកហូតចេញពីមុខតំណែងវិញ អភិបាលអាចត្រូវដកហូតចេញពីមុខតំណែង បានដោយសម្លេងឆ្នោតភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ។[56] ក្រៅពីនេះ ច្បាប់បានកំណត់ទៀតថា អភិបាល អាចលាលែងពីមុខតំណែងនៅពេលណាក៏បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន។ ការលាលែងពីមុខតំណែងនេះ ត្រូវមានសុពលភាពភ្លាម ឬមាន

---

[55] គង់ សាផន នីតិពាណិជ្ជកម្ម (ភ្នំពេញ ២០១២) ទំព័រ២៨៧-២៨៨

[56] មាត្រា ១២៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ប្រសិទ្ធិភាព ចាប់ពីពេលដែលបានចែងនៅក្នុង លិខិតជូនដំណឹងនោះ។ ក្នុងករណីដែលមានអភិបាលតែម្នាក់ ដែលជាអភិបាលនៅសល់ចុងក្រោយក្នុងក្រុមហ៊ុន ហើយអភិបាលនោះបានធ្វើការលាលែងមុនពេលអភិបាល ផ្សេងត្រូវបានតែងតាំង អភិបាលនោះត្រូវទទួលខុសត្រូវ ចំពោះការខូតខាតដែលបានបង្កឡើងដល់ក្រុមហ៊ុន ដោយសារការលាលែងរបស់ខ្លួន។[57]

បន្ទាប់ពីអាណត្តិរបស់ខ្លួនបានផុតកំណត់ អភិបាលត្រូវបន្តបម្រើការងាររបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងជំនួសជាថ្មី។[58]

ក្រៅពីនេះ គេសង្កេតឃើញថាតួនាទីជាអភិបាលក៏ត្រូវបញ្ចប់ផងដែរ ប្រសិនបើអភិបាលបានទទួលមរណៈភាពហើយ ឬ ទទួលរងការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌជាដើម។

### ២.១.២. ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលគឺជាបណ្តុំនៃអភិបាលដែលធ្វើសេចក្តីសម្រេចចិត្ត អំពីការគ្រប់គ្រងក្រុមហ៊ុន។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដោយអនុលោមតាមច្បាប់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។រូបវន្តបុគ្គលដែលមានសមត្ថភាពមានអាយុលើសពី១៨ឆ្នាំអាចបម្រើជាអភិបាល ឬជាអ្នកគ្រប់គ្រងក្រុមហ៊ុនបាន។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវមានក្រុមប្រឹក្សាភិបាលដែលជ្រើសតាំងដោយម្ចាស់ភាគហ៊ុន។ ក្រុមប្រឹក្សាភិបាលនេះ មានភារកិច្ចទទួលខុសត្រូវទាំងស្រុង នូវរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន។ ក្រុមហ៊ុននេះត្រូវមានមន្ត្រីដែលតែងតាំងដោយក្រុមប្រឹក្សាភិបាល និងដែលទទួលបន្ទុកលើប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ដោយអនុវត្តអំណាចដែលត្រូវបានប្រគល់ជូនដោយក្រុមប្រឹក្សាភិបាល។

#### ២.១.២.១.ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាល

បុគ្គលដែលអាចធ្វើជាអភិបាលគឺ រាល់រូបវន្តបុគ្គលដែលមានសកម្មភាពតាមច្បាប់ និងមានអាយុចាប់ពី ១៨ឆ្នាំឡើង អាចបម្រើការជាអភិបាល ឬមន្ត្រីក្រុមហ៊ុន។ អភិបាល ឬមន្ត្រីមិនចាំបាច់ជាម្ចាស់ភាគហ៊ុន ឬក៏មានលក្ខណៈសម្បត្តិដទៃទៀតទេលើកលែងលក្ខន្តិកៈក្រុមហ៊ុនតម្រូវឱ្យ អ្នកទាំងនោះមានលក្ខណៈសម្បត្តិជាក់លាក់។

[57] មាត្រា ១២៥ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[58] មាត្រា ១២៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ចំនួន និងអាណត្តិរបស់អភិបាល ត្រូវចែងនៅក្នុងលក្ខន្តិកៈ។ ក្នុងករណីមិនមានចែងក្នុងលក្ខន្តិកៈត្រូវមានចំនួន៣រូប។ ក្នុងករណីមិនមានចែងក្នុងលក្ខន្តិកៈ អភិបាលត្រូវបោះឆ្នោត សម្រាប់អាណត្តិរយៈពេល ២ឆ្នាំ។ អាណត្តិរបស់អភិបាលត្រូវកំណត់ជាដំណាក់ៗ និងមិនត្រូវបញ្ចប់ក្នុងឆ្នាំជាមួយគ្នាទេ។

### ២.១.២.២. សមាសភាពក្រុមប្រឹក្សាភិបាល

នៅក្នុងក្រុមហ៊ុន សមាសភាពរបស់ក្រុមប្រឹក្សាភិបាលមាន អភិបាលមួយចំនួនដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងប្រធានមួយរូបដែលជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនហើយក្រុមប្រឹក្សាភិបាលនេះ ត្រូវដឹកនាំដោយបុគ្គលទៅតាមឋានានុក្រម និងតាមតួនាទី។

ក្រុមប្រឹក្សាភិបាលរបស់សហគ្រាសបោះផ្សាយត្រូវមានសមាជិកមិនលើសពី ០៧ (ប្រាំពីរ) រូបឡើយ ដោយអនុលោមទៅតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសាធារណៈ។ ក្រុមប្រឹក្សាភិបាល ត្រូវមានអភិបាលឯករាជ្យយ៉ាងតិចចំនួន ០១ (មួយ) រូប និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនយ៉ាងតិចចំនួន ០១ (មួយ) រូប។[59]

### ២.១.២.៣.គណៈកម្មការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល អាចត្រូវបានបង្កើតឡើងដោយ លក្ខន្តិកៈក្រុមហ៊ុន បទបញ្ជាផ្ទៃក្នុង ឬដោយសម្លេងភាគច្រើន នៃក្រុមប្រឹក្សាទាំងមូលតាមរយៈដំណោះស្រាយជាលាយលក្ខណ៍អក្សរ។ គណៈកម្មាធិការនីមួយៗ អាចមានសមាជិកជាអភិបាលម្នាក់ ឬច្រើនដែលត្រូវតែងតាំងដោយសម្លេងភាគច្រើននៃក្រុមប្រឹក្សាភិបាលទាំងមូល។ សន្និបាតរបស់គណៈកម្មាធិការត្រូវអនុវត្តតាមបែបបទដូចគ្នានឹងមហាសន្និបាតរបស់ក្រុមប្រឹក្សាភិបាលគណៈកម្មាធិការនីមួយៗ ត្រូវមានអំណាចដែលផ្តល់ឱ្យដោយឯកសារជាលាយលក្ខណ៍អក្សរដែលបង្កើតគណៈកម្មាធិការ។

### ២.១.២.៤. សិទ្ធិ និងអំណាចរបស់ប្រឹក្សាភិបាល

អំណាចរបស់ក្រុមប្រឹក្សាភិបាល មានដូចជា៖ តែងតាំង ដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងអស់កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗសម្រាប់អភិបាលទាំងឡាយហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បី សុំសេចក្តីសម្រេច។ ចេញប័ណ្ណកំណត់សន្យាសញ្ញាប័ណ្ណ និងលិខិតស្នាមដែលបញ្ជាក់ថា មានបំណុលនិងតឹកតាំងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់លក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ លិខិត

[59] ប្រការ១១ ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

ស្នាមទាំងឡាយនោះ។ ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងហ៊ុន និងបុគ្គលផ្សេងស្នើសុំម្ចាស់ហ៊ុនដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ ឬមួយភាគស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន។ ប្រកាសភាគលាភទៅតាមគោលការណ៍គណនី និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុនប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ។ ចេញប័ណ្ណភាគហ៊ុនទៅតាមវិសាលភាព ដែលបានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ ថ្មីប្រាក់បោះចេញបោះចេញសាជាថ្មី ឬលក់មូលបត្ររបស់ក្រុមហ៊ុន។ ចុះកិច្ចសន្យាធានាក្នុងនាមក្រុមហ៊ុន។ ធ្វើអ្វីប៉ុតែកចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន។ រៀបចំការបិទបញ្ជីគណនីនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើ ចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន។

ភារកិច្ចរបស់អភិបាល៖ ក្រុមប្រឹក្សាភិបាលត្រូវចាត់ចែងដឹកនាំ និងទទួលខុសត្រូវចំពោះក្រុមហ៊ុន និងគ្រប់កិច្ចការរបស់ក្រុមហ៊ុន។ អភិបាលទាំងអស់ត្រូវតែស្មោះត្រង់ចំពោះក្រុមហ៊ុន និងធ្វើការងារដើម្បីជាផលប្រយោជន៍ក្រុមហ៊ុន។ អំណាចនៃក្រុមប្រឹក្សាភិបាលអនុវត្តអំណាចនៅក្នុងការចាត់ចែង និងដឹកនាំរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ។

### **២.១.២.៥. ប្រាក់បៀវត្ស និងប្រាក់លាភការ**

បើនិយាយពីប្រាក់បៀវត្ស និងប្រាក់លាភ អភិបាលមានសិទ្ធិនឹងទទួលបានប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ ដូចដែលច្បាប់បានកំណត់។ [60] ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់អភិបាលទាំងឡាយ នឹងត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ។ លើសពីនេះទៅទៀត អភិបាលក៏ទទួលបាននូវប្រាក់លាភការបន្ថែមផងដែរ។

### **២.១.២.៦. ការបញ្ចប់តួនាទីរបស់ក្រុមប្រឹក្សាភិបាល**

មនុស្សយើងកើតមកមិនមានជីវិតជារៀងរហូតទេ ពោលក្រុមប្រឹក្សាភិបាលក៏ដូចគ្នាផងដែល គឺមិនអាចមានជីវិតជារៀងរហូតនោះទេ តែងតែមានការបញ្ចប់ជីវិតទៅវិញជាធម្មតា។ ការបញ្ចប់ជីវិត ឬតួនាទីរបស់ក្រុមប្រឹក្សាភិបាលនោះមានមូលហេតុជាច្រើនដូចជាការមកដល់នូវពេលវេលាដែលបានកំណត់ការលាលែងរបស់ក្រុមប្រឹក្សាភិបាលការដកហូត និងតាមករណីផ្សេងៗទៀតមួយចំនួនផងដែរ។

---

[60] មាត្រា ១១៩ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

### ក. ការដល់អាណត្តិ

អភិបាល ត្រូវបានកំណត់ពេលវេលាមួយយ៉ាងច្បាស់លាស់នៅក្នុងការបំពេញតួនាទី។ រយៈពេលនៃការកំណត់នោះបានមកដល់ហើយ អភិបាលត្រូវបានបញ្ចប់តួនាទីរបស់ខ្លួនជាដាច់ខាត ដោយខានមិនបានឡើយ លើកលែងតែមានការជ្រើសតាំងជាថ្មី។ ប៉ុន្តែអភិបាលចាស់នោះអាចបន្តបម្រើការងារ ឬបំពេញតួនាទីរបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងអភិបាលថ្មីមកជំនួសខ្លួន[61]។ ការកំណត់អាណត្តិរបស់អភិបាលទាំងឡាយមិន អាចបញ្ចប់នៅក្នុងឆ្នាំជាមួយគ្នាបានឡើយ[62]។

### ខ. ការសុំលាលែងរបស់ក្រុមប្រឹក្សាភិបាល

ការសុំលាលែងពីមុខតំណែងរបស់អភិបាលទាំងឡាយនៅពេលណាក៏បាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុនជាការស្រេច។ ការសុំលាលែងពីមុខតំណែងនេះ ត្រូវមានសុពលភាពភ្លាម ឬមានប្រសិទ្ធភាពចាប់ពីពេលដែលបានចែងយ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹងនោះ។ អភិបាលម្នាក់ដែលនៅសល់ចុងក្រោយគេនៃក្រុមហ៊ុន ហើយអភិបាលនោះធ្វើការសុំលាលែងពីមុខតំណែងមុនពេលអភិបាលផ្សេងទៀតត្រូវបានតែងតាំងអភិបាលនោះត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងដល់ក្រុមហ៊ុន ដោយសារតែការលាលែងរបស់ខ្លួននោះ[63]។ ប៉ុន្តែការសុំលាលែងក៏អាចធ្វើឡើងបានដែរ ដោយមានការបង្ខិតបង្ខំនៅក្នុងករណីអភិបាលគាត់ធ្លាក់ទៅក្នុងស្ថានភាពអសមត្ថភាពដូចជាមានជម្ងឺធ្ងន់ធ្ងរចាស់ជរានិងមានវិសមិតភាពចំពោះការងារ។

### គ. ការដកហូតមុខតំណែង

អភិបាល ត្រូវបានដកហូតចេញពីមុខតំណែងបាន ដោយសម្លេងភាគច្រើនដាច់ខាតរបស់ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះបីជាមានមូលហេតុ ឬគ្មានមូលហេតុក៏ដោយ[64]។ ការដកហូតពីមុខតំណែងនេះ បើធ្វើឡើងប្រកបដោយហេតុផលទុច្ចរិត ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់អភិបាល ជាទូទៅអភិបាលរូបនោះគាត់អាចធ្វើការប្តឹងទាមទារសំណងជំងឺចិត្ត ប៉ុន្តែតំណែងជាអភិបាលនោះគាត់មិនអាចទទួលបានមកវិញឡើយ។ ដូចក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតACLEDA Bank Plc. ចែងថា៖ "**មានតែម្ចាស់ភាគហ៊ុនដែលបានជ្រើសរើស ឬតែងតាំងសមាជិកក្រុមប្រឹក្សាទេ ដែលអាចដក**

[61] មាត្រា ១២៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[62] មាត្រា ១២២ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[63] មាត្រា ១២៥ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[64] មាត្រា ១២៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

**សមាជិកក្រុមហ៊ុនបាន**“។ ការដកតំណែងនេះ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលា ដោយគ្រាន់តែមានការជូនដំណឹងសមស្របដល់ប្រធានក្រុមប្រឹក្សាភិបាលប៉ុណ្ណោះ[65]។

នៅក្នុងករណីដែលមានការដកហូតពីមុខតំណែង មុនពេលបញ្ចប់អាណត្តិធម្មតារបស់អភិបាលសមាជិកនៃក្រុមប្រឹក្សាភិបាល ត្រូវមានការតែងតាំងអភិបាលថ្មីមួយរូបដើម្បីឱ្យបម្រើការងារជំនួស អតីតសមាជិកនៃក្រុមប្រឹក្សាភិបាលនៃកន្លែងដែលនៅទំនេរ មិនទាន់មកដល់អាណត្តិកំណត់នោះ។

## ២.១.២.៧. ការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមួយ ត្រូវដឹកនាំដោយប្រធានមួយរូប។ ប្រធានក្រុមប្រឹក្សាភិបាលនោះត្រូវបានបោះឆ្នោតជ្រើសតាំងចេញពីសមាជិកនៃក្រុមប្រឹក្សាភិបាល ហើយនៅក្នុងច្បាប់មិនឃើញមានការកំណត់អាណត្តិរបស់ប្រធានក្រុមប្រឹក្សាភិបាលឡើយ ប៉ុន្តែការតែងតាំងមិនអាចឱ្យលើសពីអាណត្តិរបស់អភិបាលដែរ និងអាចមានការចាំបាច់លក្ខន្តិកៈអាចចែងឱ្យលើសពីនេះក៏បាន ហើយរូបវន្តបុគ្គលនោះអាចត្រូវបានជ្រើសតាំងជាប្រធានក្រុមប្រឹក្សាភិបាលសាជាថ្មីបានទៀតផង។ ប្រធានក្រុមប្រឹក្សាភិបាល អាចត្រូវដកហូតចេញពីមុខតំណែងដោយសម្លេងភាគច្រើនដាច់ខាតរបស់អភិបាលទាំងឡាយ ប៉ុន្តែមិនត្រូវបានដកហូតចេញពីឋានៈជាអភិបាលឡើយ[66] ។

## ២.១.២.៨. អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលដោយមហាសន្និបាត

អង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវប្រព្រឹត្តទៅដោយមានការជូនដំណឹងនូវកាលបរិច្ឆេទទីកន្លែងប្រជុំ និងកូរ៉ុមយ៉ាងច្បាស់លាស់ដល់អភិបាលទាំងឡាយ។ ដោយអនុលោមតាមច្បាប់ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំយ៉ាងហោចណាស់មួយដងក្នុង១ត្រីមាស។ ក្រុមប្រឹក្សាភិបាលអាចអនុម័ត សេចក្តីសម្រេចដោយផ្អែកលើការបោះឆ្នោតសម្លេងភាគច្រើនរបស់សមាជិក ឬតំណាងដែលមានវត្តមាន។

## ក. សេចក្តីជូនដំណឹងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល

សេចក្តីជូនដំណឹងអង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវតែ ធ្វើជាលាយលក្ខណ៍អក្សរដើម្បីជូនដំណឹងទៅឱ្យសមាជិកក្រុមប្រឹក្សាទាំងអស់ឱ្យមកចូលរួម។ លិខិតជូនដំណឹងត្រូវចុះកាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈពិស្តារផងដែរ។

---

[65] ឧបសម្ព័ន្ធទី១ ប្រការ៣៩ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ACLEDA BANK PLC.

[66] មាត្រា ១២៧ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

**ខ. របៀបវារៈ**

របៀបវារៈ គឺជាការលើកឡើងនូវកម្មវត្ថុរបស់ក្រុមហ៊ុនជាកិច្ចពិភាក្សានៅក្នុងអង្គប្រជុំអំពីសំណួរ ដែលត្រូវចោទសួរ និងពីគោលបំណងកម្មវត្ថុនោះ។ របៀបវារៈត្រូវធ្វើនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ។ របៀបវារៈនេះត្រូវដាក់ចេញដោយក្រុមហ៊ុនផ្ទាល់ទៅលើអាជីវកម្មរបស់ខ្លួន ប៉ុន្តែក្នុងករណីខ្លះទៀត វាជាកិច្ចស្នើសុំឱ្យដោះស្រាយ ឬបញ្ហាផ្សេងៗទៀតរបស់សមាជិកណាម្នាក់ដែលយល់ថាជាកិច្ចការសំខាន់ពាក់ព័ន្ធនឹងអាជីវកម្មក្រុមហ៊ុន។ របៀបវារៈនេះ ត្រូវមានបញ្ជាក់ច្បាស់លាស់នៅរាល់កិច្ចប្រជុំម្តងៗរបស់ក្រុមហ៊ុននៅក្នុងលិខិតអញ្ជើញ ឬលិខិតជូនដំណឹងរួម។

**គ. ទីកន្លែងប្រជុំ**

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ។ ក្រុមប្រឹក្សាភិបាល អាចជួបប្រជុំនៅកន្លែងណាមួយទៅតាមលិខិតជូនដំណឹង។ ដូចនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ACLEDA Bank Plc. បានចែងថា "កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវរៀបចំឡើងនៅការិយាល័យកណ្តាលនៃក្រុមហ៊ុនដែលបានចុះបញ្ជីដូចដែលបានកំណត់បញ្ជាក់នៅខាងលើ ឬនៅទីកន្លែងណាមួយផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលបានសម្រេច[67]។

**ឃ. កូរ៉ុម**

ដើម្បីធានានូវការប្រជុំនេះឱ្យមានសុក្រឹតភាព និងសេចក្តីសម្រេចនៃអង្គប្រជុំមានអានុភាពនោះ ទាមទារឱ្យមានការចូលរួមសម្លេងពីសមាជិកតាមចំនួនកំណត់មួយ។ ចំនួនភាគច្រើននៃអភិបាលទាំងអស់ ដែលមានវត្តមាននៅពេលប្រជុំបង្កើតបានកូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល។ ប៉ុន្តែលក្ខន្តិកៈ អាចតម្រូវឱ្យមានចំនួនច្រើនជាងនេះបាន។

**២.១.២.៩.អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងអង្គប្រជុំវិសាមញ្ញ**

សមាជិកក្រុមប្រឹក្សាភិបាលមួយរូបៗ មានសម្លេងឆ្នោតមួយសម្លេង[68]។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលធ្វើដោយអនុលោមទៅតាមលក្ខន្តិកៈ ត្រូវមានសម្លេងឆ្នោតគាំទ្រយ៉ាងហោចណាស់៥១ភាគរយ នៃក្រុមប្រឹក្សាភិបាលចូលរួមរាល់អង្គប្រជុំដែលមានកូរ៉ុមគ្រប់ចំនួន លើកលែងតែការសម្រេចដែលទាងទងទៅនឹង

---

[67] ឧបសម្ព័ន្ធទី១ ប្រការ១៦ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ACLEDA BANK PLC.

[68] មាត្រា ១៣២ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ករណីដូចខាងក្រោមនេះ ដែលតម្រូវការសម្លេងឆ្នោតគាំទ្រ យ៉ាងហោចណាស់ ២/៣ នៃសមាជិកក្រុមប្រឹក្សាភិបាលដែលកំពុងបម្រើការៈ

- ការកែប្រែប្រការ ឬខទាំងឡាយនៃលក្ខន្តិកៈ
- ការអនុម័តលើថវិកាប្រចាំឆ្នាំ ឬការផ្លាស់ប្ដូរថវិកាប្រចាំឆ្នាំ ដែលមានអគ្គនាយកដាក់ជូន នៅក្នុងនោះរាប់បញ្ចូលទាំងថវិកា ដែលបានចំណាយលើមូលធន។
- ការចំណាយលើមូលធនលើសពីថវិកា ដែលត្រូវបានអនុម័តពីដំបូងរួចមកហើយសម្រាប់ សារពើពន្ធនោះ។
- ការតែងតាំង ឬ ដកហូតអគ្គនាយកក្រុមហ៊ុន។
- ការធ្វើប្រតិវេទន៍ ឬការទូទាត់ភាគលាភឬការបែងចែកទ្រព្យសកម្មផ្សេងៗទៅឱ្យម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន។
- ការរំលាយដោយស្ម័គ្រចិត្ត ឬ ជម្រះបញ្ជីក្រុមហ៊ុន
- ការអនុម័តលើការទូទាត់ភាគលាភរបស់ក្រុមហ៊ុន ត្រូវធ្វើទៅតាមគោលការណ៍ទាក់ទិននឹង ការធ្វើប្រតិវេទន៍ និងការទូទាត់ភាគលាភរបស់ក្រុមហ៊ុន។
- ការទិញភាគហ៊ុនវិញ។

### គ. សេចក្ដីសម្រេច និងកំណត់ហេតុ

រាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែបង្ហាញឱ្យឃើញច្បាស់លាស់ ដោយការកត់ត្រាសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយកំណត់ហេតុនៃអង្គប្រជុំ ដែលសេចក្ដីសម្រេចបានធ្វើឡើងកំណត់ហេតុនោះ និងត្រូវបានឱ្យសច្ចានុម័តដោយអង្គប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល។ ការបោះឆ្នោតនៅរៀងរាល់ឆ្នាំ អង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយការលើកដៃ ឬដោយវិធីផ្សេងៗទៀត ដែលស្ថិតនៅក្រោមអធិបតីភាពរបស់ក្រុមប្រឹក្សាជាសម្រេច។[69]

[69] ឧបសម្ព័ន្ធទី១ ប្រការ ៣៥ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ACLEDA BANK PLC.

### ខ. ការសម្រេចឯកច្ឆ័ន្ទជាលាយលក្ខណ៍អក្សរ

សមាជិកក្រុមប្រឹក្សាភិបាល អាចធ្វើសកម្មភាពនៅចន្លោះកិច្ចប្រជុំក្រុមប្រឹក្សាភិបាល តាមរយៈសេចក្ដីសម្រេចជាឯកច្ឆ័ន្ទដែលមានហត្ថលេខា ដោយសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើបញ្ហាទាំងអស់នោះ[70]។

### ២.១.២.១០. ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

អភិបាល ជាអ្នកដឹកនាំក្រុមហ៊ុន ហេតុនេះអភិបាលត្រូវទទួលខុសត្រូវចំពោះកំហុសខ្លួនដែលបានប្រព្រឹត្តទោះបីដោយចេតនាក្ដី ឬដោយអចេតនាក្ដី។

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវចំពោះភាពជោគជ័យរយៈពេលវែងរបស់សហគ្រាសបោះផ្សាយ ព្រមទាំងចីរភាពនៃប្រៀបប្រកួតប្រជែង ដោយធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងការទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួន ហើយត្រូវធ្វើសកម្មភាពណាដែលបម្រើនូវផលប្រយោជន៍ ទាំងស្រុងរបស់សហគ្រាសបោះផ្សាយ និងភាគហ៊ុនិក។ ក្រុមប្រឹក្សាភិបាលត្រូវធានាថា អភិបាលទទួលការបណ្ដុះបណ្ដាល ដើម្បីធ្វើបច្ចុប្បន្នកម្មអំពីការវិវត្ត នៃអភិបាលកិច្ចសាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលមានផលប៉ះពាល់ដល់ដំណើរការធុរកិច្ចសហគ្រាសបោះផ្សាយ។ [71]

### ក. ការទទួលខុសត្រូវរដ្ឋប្បវេណី

- កំហុសដឹកនាំក្រុមហ៊ុន។
- រំលោភលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។
- ការប្រព្រឹត្តល្មើសមិនយល់ដឹង មិនអនុវត្តតាមបទបញ្ជានិងច្បាប់ដែលបាននៅជាធរមាន។

### ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

ត្រូវផ្ដន្ទាទោសដាក់គុកពី មួយឆ្នាំ ទៅប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល ទៅដប់លានរៀលចំពោះ ៖

- អភិបាលដែលគ្មានបញ្ជីសារពើភណ្ឌ ឬដោយលើបញ្ជីសារពើភណ្ឌក្លែងបន្លំ បានធ្វើការបែងចែកនូវប្រាក់ចំណេញដោយប្រឌិត។

[70] ឧបសម្ព័ន្ធទី១ ប្រការ ៣៦ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ACLEDA Bank Plc.

[71] ប្រការ១៨ ប្រកាសស្ដីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

- សមាជិកទាំងឡាយណាដែលបានដឹងជាមុន ហើយទទួលប្រាក់ចំណេញដោយប្រឌិត។ បន្ថែមពីលើទណ្ឌកម្មនេះ សមាជិកនោះត្រូវបង្វិលសងប្រាក់មកក្រុមហ៊ុនវិញ។

### គ. ការធានាសំណង

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចចេញសងការខូចខាតដល់អភិបាល ដែលកើតឡើងក្នុងការអនុវត្តការងាររបស់ខ្លួនកាលណាបុគ្គលនោះបានចាត់វិធានការដោយសមហេតុផល និងដោយបំណងល្អ។ សំណងខូចខាតត្រូវទូទាត់ ចំពោះរាល់ការចំណាយសមហេតុផល ឬការខូចខាតដែលកើតឡើងដោយសារបណ្តឹងផ្លូវច្បាប់ ឬរដ្ឋបាលប្រឆាំងនឹងអភិបាល ដែលបណ្តឹងនោះកើតឡើងពីការបំពេញមុខងារជាអភិបាលនៃក្រុមហ៊ុន។

ប្រសិនបើបានកំណត់ នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនធ្វើការធានាសំណងជំនួសឱ្យសមាជិកក្រុមប្រឹក្សាភិបាលណា ដែលបានខិតខំប្រឹងប្រែងចាត់ចែងបំពេញសកម្មភាពជូនក្រុមហ៊ុនដោយក្តីស្មោះត្រង់។ ក្រុមហ៊ុនត្រូវធ្វើការធានាចំណាយសេវាមេធាវី និងប្រាក់ពិន័យដែលត្រូវបង់ ក្នុងការដោះស្រាយដែលសមាជិកក្រុមប្រឹក្សាភិបាលរូបនោះ ដែលជាប់ពាក់ព័ន្ធជាមួយនឹងកំហុសផ្លូវច្បាប់។

### ឃ. គណៈកម្មាធិការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗបានតាមការចាំបាច់ដើម្បីសម្រួលដល់ការងាររបស់ក្រុមហ៊ុន។ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល អាចត្រូវបង្កើតឡើងដោយសេចក្តីសម្រេច ជាលាយលក្ខណ៍អក្សរនៃសម្លេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការរបស់ក្រុមហ៊ុននីមួយៗ ត្រូវមានអភិបាលមួយរូប ឬ ច្រើនរូបដែលត្រូវតែងតាំងដោយសម្លេងភាគច្រើនដាច់ខាត របស់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការ ត្រូវអនុវត្តកិច្ចការប្រជុំរបស់ខ្លួនតាមវិធីដូចគ្នានឹងក្រុមប្រឹក្សាភិបាលដែរ។

គណៈកម្មាធិការនីមួយៗ ត្រូវមានសិទ្ធិដែលបាន ផ្តល់ឱ្យដោយឯកសារជាលាយលក្ខណ៍អក្សរ ដែលបានបង្កើតគណៈកម្មាធិការនោះ។ ប៉ុន្តែគណៈកម្មាធិការមួយមិនអាចត្រូវ បានគេផ្ទេរអំណាចណាមួយ ដើម្បីធ្វើសកម្មភាពដូចតទៅនេះទេ៖

- ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន។
- ស្នើសុំទៅម្ចាស់ហ៊ុនធ្វើកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬ ការរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលណាមួយផ្សេង។

- ស្នើសុំទៅម្ចាស់ហ៊ុនធ្វើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមួយភាគ ឬ ទាំងអស់។
- ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន។
- ប្រកាសភាគលាភ។
- បោះចេញនូវប័ណ្ណភាគហ៊ុននៅក្នុងក្រុមហ៊ុន[72]។

### ២.១.៣. សិទ្ធិរបស់ម្ចាស់ហ៊ុន

ម្ចាស់ហ៊ុនប្រើអំណាចរបស់ខ្លួនតាមរយៈមហាសន្និបាតម្ចាស់ហ៊ុន ។ ម្ចាស់ហ៊ុនជាអង្គមានឋានៈធំជាងគេ នៅក្នុងអភិបាលកិច្ចក្រុមហ៊ុន ។ សិទ្ធិរបស់ម្ចាស់ហ៊ុនមានដូចជា៖

- ចូលរួមមហាសន្និបាត
- មានសិទ្ធិទទួលបាននូវភាគលាភ
- ចូលរួមបោះឆ្នោតជ្រើសរើសអភិបាល ឬ ដកអភិបាល
- អាចលក់ភាគហ៊ុនបានដោយសេរី លើកលែងតែមានចែងក្នុងលក្ខន្តិកៈ
- មានការទទួលខុសត្រូវមានកម្រិត
- មានសិទ្ធិឲ្យបុគ្គលផ្សេងធ្វើតំណាងដើម្បីបោះឆ្នោត
- អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- អាចប្ដឹងបដិសេធសេចក្ដីសម្រេច ក្នុងកិច្ចប្រជុំដែលខ្លួនមិនបានទទួលដំណឹងឲ្យចូលរួម។

### ២.១.៤. មហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន

មហាសន្និបាតម្ចាស់ហ៊ុនត្រូវធ្វើឡើងនៅកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាដែលចែងក្នុងលក្ខនិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។ មហាសន្និតបាតម្ចាស់ហ៊ុនអាចធ្វើឡើងនៅក្រៅព្រះរាជាណាច្រកម្ពុជា ប្រសិនមានការយល់ព្រមពីម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់។[73]

មហាសន្និបាតម្ចាស់ហ៊ុនអាចប្រព្រឹត្តឡើងតាមរយៈ ៖

- ➢ សិទ្ធិកោះហៅដោយប្រធានក្រុមប្រឹក្សាភិបាល

[72] មាត្រា ១៣១ ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[73] មាត្រា ២០៥ ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

- សិទ្ធិកោះហៅដោយសំណើ១/៣ នៃចំនួនអភិបាលក្នុងដំណែង
- កោះហៅដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អភិបាលម្នាក់ៗក្នុងរយៈពេលយ៉ាងហោច ២០ថ្ងៃមុនការប្រគល់សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសន្និបាតនៃក្រុមប្រឹក្សាភិបាល នេះគឺជាការទទួលខុសត្រូវរបស់លេខាធិការ
- មធ្យោបាយជូនដំណឹងធ្វើឡើងតាម ទូសារ ឬជាលិខិតអនុសិទ្ធិ
- គ្រប់អភិបាលត្រូវផ្ដល់លេខទូរស័ព្ទ និងអាសយដ្ឋានបច្ចុប្បន្នរបស់ខ្លួនជូនក្រុមហ៊ុន
- ក្នុងការធ្វើដំណឹងជាលាយលក្ខណ៍អក្សរនីមួយៗ លេខាធិការត្រូវរក្សាទុកក្នុងឯកសារជាភស្តុតាង ទោះបីជាបង្កាន់ដៃប្រៃសណីយ៍ ឬការប្រកាសមានកសិណសាក្សីនៃនិរសារ ឬពេលវេលា និងកាលបរិច្ឆេទដែលមានក្នុងលិខិតជូនដំណឹង
- លិខិតជូនដំណឹងពីការប្រជុំមហាសន្និបាតក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែងនៃមហាសន្និតបារនោះ ឱ្យបានពិស្ដារត្រឹមត្រូវ។

នៅក្នុងករណីមិនគោរពតាមបញ្ញត្តិក្នុងវាក្យខណ្ឌខាងលើនេះ នឹងបណ្ដាលឱ្យមហាសន្និបាតត្រូវចាត់ទុកជាមោឃៈលើកលែងតែអភិបាលទាំងអស់លះបង់ចោលការជំទាស់របស់ខ្លួនជា ឯកច្ឆ័នលើវិការៈក្នុងសេចក្ដីជូនដំណឹងនេះ។

### ២.១.៤.១. មហាសន្និបាតវិសាមញ្ញនៃម្ចាស់ភាគហ៊ុន

មហាសន្និបាតវិសាមញ្ញ គឺជាកិច្ចប្រជុំបន្ទាន់មួយដែលត្រូវបានកោះហៅ ឬប្រព្រឹត្តឡើង ដើម្បីដោះស្រាយបញ្ហារបស់ក្រុមហ៊ុន ក្នុងភាពបន្ទាន់ ឬភាពអាសន្ន។

កិច្ចប្រជុំមហាសន្និបាតវិសាមញ្ញនេះ ច្រើនតែសម្រេចទៅលើការកែប្រែក្រុមហ៊ុនមានដូចជា ការកែប្រែលក្ខន្តិកៈ ការបន្ថែម ឬបន្ថយដើមទុនក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជីក្រុមហ៊ុនជាដើម ហើយការសម្រេចរបស់មហាសន្និបាតវិសាមញ្ញ ត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើនដាច់ខាត ២/៣ ដែលបានចូលរួមក្នុងការបោះឆ្នោតលើសេចក្ដីសម្រេចនោះ ។

### ២.១.៤.២. មហាសន្និបាតប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន

មហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន ត្រូវធ្វើឡើងយ៉ាងហោចណាស់ក្នុងមួយឆ្នាំម្ដង។ មហាសន្និបាតលើកទីមួយរបស់ម្ចាស់ភាគហ៊ុនត្រូវធ្វើឡើងក្នុងអំឡុងពេលមួយឆ្នាំក្រោយពីបានចេញលក់ភាគហ៊ុនក្នុងហ៊ុនដំបូង។

ប្រសិនបើក្រុមហ៊ុនមិនបានកំណត់ពេល មហាសន្និបាតប្រចាំឆ្នាំណាមួយ នៅក្នុងរយៈពេលមួយឆ្នាំ ឬក្រោយពីមហាសន្និបាតប្រចាំឆ្នាំចុងក្រោយ អភិបាលម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រសួងពាណិជ្ជកម្ម អាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច ឱ្យកោះប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុន។

កិច្ចប្រជុំនៃមហាសន្និបាតដែលរៀបចំការប្រព្រឹត្តទៅតាមការស្នើសុំនេះ តុលាការអាចកំណត់កូរ៉ុមផ្សេងពីកូរ៉ុមដែលមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ប្រសិនបើតុលាការយល់ឃើញថាជាការចាំបាច់។[74]

### ២.១.៤.៣. ការដឹកនាំសន្និបាតរបស់ម្ចាស់ភាគហ៊ុន

អគ្គនាយកនៃក្រុមហ៊ុន ត្រូវធ្វើជាអធិបតីគ្រប់គ្រងសន្និបាតរបស់ម្ចាស់ភាគហ៊ុន។ នៅក្នុងសន្និបាតរបស់ម្ចាស់ភាគហ៊ុនក្រុមប្រឹក្សាភិបាល និងសវនករគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបង្ហាញរបាយការណ៍ប្រចាំឆ្នាំដល់ម្ចាស់ភាគហ៊ុន ដើម្បីធ្វើការសម្រេចយល់ព្រម ឬមិនយល់ព្រម។

### ២.១.៤.៤. សេចក្តីសម្រេចដោយម្ចាស់ហ៊ុនក្នុងអង្គប្រជុំពិសេស

សេចក្តីសម្រេចដែលចាត់ទុកជា សេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន គឺជាសេចក្តីសម្រេចដែលម្ចាស់ហ៊ុនបានធ្វើឡើងជា លាយលក្ខណ៍អក្សរដោយបានចុះហត្ថលេខាដោយម្ចាស់ហ៊ុនទាំងអស់ ដែលមានសិទ្ធិបោះឆ្នោតសេចក្តីសម្រេចនេះមានសុពលភាព ដូចគ្នានឹងសេចក្តីសម្រេចដែលបានអនុម័តនៅមហាសន្និបាតម្ចាស់ហ៊ុនដែរ។ ឯកសារជាសេចក្តីសម្រេចត្រូវរក្សាទុកដោយមានភ្ជាប់ជាមួយកំណត់ហេតុមហាសន្និបាតម្ចាស់ហ៊ុន។[75]

### ២.១.៤.៥. ការទទួលភាគលាភតាមគោលនយោបាយទូទៅនៃភាគលាភ

ភាគលាភគឺជាការទូទាត់ដោយក្រុមហ៊ុនទៅ ឲ្យម្ចាស់ហ៊ុនដោយផ្អែកតាមសមាមាត្រនៃប្រាក់ចំណេញ។ ការទូទាត់ភាគលាភអាច ត្រូវធ្វើឡើងជាសាច់ប្រាក់ ទ្រព្យសម្បត្តិ បំណុល ឬ**សន្និធិក្រុមហ៊ុន**។ យ៉ាងណាមិញមានវិធីផ្សេងទៀតដែលម្ចាស់ហ៊ុនទទួលបានប្រយោជន៍តាមរយៈភាគលាភដែលបានបង់លើភាគហ៊ុនរបស់ពួកគេ។ អភិបាលក្រុមហ៊ុនអាចប្រកាសចេញនូវភាគលាភសល់ ឬប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុនដោយអនុលោមតាមលក្ខន្តិកៈក្រុមហ៊ុន ហើយក្រុមហ៊ុនមានទ្រព្យសម្បត្តិគ្រប់គ្រាន់។ អភិបាលអាចចាត់ចែងប្រាក់បម្រុងមួយភាគ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តកិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន ដោយប្រើប្រាស់នូវមូលនិធិណាមួយរបស់ក្រុមហ៊ុនដែលមានសម្រាប់បែងចែកភាគលាភ។

[74] មាត្រា ២០៨ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[75] មាត្រា ២២១ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

គ្រប់ក្រុមហ៊ុនមូលធនទាំងអស់ បោះចេញនូវភាគហ៊ុនចុះបញ្ជី ឬសន្និធិ[76] ទៅឲ្យក្រុមហ៊ុនរបស់ខ្លួន។ ទិញភាគហ៊ុនពីអ្នកផ្សេង ឬទទួលភាគហ៊ុនជាអំណោយ។ ម្ចាស់ហ៊ុនអាចទិញភាគហ៊ុនតាមឋានានុក្រមនៃការទាមទារលើទ្រព្យសម្បត្តិពាណិជ្ជកម្ម។ ប៉ុន្តែម្ចាស់ហ៊ុនត្រូវ បានទទួលនូវសំណងលំដាប់ក្រោយគេបំផុត ពីព្រោះដោយសារភាពជាម្ចាស់នៅក្នុងក្រុមហ៊ុន។ ផ្ទុយទៅវិញម្ចាស់ហ៊ុននឹងទទួលបានចំណូលខ្ពស់ ប្រសិនបើអាជីវកម្ម ទទួលបានជោគជ័យ។ម្យ៉ាងទៀតម្ចាស់ហ៊ុននឹងទទួលបានអត្ថប្រយោជន៍នៅពេល ដែលតម្លៃភាគហ៊ុនរបស់គេកើនឡើង។

ប្រសិនបើលក្ខន្តិកៈ ក្រុមហ៊ុនមិនមានចែងអំពីភាគលាភនោះទេ ក្រុមប្រឹក្សាភិបាលត្រូវសម្រេចលើពេលវេលាបែងចែកភាគលាភ និងកំណត់ចំនួនភាគលាភតាមថ្នាក់ហ៊ុន។ ក្រុមប្រឹក្សាភិបាល មិនត្រូវធ្វើការបែងចែកភាគលាភទេ ប្រសិនបើការបែងចែកភាគលាភចែកនេះបណ្តាលឱ្យដើមទុន ចុះបញ្ជីថយចុះ ឬប៉ះពាល់ដល់ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។ អភិបាលមួយ ដែលបានបោះឆ្នោតគាំទ្រការបែងចែកភាគលាភដោយរំលោភបំពានត្រូវទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នាចំពោះការសងវិញ ផ្នែកខុសច្បាប់ទាំងមូលនៃភាគលាភ។

សេចក្តីសម្រេចអំពីការបែងចែកភាគលាភ ត្រូវមានកំណត់ជាក់លាក់នៅក្នុងលក្ខន្តិកៈអំពីកាលបរិច្ឆេទដែលត្រូវ មកបើកយកភាគលាភនេះ "**កាលបរិច្ឆេទផ្លូវការ**"។ រយៈពេលបើកភាគលាភនេះត្រូវកំណត់ក្នុងរយៈជាក់លាក់តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

សិទ្ធិទទួលភាគលាភសំដៅដល់បុគ្គលដែលត្រូវបង្ហាញថាជាម្ចាស់ភាគហ៊ុន និងមានឈ្មោះនៅក្នុងបញ្ជីភាគហ៊ុននៃក្រុមហ៊ុនប៉ុណ្ណោះ។ ក្រោយរយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃកំណត់ឱ្យមកបើកភាគលាភនោះ ម្ចាស់ភាគលាភណាដែលមិនបានមកបើកយកភាគលាភរបស់ខ្លួនចាត់ទុកថាជាការបោះបង់សិទ្ធិហើយ ចំណែកភាគលាគនេះត្រូវបង្វិលបញ្ចូលទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុនវិញ។

### ២.១.៤.៦. ការធ្វើវិសោធនកម្មលើលក្ខន្តិកៈរបស់ក្រុមហ៊ុន

វិសោធនកម្មគឺជាការផ្លាស់ប្តូរ ឬបន្ថែមបន្ថយលក្ខខណ្ឌនៃកិច្ចសន្យា ឬបទបញ្ញាណាមួយឲ្យស្របតាមតម្រូវការអនុវត្តជាក់ស្តែងនៃបច្ចុប្បន្នភាព។

ក្រុមហ៊ុនមូលធន អាចធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលា តាមសេចក្តីសម្រេចពិសេស។ កាលណាក្រុមហ៊ុនមិនទាន់បានចេញលក់ភាគហ៊ុននៅឡើយទេស្ថាបនិកក្រុមហ៊ុនអាចធ្វើវិសោធនកម្មផ្លាស់ប្តូរ

[76] ទ្រព្យ ឬប្រាក់សន្សំ

លក្ខន្តិកៈ ឬបន្ថែមបន្ថយលក្ខខណ្ឌនៃកិច្ចសន្យា បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនជាដើម ឬប្រសិនបើបានជ្រើសតាំងអភិបាលដំបូងហើយ ការធ្វើវិសោធនកម្មនេះ អាចធ្វើដោយសម្លេងភាគច្រើននៃអភិបាលដំបូងនោះ។ ប្រសិនបើមានការចេញលក់ភាគហ៊ុនរួចហើយ ការធ្វើវិសោធនកម្មរបស់ក្រុមហ៊ុនអាចត្រូវធ្វើ សម្លេងភាគច្រើននៃថ្នាក់ហ៊ុននីមួយៗ ដែលមានសិទ្ធិបោះឆ្នោត និងការបោះឆ្នោតនេះ ត្រូវធ្វើឡើងដោយឡែកតាមថ្នាក់ ទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលកែប្រែដោយផ្ទាល់ ឬ ដោយប្រយោល ឬ ប៉ះពាល់ទៅនឹង សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹង ប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ [77]។ លក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អាចចែងកំណត់ចំនួនសម្លេងឆ្នោតខុសពីនេះបាន។ សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីសន្និបាតដើម្បីធ្វើវិសោធនកម្មលក្ខន្តិកៈឬ បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនត្រូវផ្តល់ជូនទៅម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតលើវិសោធនកម្មនេះ យ៉ាងតិច ២០ ថ្ងៃ មុនថ្ងៃសន្និបាតនេះ[78]។

### ២.១.៥. ការផ្សព្វផ្សាយជាសាធារណៈ

ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពីបំណងរំលាយជាទម្រង់លម្អិតទៅឱ្យក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលសេចក្តីប្រកាសពីបំណងរំលាយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុនពេលនោះក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួនចាប់ពីថ្ងៃដែលបានលុបឈ្មោះចេញពីបញ្ជីក្រុមហ៊ុន។

#### ២.១.៥.១. វិញ្ញាបនបត្រ

វិញ្ញាបនបត្រ ត្រូវធ្វើឡើងដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងនៅក្រសួងពាណិជ្ជកម្ម បន្ទាប់ពីទទួលបានការយល់ព្រមលើសេចក្តីសម្រេចនេះ។ នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជី ឬរំលាយនៃក្រុមហ៊ុនបុគ្គលភាពរបស់ក្រុមហ៊ុននឹងមានសុពលភាពនៅពេលដែលក្រសួងពាណិជ្ជកម្ម ចេញវិញ្ញាបនបត្របញ្ជាក់ ពីការចុះបញ្ជី ឬការរំលាយជាស្ថាពរ។

#### ២.១.៥.២.សិទ្ធិ និងភាតព្វកិច្ចរបស់ក្រុមហ៊ុន

ក្រោយពីការយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោយពីបានទទួលសាហ៊ុយនៃការតម្កល់នោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញជាលិខិតបញ្ជាក់មួយជាសម្គាល់។

[77] កថាខណ្ឌទី២ មាត្រា ២៣៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[78] មាត្រា ២៣៧ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

បន្ទាប់ពីការចុះបញ្ជី ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ មានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ។ ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចបានទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនអាចធ្វើពាណិជ្ជកិច្ចក្រៅប្រទេសបាន លុះត្រាច្បាប់ប្រទេសនោះផ្តល់ការអនុញ្ញាត។

ទោះបីទទួលបាននីតិបុគ្គលិកលក្ខណៈបែបនេះក្តី ក្រុមហ៊ុនមិនត្រូវប្រកបពាណិជ្ជកិច្ចណាមួយ ឬអនុវត្តសិទ្ធិណាមួយផ្ទុយពីលក្ខន្តិកៈរបស់ខ្លួនឡើយ។

## ២.២.ការរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និងកំណត់ហេតុ

ជាទូទៅគ្រប់ក្រុមហ៊ុនមូលធន ត្រូវរៀបចំឲ្យមាននូវលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងព្រមទាំងធ្វើការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន និងប្រកាសផ្សាយជាសាធារណៈចំពោះការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រសួងពាណិជ្ជកម្ម។

### ២.២.១.លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

លក្ខន្តិកៈក្រុមហ៊ុន ( Article of incorporation ) គឺជាសំណុំឯកសារផ្លូវការដែលជាអត្ថបទចងក្រងឡើងជាឯកសារស្របច្បាប់ស្តីពីដំណើរការបង្កើតសាជីវកម្មដែលបានដាក់តម្កល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

ចំពោះខ្លឹមសារនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ ត្រូវចែងកំណត់ឲ្យបានច្បាស់លាស់ ជាពិសេសត្រូវតែអនុលោមទៅតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលមានត្រូវកំណត់នូវចំណុចដូចតទៅនេះ ៖[79]

ក. នាមករណ៍របស់ក្រុមហ៊ុន។

ខ. ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គ. កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះធ្វើ ពាណិជ្ជកិច្ច។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬ ច្រើនប្រភេទដែលមិន ផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់។

ឃ. ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ។

[79] មាត្រា ៩៣-៩៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ង. ចំណាត់ប្រភេទ និង ចំនួនអតិបរមានៃភាគហ៊ុន ព្រមទាំងតម្លៃចារឹកលើប័ណ្ណ ភាគហ៊ុន ដែលត្រូវបាន អនុញ្ញាតឲ្យបោះចេញដោយក្រុមហ៊ុននោះ។

ច. ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឲ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទហ៊ុននោះលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃចារឹក លើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ។

ឆ. ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាស៊េរី លក្ខន្តិកៈក្រុមហ៊ុននោះត្រូវអនុញ្ញាត ឲ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃស៊េរីនីមួយៗ ដើម្បីកំណត់ប្លង់បែងចែកស៊េរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិដែលរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងស៊េរីនីមួយៗនោះ។

ជ. ក្នុងករណីការបោះចេញ ការផ្ទេរ ឬការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធិភាព និងមានរបាយការណ៍ពីការកម្រិតនោះ។

ឈ. ឈ្មោះ និងអាស័យដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ។

ញ. ចំនួនអភិបាល និងចំនួនអប្បរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ។

លក្ខន្តិកៈក្រុមហ៊ុនត្រូវធ្វើឡើងតាមរូបភាពជាលិខិតឯកជន ឬលិខិតសាការី។ សមាជិកទាំងអស់របស់ក្រុមហ៊ុនត្រូវចុះហត្ថលេខាសង្ខេបគ្រប់ទំព័រនៃលក្ខន្តិកៈដើម្បីបញ្ជាក់ពីការឯកភាពទទួលយកលក្ខន្តិកៈនោះជាផ្លូវការ។

បទបញ្ជាផ្ទៃក្នុងគឺស្តីពីវិធានរួមក្នុងក្របខណ្ឌអង្គភាពសាជីវកម្ម ដែលមានកំណត់អំពីសកម្មភាពវិន័យ លក្ខខណ្ឌការងារ សិទ្ធិ និងកាតព្វកិច្ចរបស់កម្មករ រង្វាន់ ការឈប់សម្រាក សំណង សិទ្ធិការពារកម្មករ វិធានការសុខភាព និងសុវត្ថិភាពការងារ ។រួមសេចក្តីមកបទបញ្ជាផ្ទៃក្នុងមានគោលបំណង សម្រេចឲ្យបានគុណភាពការងារ ប្រសិទ្ធិភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

### **២.២.២. ទីស្នាក់ការចុះបញ្ជី**

ទីស្នាក់ការចុះបញ្ជី ឬអាស័យដ្ឋានអាជីវកម្ម (The principal business address ) គឺសំដៅដល់អាស័យដ្ឋានចុះបញ្ជីរបស់ក្រុមហ៊ុន និងជាទីតាំងជាក់ស្តែងដែលក្រុមហ៊ុនបោះទីតាំងធ្វើប្រតិបត្តិការអាជីវកម្មជាចម្បង

របស់ខ្លួន។ ទីស្នាក់ការចុះបញ្ជីនេះជាទីតាំងកណ្តាលរបស់ក្រុមហ៊ុនផ្លូវការសម្រាប់ការទទួលសំបុត្រ និងការជូនដំណឹងផ្លូវការពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ។

### ២.២.៣. កំណត់ហេតុ

កំណត់ហេតុសាជីវកម្ម ( Corporate Record )គឺសម្រង់ខ្លឹមសារដោយសង្ខេប ដោយមានបញ្ជាក់ពីប្រធានបទ តួសេចក្តី សន្និដ្ឋាន អនុសាសន៍ និងសំណូមពរ ហើយធ្វើការចងក្រង ជាឯកសារទុកជាសារព័ត៌មានអំពីប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុនដោយធានាបាននូវការអនុលោមតាមបញ្ញត្តិច្បាប់ និងលក្ខនិកៈ ដើម្បីជួយសម្រួលដល់ការធ្វើសេចក្តីសម្រេចចិត្តទទួលបានលទ្ធផលល្អ ប្រកបដោយគុណភាពខ្ពស់។

### ២.២.៤. របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ( Annual Fmancial Statement ) គឺសំដៅដល់តារាងតុល្យការមានបញ្ជីទ្រព្យសម្បត្តិ ឬបញ្ជីសារពើភណ្ឌ និងបំណុលរបស់ក្រុមហ៊ុន។

អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ។

របាយការណ៍ត្រូវមាន៖

- របាយការណ៍ហិរញ្ញវត្ថុដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និង ឆ្នាំសារពើពន្ធឆ្នាំមុន។ នៅក្នុងឆ្នាំដំបូងនៃអត្ថិភាពរបស់ក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុត្រូវចាប់ផ្តើមពិនិត្យពីពេលក្រុមហ៊ុនមានអត្ថិភាព បញ្ចប់នៅកាលបរិច្ឆេទមិនលើសពី៦ខែមុនមហាសន្និបាតប្រចាំឆ្នាំ។
- របាយការណ៍របស់សវនករ។
- ព័ត៌មានផ្សេងទៀតដែលធ្វើតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុនដែលតម្រូវដោយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន។

ម្ចាស់ហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួនអាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបានដោយមិនគិតថ្លៃ។[៨០]

[៨០] មាត្រា ២២៥ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ក្រុមហ៊ុនមិនអនុញ្ញាតឲ្យបោះផ្សាយ ឬធ្វើចរាចរឯកសារនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ។ ក្រុមហ៊ុនអាចធ្វើខាងលើបាន លុះត្រារបាយការណ៍ហិរញ្ញវត្ថុនោះមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និងអមដោយរបាយការណ៍សវនករផង[81] ។

### ២.២.៥. ថិរវេលាក្រុមហ៊ុន

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវបានកំណត់ថាមានដំណើរការនៅក្នុងអំឡុងពេល ៩៩ ឆ្នាំ និងអាចចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញបាន។ ប៉ុន្តែក្រុមហ៊ុនអាចនឹងត្រូវរំលាយមុនការកំណត់មកដល់ឬពន្យាតាមលក្ខខណ្ឌដែលបានគ្រោងទុកនៅក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។ ស្របពេលជាមួយគ្នានោះដែរ ថិរវេលានេះអាចត្រូវបានពន្យាពេលបន្ថែមទៀត ប្រសិនបើមានការសំរេចជាឯកច្ឆ័ន្ទពីសមាជិកហ៊ុនទាំងអស់។[82]

[81] កថាខណ្ឌទី២ មាត្រា ២២៦ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[82] គង់ សាផន, នីតិពាណិជ្ជកម្ម (ភ្នំពេញ, ២០១២), ទំព័រ២៧០

# ជំពូកទី៣

## ជំពូលទី៣៖ ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនអាចត្រូវបញ្ចប់សកម្មភាពប្រតិបត្តិការរបស់ខ្លួន ដូចបានកំណត់ក្នុងលក្ខន្តិកៈ ឬកង្វះសមត្ថភាពដោយការក្ស័យធនជាដើម។ ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយអាចរំលាយនៅពេលណាក៏បានតាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់។ ប្រសិនបើក្រុមហ៊ុនមានចេញ ប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះការរំលាយត្រូវធ្វើតាមរយៈសេចក្តីសម្រេចចិត្តពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននេះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ។

ការរំលាយក្រុមហ៊ុនប្រព្រឹត្តទៅតាមការស្នើសុំទៅកាន់ក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់ពីការរំលាយជាផ្លូវការមានន័យថាក្រុមហ៊ុនលែងស្ថិតនៅជានីតិបុគ្គលតទៅទៀត ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីក្រសួងពាណិជ្ជកម្ម [83]។

### ៣.១. ការរំលាយក្រុមហ៊ុន

ការរំលាយក្រុមហ៊ុន គឺជាការបញ្ចប់អត្ថិភាពរបស់ក្រុមហ៊ុនក្នុងនាមជានីតិបុគ្គល។[84] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានកំណត់ថា ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់។ ចំណែកឯក្រុមហ៊ុនដែលគ្មានទ្រព្យសម្បត្តិ និង គ្មានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេច ចិត្តពិសេស (សេចក្តីសម្រេចមួយដែលត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន ២/៣ ដែលបាន ចូលរួមក្នុងការបោះឆ្នោត ឬ ពីការចុះហត្ថលេខារបស់សមាជិកភាគហ៊ុនទាំងឡាយ ដែលមានសិទ្ធិ ក្នុងការបោះឆ្នោតធ្វើសេចក្តីសម្រេចនោះ)[85] របស់ម្ចាស់ហ៊ុន ឬ ប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណ ភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នក កាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬ គ្មានសិទ្ធិបោះឆ្នោតក៏ដោយ។[86] តាមរយៈនេះ ក្រុមហ៊ុនត្រូវបញ្ជូនសេចក្តីសម្រេចរំលាយក្រុមហ៊ុនទៅឲ្យមន្ត្រីទទួល បន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុម

[83]កថាខណ្ឌទី២ មាត្រា ២៥១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

[84]ក្រសួងពាណិជ្ជកម្ម, សៀវភៅណែនាំ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និង ការប្រកបអាជីវកម្មអនុលោមតាមច្បាប់១១២

[85]មាត្រា៨៨ វាក្យខណ្ឌ១០ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[86]មាត្រា២៥១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥

ហ៊ុននៃក្រសួងពាណិជ្ជកម្ម នឹងចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឲ្យ ដល់ក្រុមហ៊ុន ហើយជាលទ្ធផលក្រុមហ៊ុនត្រូវបានចាត់ទុកថាលែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុននោះ ។

បន្ទាប់ពីមានការយល់ព្រមលើសេចក្តីសម្រេចជម្រះបញ្ជី និងការរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពីបំណងរំលាយ ជាទម្រង់លម្អិតទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលបានសេចក្តីប្រកាសពីបំណងរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុននោះ។ នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ក្រុមហ៊ុន ត្រូវបញ្ឈប់ការធ្វើអាជីវកម្ម លើកលែងតែចំពោះការពន្យាចាំបាច់សម្រាប់ការជម្រះបញ្ជីតែប៉ុណ្ណោះ ប៉ុន្តែនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុននៅតែមានសុពលភាពរហូតដល់ក្រសួងពាណិជ្ជកម្មចេញ វិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ។[87]

ក្រោយពីពេលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួល បន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវ ៖[88]

ក. ផ្ញើលិខិតជូនដំណឹងស្តីពីបំណងរំលាយជាបន្ទាន់ទៅឲ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន។

ខ. ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់ សម្រាប់រយៈពេល ២ (ពីរ) សប្តាហ៍ជាប់ៗគ្នា នៅក្នុងសារពត៌មានដែលបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុន មានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬ បោះពុម្ពផ្សាយដទៃទៀត ដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។

ស្របពេលជាមួយគ្នានេះដែរ ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុនត្រូវ៖[89]

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឲ្យម្ចាស់ហ៊ុន
- បំពេញកាតព្វកិច្ចទាំងឡាយ
- ធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី។

[87] មាត្រា២៥៣ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥

[88] មាត្រា២៥៤ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[89] មាត្រា២៥៥ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬ ជាវត្ថុទៅឲ្យម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។

**ក.កិច្ចព្រមព្រៀងរំលាយចូលគ្នា**

កិច្ចព្រមព្រៀងរំលាយបញ្ចូលគ្នាត្រូវចែងពីៈ

1) ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

2) លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម។

3) បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឲ្យទៅជាភាគហ៊ុនមូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម។

4) របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិមូលបត្រ ឬកម្មសិទ្ធិផ្សេងសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុនបញ្ចូលគ្នាប្រសិនបើភាគហ៊ុនណាមួយ របស់ក្រុមហ៊ុនដើមមិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មីដែល ទទួលបន្ទុកបន្តអាជីវកម្មនោះទេ។

5) ព័ត៌មានមានដទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹង ដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

6) ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឲ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រងព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់ នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម។

**ខ. កិច្ចប្រជុំម្ចាស់ហ៊ុន**

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅម្ចាស់ក្រុមហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅៈ[៩០]

1) នៅក្នុងរយៈពេល៣០ ថ្ងៃក្រោយកិច្ចព្រមព្រៀងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

2) លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពី ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

[៩០] ខាន់ ធី, សៀវភៅ នីតិសហគ្រាសពាណិជ្ជកម្ម ទំព័រ ៨៦

3) ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច២០ថ្ងៃមុន។

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន២/៣នៃក្រុមហ៊ុនដើមនីមួយៗ។

## ៣.២. ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

ក្រុមហ៊ុនពីរ ឬច្រើនអាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួម ចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន។ ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើ អាជីវកម្មតទៅទៀតហៅថា ក្រុមហ៊ុនថ្មី។ ក្រុមហ៊ុនដើមត្រូវបាត់បង់នីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់[៩១]។

**កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :**

- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម។
- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឱ្យទៅជាភាគហ៊ុន ឬមូលបត្រផ្សេងៗ របស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម។
- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬកម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុន ត្រូវទទួលក្នុង ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ។
- ព័ត៌មានមានដទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹងដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

---

[៩១] មាត្រា ២៤២ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្ដល់ដល់ការគ្រប់គ្រងព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម។

**ក្រោយពីបានទទួលសេចក្ដីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវ ជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្ដីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ :**

- នៅក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗ ត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្ដល់លិខិតជូនដំណឹងស្ដីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០ម្ភៃ) ថ្ងៃមុន។

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្ដីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ។ ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុន ណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែក ក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌនៃប្រភេទ ឬស៊េរីនៃភាគហ៊ុនផ្សេងៗ។ អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងច្បាប់នេះមិនអាចបដិសេធ ឬកែប្រែដោយលក្ខន្តិកៈ របស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ។ **អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមាន ជាអាទិ៍ :**

- កិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា
- សេចក្ដីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីការរំលាយក្រុមហ៊ុន បញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និង នៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ
- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត
- សេចក្ដីប្រកាសរបស់អភិបាល ឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីខាងមន្ត្រី ទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម សេចក្ដីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :

ក្រុមហ៊ុនដើម និងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួនតាមពេលវេលាដែលត្រូវសងធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តមិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើមគ្មានម្ចាស់បំណុលណាមួយទទួលការខូចខាត ដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។ ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលមានចុះនៅ លើវិញ្ញាបនបត្រនេះ :

- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន
- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មី ដែលបន្តធ្វើអាជីវកម្ម
- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ
- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធ ដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមាន ជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម
- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈសម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្ម សម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្មក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នាម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើម មានសិទ្ធិទាមទារឱ្យមានការវាយតម្លៃលើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម។

ប៉ុន្តែដើម្បីទទួលបាន សិទ្ធិធ្វើការវាយតម្លៃម្ចាស់ហ៊ុនទាំងនោះត្រូវ បំពេញលក្ខខណ្ឌដូចតទៅ :

- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ
- នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នា
- ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។

នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុនក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុន ដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួលរកតម្លៃសមរម្យមួយក្នុង រយៈពេល ៩០(កៅសិប) ថ្ងៃ ដើម្បីឱ្យមានការព្រមព្រៀងលើតម្លៃសមរម្យមួយសម្រាប់ភាគហ៊ុនទាំងនោះ ។ តម្លៃសមរម្យត្រូវកំណត់តាមការពិនិត្យគ្រប់កត្តាដែលពាក់ព័ន្ធទាំងអស់ លើកលែងតែតម្លៃណាមួយដែលមានកំណត់រួចហើយនៅក្នុងកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា។ លក្ខន្តិកៈរបស់ក្រុមហ៊ុនដើមណាមួយ ឬកិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាអាចចែងថា គ្រប់វិវាទក្នុងការវាយតម្លៃ នឹងត្រូវសម្រេចដោយមជ្ឈត្តកម្ម។ មុននឹងមជ្ឈត្តករចេញសេចក្ដីសម្រេចចុងក្រោយ ម្ចាស់ហ៊ុនអាចដកបណ្ដឹងទាមទាររបស់ខ្លួន ក្នុងការវាយ តម្លៃនៅពេលណាមួយក៏បាន ។ ក្នុងករណីនេះ ម្ចាស់ហ៊ុននោះត្រូវមានសិទ្ធិទទួលពីក្រុមហ៊ុនថ្មី ដែលទទួលធ្វើ អាជីវកម្មបន្តនូវតម្លៃសមមូលដែលក្រុមហ៊ុនបានកំណត់ពីមុន។ ប្រសិនបើមិនអាចព្រមព្រៀងគ្នាលើតម្លៃសមរម្យណាមួយបានទេភាគីទាំងពីរត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចសម្រេចពីតម្លៃសមរម្យមួយបើម្ចាស់ហ៊ុនដែលទាមទារត្រូវទទួលទៅតាមចំនួននោះ។

### ៣.២.១. ការបញ្ចប់អត្ថិភាពក្រុមហ៊ុនដើម

ការបញ្ចប់អត្ថិភាពនៃក្រុមហ៊ុនដើម គឺជាការរំលាយនៃក្រុមហ៊ុនដើមក្នុងនាមជានីតិបុគ្គល។

### ៣.២.២. ការបង្កើតក្រុមហ៊ុនថ្មី

ការបង្កើតក្រុមហ៊ុនថ្មី ជាការចាប់ផ្ដើមនូវការបង្កើតក្រុមហ៊ុនក្នុងនាមជានីតិបុគ្គលសារជាថ្មីក្រោយពីបញ្ចប់ក្រុមហ៊ុនដើម។ ការបង្កើតក្រុមហ៊ុនថ្មីនេះ អាចកើតមានឡើងនៅពេលដែលក្រុមហ៊ុនដើមត្រូវបានបញ្ចប់អត្ថិភាពក្រោយពីចេញវិញ្ញាបនបត្រស្ដីពីការរំលាយ ពោលក្រុមហ៊ុនថ្មីកើតចេញពីការរួមបញ្ចូលគ្នានៃក្រុមហ៊ុន។

## ៣.៣.ការរំលាយ និង បញ្ចប់អត្ថិភាពក្រុមហ៊ុន

### ៣.៣.១.ការជ្រើសតាំងអ្នកជម្រះបញ្ជី

ការជ្រើសតាំងអ្នកជម្រះបញ្ជីជាការចាត់ចែងអ្នកជម្រះបញ្ជីម្នាក់ឬច្រើននាក់ជាសិទ្ធិរបស់មហាសន្និបាត។ នៅពេលជម្រះបញ្ជីចប់ ក្រុមហ៊ុនរៀបចំសេចក្ដីសម្រេចស្ដីពីការរំលាយក្រុមហ៊ុនផ្ញើទៅមន្ត្រី ទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ពេលនោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន ត្រូវចេញវិញ្ញាបនបត្របញ្ជីពីការរំលាយក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវបញ្ចប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃមានចុះក្នុងវិញ្ញាបនត្របញ្ជាក់ការរំលាយ។[92]

[92] អៀប សុធានី, នីតិក្រុមហ៊ុន, ទំព័រ១០៨

ការជម្រះបញ្ជីក្រុមហ៊ុន គឺជាការដោះស្រាយកិច្ចការហិរញ្ញវត្ថុរបស់អាជីវកម្ម ឬបុគ្គលដោយជាទូទៅធ្វើការបំលែងទៅជាសាច់ប្រាក់នូវរាល់ទ្រព្យសកម្មទាំងឡាយ ដើម្បីចែកចាយឲ្យទៅឥណទានយក(ម្ចាស់បំណុល)។[93] **ពាក្យ " ការជម្រះបញ្ជី "** នេះត្រូវបានបែងចែកចេញពីពាក្យ " **ការរំលាយ** "។ ដោយផ្អែកតាមការស្នើយោបល់របស់ក្រុមប្រឹក្សាភិបាល នៅពេលរំលាយក្រុមហ៊ុនមហាសន្និបាតវិសាមញ្ញនៃម្ចាស់ហ៊ុន ត្រូវកំណត់នូវវិធានការនៃការជម្រះបញ្ជីក្រុមហ៊ុន និង តែងតាំងអ្នកជម្រះបញ្ជីម្នាក់ ឬច្រើននាក់ ដោយកំណត់សិទ្ធិអំណាចឲ្យបានច្បាស់លាស់ លើកលែងតែការជម្រះបញ្ជីនោះត្រូវសម្រេចដោយតុលាការ។[94] ការជម្រះបញ្ជីក្រុមហ៊ុន គឺជានីតិវិធីមួយដែលត្រូវបានអនុវត្តព្រមៗគ្នាជាមួយនឹងការរំលាយក្រុមហ៊ុនដែរ ដែលការជម្រះបញ្ជីនេះអាចមានជាការជម្រះបញ្ជីដោយស្ម័គ្រចិត្ត និការជម្រះបញ្ជីតាមផ្លូវតុលាការ។

### ៣.៣.២.សិទ្ធិ និងភាតព្វកិច្ចអ្នកជម្រះបញ្ជី

អ្នកជម្រះបញ្ជី មានកាតព្វកិច្ចប្រមូលទ្រព្យទាំងអស់របស់ក្រុមហ៊ុន និងបម្លែងទ្រព្យទាំងនោះទៅជាសាច់ប្រាក់ (ដូចជាការលក់ទ្រព្យ) បន្ទាប់មកយកប្រាក់ទាំងនោះទៅសងបំណុលនៃម្ចាស់បំណុល បង់សោហ៊ុយជម្រះបញ្ជី យកសំណល់ពីការសង និងការចំណាយនេះទៅបែងចែកឱ្យម្ចាស់ហ៊ុនម្នាក់ៗ ទៅតាមសិទ្ធិបុព្វសិទ្ធិដែលភ្ជាប់នឹងភាគហ៊ុននីមួយៗ។ ក្រុមហ៊ុនត្រូវតែងតាំងអ្នកជម្រះបញ្ជី ដើម្បីចាត់ចែងកិច្ចការជម្រះបញ្ជីនេះ។ នៅក្នុងដំណាក់កាលនៃការជម្រះបញ្ជីនេះ បើម្ចាស់ហ៊ុនមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬអ្នកមានផលប្រយោជន៍ (ដូចជាម្ចាស់បំណុលជាដើម) មើលឃើញមានបញ្ហា ដែលត្រូវអន្តរាគមន៍ពីតុលាការ អ្នកទាំងនោះអាចប្តឹងទៅតុលាការ ដើម្បីសុំឱ្យតុលាការបញ្ជាឱ្យបើកការជម្រះបញ្ជីមួយដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ[95]។

#### ក. ការជម្រះបញ្ជីដោយស្ម័គ្រចិត្ត

ចំពោះអភិបាល ឬម្ចាស់ភាគហ៊ុនម្នាក់ ដែលមានសិទ្ធិបោះឆ្នោតនៅពេលមហាសន្និបាតម្ចាស់ហ៊ុន អាចស្នើឲ្យជម្រះបញ្ជី និងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តបាន។ លិខិតជូនដំណឹងស្តីពី ការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងគោលបំណងជម្រះបញ្ជី លក្ខខណ្ឌសម្រាប់ការជម្រះបញ្ជី ឬរំលាយក្រុមហ៊ុនដែលស្នើឡើងត្រូវចែងពី និងការរំលាយក្រុមហ៊ុននោះ។

[93] ក្រសួងពាណិជ្ជកម្ម, សៀវភៅណែនាំ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និង ការប្រកបអាជីវកម្មអនុលោមតាមច្បាប់១១៣

[94] គង់ សាផន, នីតិពាណិជ្ជកម្ម (ភ្នំពេញ, ២០១២), ទំព័រ២៩៥-២៩៦

[95] មាត្រា២៥៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ឧទាហរណ៍ ៖ នៅក្នុងមាត្រាទី ៥៤ នៃលក្ខន្តិកៈរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA Bank.PLC) បានកំណត់ថា ធនាគារ អាចត្រូវរំសាយហើយចំណូលពីការលក់ ( បន្ទាប់ ពីបានដោះបំណុលរបស់ធនាគាររួចរាល់ហើយ ភាគហ៊ុនដែលភាគទុនិកម្នាក់ៗមាននៅក្នុងស្តុក ) ត្រូវបែងចែកឲ្យភាគទុនិក តាមសមាមាត្រនៃចំនួន នៅពេលធ្វើការរំសាយធនាគារនោះដែលក្នុង នោះជាបឋមការរំសាយ ត្រូវបានស្នើឡើងដោយសម្លេងឆ្នោតគាំទ្រ ៧៥ ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សា ដែលកំពុងបម្រើការងារ។

### ខ. ការជម្រះបញ្ជីតាមផ្លូវតុលាការ

នៅគ្រប់ពេលក្នុងអំឡុងពេលនៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រង ក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬ ជនដែលមានការពាក់ព័ន្ធផលប្រយោជន៍អាចស្នើទៅតុលាការ ដើម្បីឲ្យការជម្រះបញ្ជីស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។ អ្នកដាក់ពាក្យសុំត្រូវផ្តល់ឲ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ ឬ តាមរយៈតំណាង។

ម្យ៉ាងទៀត តុលាការអាចធ្វើអន្តរាគមន៍នូវមូលហេតុមួយចំនួនដូចជា ៖

- ក្រុមហ៊ុនមិនមានសកម្មភាពក្នុងរយៈពេល១ឆ្នាំ ចាប់តាំងពីការបង្កើតមក
- ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពរបស់ខ្លួនជាង១ឆ្នាំមកហើយ
- ក្រុមហ៊ុនមានសមាជិកតិចជាង ៣ រូប។
- ការទទួលខុសត្រូវរបស់អ្នកជម្រះបញ្ជី

### គ.ការទទួលខុសត្រូវរបស់អ្នកជម្រះបញ្ជី

កំហុសមួយចំនួនអាចកើតមានឡើងក្នុងពេលជម្រះបញ្ជី ដែលតម្រូវឲ្យអ្នកជម្រះបញ្ជីទទួល ខុសត្រូវចំពោះកំហុសដែលបានកើតឡើង អ្វីដែលគួរឲ្យកត់សម្គាល់នៅក្នុងពេលថ្មីៗនេះ ខុសត្រូវកាន់តែច្រើនឡើងពីម្ចាស់បំណុល រយៈពេល ៣ ទាំងផ្នែករដ្ឋប្បវេណី និង ព្រហ្មទណ្ឌ និង(ករណីធ្ងន់ធ្ងរ)។ គឺថាមានបណ្តឹងចំពោះមុខអ្នកជម្រះបញ្ជីឲ្យទទួលពីសមាជិកហ៊ុន។ អាជ្ញាយុកាលនៃបណ្តឹងនេះមានរយៈគិតចាប់ពីពេលរកឃើញអំពើបង្កឲ្យមានការអន្តរាយ និង អាជ្ញាយុកាលពាណិជ្ជកម្មមានរយៈពេល ២ឆ្នាំ ដោយសងនូវការខូតខាត និងជម្ងឺចិត្ត។[96]

[96] គង់ សាផន, នីតិពាណិជ្ជកម្ម (ភ្នំពេញ, ២០១២), ទំព័រ២៩៧។ 150 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥៧។

### ឃ.លទ្ធផលនៃការជម្រះបញ្ជី

បន្ទាប់ពីការជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន ហើយសេចក្តីសម្រេចស្តីពីការរំលាយនេះ ត្រូវផ្ញើទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលបានសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុនពេលនោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុន។ ជាពិសេសនោះក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនឬ អាចនិយាយបានថាក្រុមហ៊ុនលែងមាននីតិបុគ្គលិក លក្ខណៈតទៅទៀតហើយពីធ្វើការជម្រះបញ្ជី ហើយក្រុមហ៊ុនត្រូវ ៖

- បង់សោហ៊ុយចំណាយផ្សេងៗ ដែលពាក់ព័ន្ធនឹងអភិបាលបណ្តោះអាសន្ន និងការជម្រះបញ្ជី តាមផ្លូវតុលាការ ឬ តាមការស្ម័គ្រចិត្ត។
- បង់ជូនរដ្ឋ នូវពន្ធ ឬ អាករ ដែលបានជំពាក់។
- បើកជូនបុគ្គលិកក្រុមហ៊ុន នូវប្រាក់បៀវត្សដែលបានជំពាក់។

### ៣.៣.៣.ការបញ្ចប់អត្ថិភាពក្រុមហ៊ុន

ការបញ្ចប់អត្ថិភាពក្រុមហ៊ុនគឺជាការមកដល់នៃពេលវេលាការបញ្ចប់ឬការបំពេញកម្មវត្ថុការអនុវត្តលក្ខិន្តិៈការចាត់ទុកជាមោឃៈនូវកិច្ចសន្យាក្រុមហ៊ុន ការរំលាយដោយស្ម័គ្រចិត្ត ដោយមហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន ការរំលាយតាមផ្លូវតុលាការ។ ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសអំពីបំណងរំលាយ ជាទម្រង់លំអិតទៅឱ្យក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលបានសេចក្តីប្រកាសអំពីបំណងរំលាយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួង ពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុន ពេលនោះក្រុមហ៊ុនត្រូវបញ្ចប់ការធ្វើអាជីវកម្ម ប៉ុន្តែនីតិបុគ្គលភាពរបស់ក្រុមហ៊ុននៅ តែមានសុពលភាព។[97]

### ក. អត្ថិភាព

ការបញ្ចប់ដោយការព្រមព្រៀង គឺជាការបញ្ចប់ដោយស្ម័គ្រចិត្ត។ ការព្រមព្រៀងរបស់ម្ចាស់ភាគហ៊ុន ឬ ក្រុមប្រឹក្សាភិបាល តាមប្រភេទក្រុមហ៊ុននីមួយៗ។

ការរំលាយក្រុមហ៊ុន ក្រសួងពាណិជ្ជកម្មតម្រូវឲ្យតំណាងក្រុមហ៊ុនបំពេញឯកសារមួយចំនួនមាន ៖[98]

[97] អៀប សុធានី, នីតិក្រុមហ៊ុន, ទំព័រ១០៨

[98] ខាត់ ធី, សៀវភៅនីតិសហគ្រាសពាណិជ្ជកម្ម ទំព័រ៨៨

| ឯកសារ | | |
|---|---|---|
| ០១ | ពាក្យសុំ គំរូ គ | ០៣ ច្បាប់(០២ច្បាប់ដើម០១ ច្បាប់ថតចម្លង) |
| ០២ | ប័ណ្ណជម្រះបញ្ជីសារពើពន្ធចេញដោយនាយកដ្ឋានពន្ធ ដារ | ០៣ ច្បាប់(០១ច្បាប់ដើម០២ ច្បាប់ថតចម្លង) |
| ០៣ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ ហ៊ុន ឬអភិបាលដែលចុះហត្ថលេខាឬស្នាមមេដៃដែលមក បង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខាលើ ពាក្យស្នើសុំ | ០៣ ច្បាប់ |
| ០៤ | រូបថតទំហំ (4 × 6)របស់ម្ចាស់ហ៊ុន ឬអភិបាលដែលមក បង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខាលើ ពាក្យស្នើសុំ | ០៣ សន្លឹក |
| ០៥ | លក្ខន្តិកៈក្រុមហ៊ុនចុះបញ្ជីបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម | ០៣ ច្បាប់ |
| ០៦ | អាជ្ញាប័ណ្ណអាជីវកម្មចេញដោយក្រសួងពាណិជ្ជកម្ម | ០១ ច្បាប់ដើម |
| ០៧ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចេញដើយក្រសួង ពាណិជ្ជកម្ម | ០១ ច្បាប់ដើម |
| ០៨ | លិខិតស្នើសុំពីក្រុមហ៊ុន | ០១ ច្បាប់ដើម |
| ០៩ | កំណត់ហេតុរំលាយក្រុមហ៊ុន(ក្រុមប្រឹក្សាភិបាល និងម្ចាស់ហ៊ុន) | ០១ ច្បាប់ដើម |
| ១០ | សេចក្តីសម្រេចរបស់ក្រុមហ៊ុនមេ (ប្រសិនបើពាក់ព័ន្ធ) | ០១ ច្បាប់ដើម |
| ១១ | កម្រៃសាហ៊ុយរដ្ឋបាល | កម្រៃសាហ៊ុយរដ្ឋបាល |

**ខ. ការព្រមព្រៀង**

ក្រុមហ៊ុនត្រូវបញ្ចប់សកម្មភាពរបស់ខ្លួនដោយសារគ្មានលទ្ធភាពបន្តអាជីវកម្ម។ តាមការព្រមព្រៀងជាឯកច្ឆ័នពីសំណាក់ម្ចាស់ហ៊ុន ដោយអាស្រ័យទៅតាមប្រភេទនៃក្រុមហ៊ុននីមួយៗ។

### គ. ការផ្ទេរផលប្រយោជន៍របស់ខ្លួន

នៅពេលម្ចាស់សហគ្រាសណាមួយមានបំណងចង់បញ្ចប់ ជាសមាជិកភាគហ៊ុន នោះត្រូវធ្វើការផ្តល់ពត៌មាន ទៅបណ្តាលសមាជិក ភាគហ៊ុនដទៃផ្សេងទៀតពីការផ្ទេរផលប្រយោជន៍ ព្រមទាំងទូទាត់លទ្ធផលក្រោយជម្រះបញ្ជី ដែលនៅសេសសល់ជាមួយបណ្តានៃសមានជិក ។

## ៣.៤.សមត្ថកិច្ចមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន

បន្ទាប់ពីមានការសម្រេចយល់ព្រមលើការរំលាយនេះហើយ ក្រុមហ៊ុនត្រូវធ្វើការប្រកាសស្តីពីបំណងនៃការរំលាយ ទៅឱ្យក្រសួងពាណិជ្ជកម្មដើម្បីធ្វើការអន្តរាគមន៍លើបញ្ហានេះ។ នៅពេលដែលក្រសួងពាណិជ្ជកម្មបាន ទទួលសេចក្តីប្រកាសស្តីពីការរំលាយមន្ត្រីទទួលបន្ទុកក្រុមហ៊ុននៃក្រសួងនេះត្រូវមានកាតព្វកិច្ចចេញវិញ្ញាបនបត្រពីបំណងនៃការរំលាយ ហើយក្រុមហ៊ុនត្រូវ ៖

១. ផ្ញើលិខិតជូនដំណឹងស្តីពីបំណងរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន ។

២. ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់ សម្រាប់រយៈពេល ២សប្តាហ៍ជាប់ៗគ្នា នៅក្នុងសារព័ត៌មានដែលបើកផ្សាយ ឬ ចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬ បោះពុម្ពផ្សាយដទៃទៀត ដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។[99]

### ៣.៤.១.សមត្ថកិច្ចមន្ត្រីទទួលបន្ទុកក្រុមហ៊ុន

វិញ្ញាបនបត្រស្តីពីការរំលាយនេះ ត្រូវធ្វើឡើងដោយក្រុមហ៊ុនខ្លួនឯងផ្ទាល់ បន្ទាប់ពីទទួលបានការយល់ព្រមលើសេចក្តីសម្រេចឱ្យមានការរំលាយ និងជម្រះបញ្ជី។ នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់បំណងនៃការរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវបញ្ឈប់ការធ្វើអាជីវកម្ម លើកលែងតែចំពោះការពន្យាចាំបាច់សម្រាប់ការជម្រះបញ្ជី ប៉ុន្តែនីតិបុគ្គលភាពរបស់ក្រុមហ៊ុននៅតែមានសុពលភាពរហូតដល់ក្រសួងពាណិជ្ជកម្ម ចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ[100]។

លក្ខន្តិកៈ និងផែនការរំលាយក្រុមហ៊ុន ដែលត្រូវធ្វើទៅឲ្យក្រសួងពាណិជ្ជកម្ម ត្រូវមានហត្ថលេខាដោយអភិបាលម្នាក់ ឬអ្នកគ្រប់គ្រងម្នាក់របស់ក្រុមហ៊ុន ឬដោយស្ថាបនិកម្នាក់ ក្នុងករណីដែលតម្រូវដោយលក្ខន្តិកៈ។

[99] មាត្រា២៥៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[100]មាត្រា ២៥៣ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

បន្ទាប់ពីបានទទួលឯកសារ ឬផែនការតាមទម្រង់កំណត់ ហើយនោះមន្រ្តីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនឹង ៖[101]

១. កត់ត្រាទុកកាលបរិច្ឆេទនៃការតម្កល់ទុក។

២. ចេញវិញ្ញាបនបត្រ។

៣. តម្កល់ទុកនូវវិញ្ញាបនបត្រ និង ឯកសារ ឬ សេចក្តីប្រកាស រូបថត ពត៌មានអេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រ និង ឯកសារ ឬ សេចក្តីប្រកាស។

៤. ផ្ញើរវិញ្ញាបនបត្រ និង ឯកសារ ឬសេចក្តីប្រកាស រូបថត ពត៌មានអេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញ នៃវិញ្ញាបនបត្រ និងឯកសារ ឬ សេចក្តីប្រកាសទៅឲ្យក្រុមហ៊ុន ឬតំណាងរបស់ក្រុមហ៊ុន។

៥. ចុះផ្សាយនូវលិខិតជូនដំណឹងនៃការចេញវិញ្ញាបនបត្រនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចត្រូវបានរំលាយដោយមូលហេតុផ្សេងទៀតដូចជា ៖[102]

- នៅមុនពេលចិរវេលាកំណត់បានមកដល់ តាមការសម្រេចរបស់មហាសន្និបាត វិសាមញ្ញនៃម្ចាស់ភាគហ៊ុន ដោយមានការស្នើយោបល់ពីក្រុមប្រឹក្សាភិបាល។
- នៅពេលចិរវេលាកំណត់បានមកដល់ តាមរយៈការប្រជុំមហាសន្និបាតវិសាមញ្ញ នៃម្ចាស់ហ៊ុននៅរយៈពេលយ៉ាងតិច ១ ឆ្នាំមុន ដើម្បីសម្រេចថាគួរតែបន្តសកម្មភាពរបស់ក្រុមហ៊ុន ឬ រំលាយក្រុមហ៊ុនតាមចិរវេលាដែលបានកំណត់ ដោយសម្លេងឆ្នោតជាឯកច្ឆ័ន្ទ។
- នៅពេលមានសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ឬ តុលាការទៅតាមមូលហេតុជាក់ស្តែង។
- ចំនួនសមាជិកហ៊ុនថយចុះតិចជាង ០៣ រូប។
- មូលធនរបស់ក្រុមហ៊ុនខាតបង់ជាងពាក់កណ្តាល។

[101] មាត្រា២៦៤ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[102] គង់ សាផន, នីតិពាណិជ្ជកម្ម ទំព័រ២៩៥

### ៣.៤.២.ការប្រកាសជាសាធារណៈចំពោះម្ចាស់បំណុល

បន្ទាប់ពីមានការសម្រេចយល់ព្រមលើការរំលាយនេះហើយ ក្រុមហ៊ុនត្រូវធ្វើការប្រកាសស្តីពី បំណងនៃការរំលាយ ទៅឱ្យក្រសួងពាណិជ្ជកម្មដើម្បីធ្វើការអន្តរាគមន៍ទៅលើបញ្ហានេះ។ នៅពេលដែលក្រសួងពាណិជ្ជកម្មបានទទួលសេចក្តីប្រកាសស្តីពីការរំលាយ មន្ត្រីទទួលបន្ទុកក្រុមហ៊ុននៃក្រសួងនេះ ត្រូវមានកាតព្វកិច្ចចេញវិញ្ញាបនបត្រពីបំណងនៃការរំលាយ ហើយក្រុមហ៊ុនត្រូវ៖

១- ផ្ញើលិខិតជូនដំណឹងស្តីពីបំណងរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន។

២- ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់ សម្រាប់រយៈពេល២ (ពីរ) សប្តាហ៍ជាប់ៗគ្នា នៅក្នុងសារពត៌មានដែលបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុម ហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬ បោះពុម្ពផ្សាយដទៃទៀត ដូចបានកំណត់ក្នុងបទ បញ្ជារបស់ក្រសួងពាណិជ្ជកម្ម[103]។

### ៣.៤.៣.ការចេញវិញ្ញាបនបត្រ

វិញ្ញាបនបត្រ នេះជាលិខិតបញ្ចប់ជាផ្លូវការនូវអត្ថិភាពនៃក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម ។ ក្រុមហ៊ុនត្រូវបញ្ចប់អត្ថិភាពរបស់ខ្លួននៅថ្ងៃចេញវិញ្ញាបនបត្រនេះ។ ហើយនេះជាដំណាក់កាលចុងក្រោយនៃការបញ្ចប់អត្ថិភាពនៃក្រុមហ៊ុន ។

ក្រោយចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុនត្រូវ៖

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ហ៊ុន បំពេញកាតព្វកិច្ចទាំងឡាយធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី ។

ក្រោយពីទទួលបានលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាព ទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬជាវត្ថុទៅឱ្យម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។[104]

---

[103] មាត្រា ២៥៤ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[104] មាត្រា២៥៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ប្រធានបទស្តីពីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតរួចមក ថា ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ អាចដំណើរការទៅបានគឺត្រូវភ្ជាប់នូវ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដូចកិច្ចសន្យាទូទៅដែរ យ៉ាងណាមិញក្រុមហ៊ុនអាចកើតឡើងប្រកបដោយបុគ្គលិកលក្ខណៈត្រឹមត្រូវស្របច្បាប់ ឬត្រូវតាមផ្លូវគតិយុត្ត។ ជាគោលការណ៍នៃសមាជិកក្រុមហ៊ុនមិនចាំបាច់ត្រូវតែមានសមត្ថភាពដែលទាមទារសម្រាប់ទទួលបានឋានៈជាពាណិជ្ជករឡើយ។ ច្បាប់ចាត់ទុករូបវន្តបុគ្គល ដែលមានសមត្ថភាពក្នុងការចូលរួមជាសមាជិកភាគហ៊ុននៃការបង្កើតនីតិបុគ្គលក្រុមហ៊ុន និងប្រកបពាណិជ្ជកម្មបាន លុះត្រាតែរូបវន្តបុគ្គលនោះមានអាយុចាប់ពី១៨ឆ្នាំ ឡើងទៅ ឬអនីតិជនដែលរួចផុតពីអាណាព្យាបាល។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាប្រភេទក្រុមហ៊ុនដែលមានទ្រង់ទ្រាយធំ និងមានសមាជិកចាប់ពី៣០នាក់ឡើង។ ចំណែកឯដើមទុនសម្រាប់បង្កើត ក្រុមហ៊ុនគឺមានចំនួនយ៉ាងតិចបំផុត (៤,០០០,០០០)បួនលានរៀល ដោយហេតុថា ក្រុមហ៊ុននេះសមាជិកទាំងអស់ទទួលខុសត្រូវត្រឹមតែដើមទុនរបស់ខ្លួនតែប៉ុណ្ណោះ។ ជាពិសេស ក្រុមហ៊ុនគឺត្រូវតែទៅចុះបញ្ជីជាមួយមន្ត្រីគ្រប់គ្រងក្រសួងពាណិជ្ជកម្មជាមុន ទើបក្រុមហ៊ុនអាចដំណើរការអាជីវកម្មរបស់ខ្លួនទៅបាន ប្រសិនបើក្រុមហ៊ុនមិនបានចុះបញ្ជីទេ ក្រុមហ៊ុនធ្វើអាជីវកម្មផ្ទុយច្បាប់។ ការចុះបញ្ជីពាណិជ្ជកម្មនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន ព្រោះថាក្រុមហ៊ុនដែលមាននីតិបុគ្គលិកលក្ខណៈ ដើម្បីធ្វើសកម្មភាពពាណិជ្ជកម្មបាន គឺគិតចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធន ដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបោះ( PLC ) ច្បាប់អនុញ្ញាតឲ្យបោះលក់មូលបត្រជាសាធារណៈ ។ ការពង្រីកទុនបន្ថែមតាមរយៈការលក់មូលបត្រនេះ គឺមានជាសិទ្ធិរបស់ក្រុមហ៊ុន លើសពីនេះទៅទៀត បណ្តាពាណិជ្ជករបរទេសអាចចូលមកធ្វើពាណិជ្ជកម្ម ឬជួញដូរមូលបត្រទៅលើទីផ្សារហ៊ុនកម្ពុជាបាន ព្រោះវាបង្កឲ្យមានភាពងាយស្រួល ដល់អតិថិជនក្នុងការជាវ និងផ្តល់ទំនុកចិត្តខ្ពស់ចំពោះទីផ្សារមូលបត្រដែលធានានូវអ្វីសព្វបែបយ៉ាងដែលធ្វើឲ្យ អតិថិជនស្ម័គ្រចិត្តទិញ និងជឿទុកចិត្ត ដើម្បីពង្រឹងសកម្មភាព ឬពង្រីកនូវទុនវិនិយោគរបស់ខ្លួនឲ្យកាន់តែធំឡើងៗថែមទៀត ។

សហគ្រាសឬក្រុមហ៊ុនពាណិជ្ជកម្ម ដែលធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រងដោយវិធានច្បាប់ពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលបានអនុម័តនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ ១៩៩៥ និងវិសោធនកម្មក្នុងឆ្នាំ១៩៩៩ និងសារាចរណ៍ណែនាំ លេខ ៣៦០ ស្តីពីការចុះបញ្ជីសហគ្រាសពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៧ ព្រមទាំងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដែលបានអនុម័ត នៅខែ

ឧសភា ២០០៥ ។ ដោយសារតែមានក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ទើបបណ្ដាលឲ្យមានសកម្មភាពជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រជាសកម្មភាពថ្មីមួយដែលពុំធ្លាប់មានពីមុនមក។ ទីផ្សារមូលបត្រកម្ពុជា ទើបតែបោះជំហានចូលក្នុងទីផ្សារនៅឆ្នាំ២០១២ ប្រការនេះបាននាំមកនូវភាពលំបាកដល់មហាជនក្នុងការយល់ដឹងអំពី មូលបត្រ និងអំពីដំណើការទិញមូលបត្រក្នុងទីផ្សារមូលបត្រកម្ពុជា។

ចំពោះឈ្មោះវិញ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានកន្ទុយថា"**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ** Public Limited Company "។ ដោយឡែក ពាក្យថា "**ភីអិលស៊ី** (Plc.) **ឬ ម.ក**" គឺជាអក្សរកាត់នៃពាក្យ "**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ** Public Limited Company" ។

ទន្ទឹមនឹងនេះផងដែរ ក្នុងករណីដែល ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានរំលាយ កាលណាកើតមានព្រឹត្តការណ៍នៃការរំលាយក្រុមហ៊ុនកើតឡើងដូចជា ការរំលាយដោយឯកភាព ការរំលាយក្រុមហ៊ុនដោយកម្មវត្ថុផ្ទុយនឹងច្បាប់ ការរំលាយក្រុមហ៊ុនដោយសាលក្រមតុលាការ និងការរំលាយក្រុមហ៊ុនដោយក្ស័យធន។ ក្រុមហ៊ុនធ្វើសេចក្ដីប្រកាសពី បំណងរំលាយជាទម្រង់លម្អិត ទៅឲ្យក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលសេចក្ដី ប្រកាស ពីបំណងរំលាយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុន ពេលនោះក្រុមហ៊ុនត្រូវបញ្ឈប់ធ្វើអាជីវកម្ម ប៉ុន្តែនីតិបុគ្គលភាពរបស់ក្រុមហ៊ុននៅតែមានសុពលភាព ។ ក្រោយពីមានការរំលាយក្រុមហ៊ុនហើយក្រុមហ៊ុនត្រូវធ្វើការជម្រះបញ្ជី។

សរុបសេចក្ដីមក យោងទៅតាមការសង្ខេបឡើងវិញពីខាងលើ យើងខ្ញុំទាំងពីរនាក់យល់ឃើញថា ការបង្កើត និងដំណើរការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចលក់ភាគហ៊ុន និងអាចបោះផ្សាយលក់មូលបត្ររបស់ខ្លួននៅលើទីផ្សារសាធារណៈបាន ដោយអនុលោមតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ មិនតែប៉ុណ្ណោះគឺងាយស្រួលក្នុងការរកប្រាក់ចំណូលបានខ្ពស់ បានទទួលនូវលទ្ធផលល្អច្រើនស្របជាមួយគ្នានេះដែរក៏មានគុណវិបត្តិ និងហានិភ័យខ្ពស់ផងដែរ។

# អនុសាសន៍

យោងតាមរយៈការសិក្សាស្រាវជ្រាវ អំពីប្រធានបទស្ដីពី "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" អស់រយៈពេលកន្លងមកយើងសង្កេតឃើញថា៖ ដើម្បីអាចបង្កើតក្រុមហ៊ុនមួយឲ្យដំណើរការទៅបាន យើងត្រូវសិក្សាស្វែងយល់ពីទម្រង់ លក្ខខណ្ឌដើមទុន និងរចនាសម្ព័ន្ធរបស់ក្រុមហ៊ុននោះឲ្យច្បាស់ជាមុនសិន ជៀសវាងមានភាពមិនប្រក្រតី ភាពខ្វះចន្លោះ ឬមានការធ្វេសប្រហែលត្រង់ចំណុចណាមួយនៅពេលក្រុមហ៊ុនចាប់ផ្ដើមដំណើរការ ការសិក្សាស្វែងយល់លម្អិតទៅតាមដំណាក់កាលនីមួយៗ គឺដើម្បីភាពប្រាកដចិត្ត និងច្បាស់លាស់ថាក្រុមហ៊ុនមួយនោះអាចប្រព្រឹត្ត និងដំណើរការទៅបានដោយរលូន និងស្របច្បាប់។ ទន្ទឹមនឹងនោះ ក៏ត្រូវដឹងពីគោលបំណងក្នុងការបង្កើតក្រុមហ៊ុននោះឡើងមកផងដែរ។ ការបង្កើត និងដំណើរការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនត្រូវមានការចូលរួមសហការពីសំណាក់ម្ចាស់ភាគហ៊ុន អ្នកគ្រប់គ្រង អភិបាល និងបុគ្គលិកក្រុមហ៊ុន។

ទាក់ទងទៅនឹងដំណើរការអាជីវកម្ម ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាក្រុមហ៊ុនដែលបង្កើតឡើងមកដើម្បីស្វែងរកប្រាក់ចំណេញ ដោយធ្វើការលក់ភាគហ៊ុន និងបង្កើតទីផ្សារលក់មូលបត្រដើម្បីឲ្យក្រុមហ៊ុនអាចស្វែងរកប្រាក់ចំណូលបានខ្ពស់ អ្នកដឹកនាំក្រុមហ៊ុនត្រូវមានភាពឆ្លាតវៃ ក្នុងការវិភាគគិតគូរឲ្យបាន វែងឆ្ងាយ អំពីការបញ្ហាប្រឈម និងវិធីសាស្ត្រក្នុងការប្រកួតប្រជែងសេដ្ឋកិច្ចទីផ្សារពីបណ្ដាក្រុមហ៊ុនផ្សេងៗ រួមទាំងការប្រើមនុស្សផងដែរ ។ ជាក់ស្ដែងដូចជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅប្រទេសកម្ពុជាគ្រប់អាជីវកម្ម ទាំងខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ កំពុងប្រកួតប្រជែងទីផ្សារគ្នាយ៉ាងគំហុក ដែលទាមទារឱ្យមានការយល់ដឹង ពីច្បាប់អាជីវកម្មកាន់តែច្រើន ហើយក៏ទាមទារឱ្យអ្នកគ្រប់គ្រង និងបុគ្គលិកជំនាញ ដែលបម្រើការនូវក្រុមហ៊ុន នោះត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ទៅលើវិសាលភាពទីផ្សារពាណិជ្ជកម្ម ដើម្បីទាក់ទាញនូវអតិថិជននានា ។

យើងសង្ឃឹមថាទៅថ្ងៃអនាគត យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល បង្កើតគោលនយោបាយបើកចំហរនូវការយោគយល់ និងអនុគ្រោះដល់ជនបរទេស បង្កើតឲ្យមានការផ្ដល់នូវសិទ្ធិឲ្យច្រើនជាង ការធ្វើនូវជាម្ចាស់ទៅលើអគារសហកម្មសិទ្ធិដល់ជនបរទេស ពីព្រោះនេះគឺជាគោលនយោបាយដើម្បីទាក់ទាញ ជនបរទេសមកបណ្ដាក់ទុន ដើម្បីជួយជំរុញឲ្យសេដ្ឋកិច្ចនៅប្រទេសកម្ពុជាកាន់តែមានភាពរីកចម្រើនខ្លាំង ក៏ដូចជាបង្កើតការងារក្នុងស្រុកដល់ប្រជាពលរដ្ឋខ្មែរផងដែរ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសដល់ពួកគាត់។ ម្យ៉ាងវិញទៀតរាជរដ្ឋាភិបាល ត្រូវតែរៀបចំការងារជាច្រើនដើម្បីជួយដល់ការទាក់ទាញ វិនិយោគិនបរទេសមកកាន់កម្ពុជា ក្រៅពីនេះរាជរដ្ឋាភិបាលគួរតែរៀបចំប្រព័ន្ធគ្រប់គ្រងច្បាប់វិនិយោគិនឲ្យបានច្បាស់លាស់ និងគួរតែអាចទុកចិត្តបាន ដើម្បីបង្កើនទំនុកចិត្តសម្រាប់វិនិយោគិនបរទេសមកធ្វើការវិនិយោគ ដោយផ្ទាល់។ ជា

ពិសេសជួយពង្រឹងទំនាក់ទំនងវិស័យសេដ្ឋកិច្ចក្នុងការធ្វើអាជីវកម្មរវាងរដ្ឋ និងរដ្ឋបណ្ដាប្រទេស ផ្សេងៗក្នុងការវិនិយោទុនផងដែរ ព្រមទាំងផ្ដល់ភាពងាយស្រួល និងទំនុកចិត្តខ្ពស់ដល់បរទេសក្នុងការមក បណ្ដាក់ទុននៅប្រទេសកម្ពុជាកាន់តែច្រើនឡើងៗលើសពីនេះយើងក៏អាចទាញយកផលចំណេញទាំងនេះ ក្នុងការផ្សព្វផ្សាយឲ្យមានមនុស្សស្គាល់ប្រទេសកម្ពុជាឲ្យកាន់តែច្រើន ដើម្បីទាក់ទាញផ្នែកវិស័យវិនិយោគទុនឲ្យរីកចម្រើនបានមួយកម្រិតទៀត។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញ
  - ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា
- លិខិតគតិយុត្ត
  - ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃ ទី១៦ ខែមិថុនាឆ្នាំ២០០៥
  - ច្បាប់ស្តីពីវិសោធកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩
  - ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- សៀវភៅណែនាំ
  - នីតិសហគ្រាសពាណិជ្ជកម្ម របស់លោកគ្រូ ខាត់ ធី នៅឆ្នាំ២០០៨
  - នីតិពាណិជ្ជកម្ម របស់លោកគ្រូ គង់ សាផន នៅឆ្នាំ២០១២

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

**ឧបសម្ព័ន្ធទី២៖** ប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

**ឧបសម្ព័ន្ធទី៣៖** ប្រកាសស្តីពីការដាក់ឲអនុវត្តនូវការកែប្រែ វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

**ឧបសម្ព័ន្ធទី៤៖** គំរូពាក្យសុំ

**ឧបសម្ព័ន្ធទី៥៖** គំរូលក្ខន្តិកៈក្រុមហ៊ុន និងការណែនាំ (ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)

**ឧបសម្ព័ន្ធទី៦៖** លក្ខខន្តិកៈរបស់ធនាគាអេស៊ីលីដា

# ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពី
# សហគ្រាសពាណិជ្ជកម្ម

## ព្រះរាជក្រម

នស/រកម/០១២២/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សម្មានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខៈ ០២៥
ថ្ងៃៈ ... ទី ២ ខែកុម្ភៈ ឆ្នាំ២០២២
ម៉ោងៈ ១១:០០នាទី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ .-**

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម៖

- ដោយធ្វើនិរាករណ៍ មាត្រា១៦៦ មាត្រា១៧៥ មាត្រា១៨២ មាត្រា១៨៣ មាត្រា១៨៤ មាត្រា១៨៥ មាត្រា១៨៦ មាត្រា១៨៧ មាត្រា១៨៨ មាត្រា១៨៩ មាត្រា១៩០ និងមាត្រា១៩៦

- ដោយកែប្រែ មាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៥៩ មាត្រា៦២ មាត្រា៨៧ មាត្រា១០១ មាត្រា១០៦ មាត្រា១១០ មាត្រា១១៤ មាត្រា១១៥ មាត្រា១៣៧ មាត្រា១៤៤ មាត្រា១៦១ មាត្រា១៧៤ មាត្រា១៩២ មាត្រា១៩៥ មាត្រា២២៥ មាត្រា២៣៤ មាត្រា២៥៥ មាត្រា២៦២ មាត្រា២៧០ និងមាត្រា២៧១ និងដោយកែប្រែជំពូកនិងផ្នែក ព្រមទាំងបន្ថែមមាត្រា៨ ស្ទួន មាត្រា៨៣ ស្ទួន ក្នុងជំពូកទី២ និងមាត្រា១៤៧ ស្ទួន ក្នុងជំពូកទី៣ ដូចតទៅ៖

**មាត្រា១ .- ថ្មី**

ច្បាប់នេះកំណត់ពីទម្រង់នៃសហគ្រាសពាណិជ្ជកម្មដែលជាសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនិងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

**មាត្រា២ .- ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១-បុគ្គល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

២-ពាណិជ្ជករ សំដៅដល់បុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបររបស់ខ្លួនជាប្រចាំ។

៣-មន្ត្រីចុះបញ្ជី សំដៅដល់អ្នកទទួលចុះបញ្ជីដែលបានតែងតាំងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

៤-ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម សំដៅដល់ការិយាល័យដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

៥-បុត្រសម្ព័ន្ធ សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនមួយផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ"។

៥.១-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានក្រុមហ៊ុនសហកម្មសិទ្ធិមេកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ។

៥.២-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនត្រូវបានក្រុមហ៊ុនមូលធនមេត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងបុត្រសម្ព័ន្ធនោះ។

៦-លេខាធិការរបស់ក្រុមហ៊ុន សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុនមូលធន ហើយមានសិទ្ធិក្នុងការទទួលនិងរក្សាទុកឯកសារដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រុមហ៊ុន។

**មាត្រា៣ .– ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមូលធន ត្រូវមានលេខាធិការរបស់ក្រុមហ៊ុនដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវផ្ដល់ជូនមន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដនិងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា។

ក្រុមហ៊ុនមូលធន ត្រូវផ្ដល់ជូនមន្ត្រីចុះបញ្ជីនូវឈ្មោះរបស់លេខាធិការរបស់ក្រុមហ៊ុន ហើយលេខាធិការរបស់ក្រុមហ៊ុននោះត្រូវតែជារូបវន្តបុគ្គលដែលមានកាយសម្បទានិងសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ។ លេខាធិការរបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតផ្លូវការនិងឯកសារទាំងឡាយព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការ ក្នុងនាមក្រុមហ៊ុនមូលធននោះ។

សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវផ្ដល់ជូនមន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្ដូរទីស្នាក់ការចុះបញ្ជីក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្ដូរ។ ក្រុមហ៊ុនមូលធន ត្រូវផ្ដល់ជូនមន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្ដូរទីស្នាក់ការចុះបញ្ជីនិងការផ្លាស់ប្ដូរលេខាធិការរបស់ក្រុមហ៊ុនក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្ដូរ។

សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .– ថ្មី**

ឯកសារនិងព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្ដល់ទៅឱ្យក្រុមហ៊ុនមូលធនត្រូវប្រគល់ទៅឱ្យលេខាធិការរបស់ក្រុមហ៊ុននៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។

ឯកសារនិងព័ត៌មានត្រូវប្រគល់ទៅឱ្យម្ចាស់សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិក្នុងអំឡុងម៉ោងធ្វើការធម្មតា លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករទូទៅបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះត្រូវផ្ញើទៅឱ្យក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្ម។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីតាមគ្រប់មធ្យោបាយ ត្រូវបានចាត់ទុកថាជាការបញ្ជូនទៅសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធននោះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥ .- ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនត្រូវប្រើនាមករណ៍ជាភាសាខ្មែរ។ នាមករណ៍ជាភាសាខ្មែរត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំស្មើនឹងពីរដងធំជាងភាសាដទៃទៀត ប្រសិនបើមាន។ ការបកប្រែន័យរបស់នាមករណ៍សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់។ នាមករណ៍ជាភាសាខ្មែរនិងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរនៅផ្នែកខាងលើនៃក្រាសញ្ញាក្បាលលិខិត បែបបទឯកសារឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន។

## ជំពូកទី២ ថ្មី

## សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិ

### ផ្នែកទី១ ថ្មី

### សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ក (ថ្មី). ការបង្កើតសហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**

**មាត្រា៨ .- ស្តួន**

សហគ្រាសឯកបុគ្គល គឺជាសហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។

ម្ចាស់សហគ្រាសឯកបុគ្គល គឺជាពាណិជ្ជករ។

សហគ្រាសឯកបុគ្គល ដែលស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

នាមករណ៍របស់សហគ្រាសឯកបុគ្គលត្រូវដាក់នូវពាក្យថា "សហគ្រាសឯកបុគ្គល" ឬសរសេរជាអក្សរកាត់ដាក់ខាងចុងឬខាងក្រោម។

កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់សហគ្រាសឯកបុគ្គល គឺជាការទទួលខុសត្រូវដោយផ្ទាល់និងដោយគ្មានកម្រិតលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសនោះ។ សហគ្រាសឯកបុគ្គលមិនតម្រូវឱ្យមានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ។ សហគ្រាសឯកបុគ្គលមិនមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីម្ចាស់សហគ្រាសឡើយ។

## ខ (ថ្មី). ការរំលាយ និងការជម្រះបញ្ជីសហគ្រាសឯកបុគ្គល និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### មាត្រា៥៣ .- ស្ទួន

ម្ចាស់សហគ្រាសឯកបុគ្គល អាចរំលាយសហគ្រាសរបស់ខ្លួនបាននៅពេលណាក៏បាន។

សហគ្រាសឯកបុគ្គល អាចត្រូវបានរំលាយដោយមូលហេតុដូចខាងក្រោម៖

- តាមការស្ម័គ្រចិត្ត
- មរណភាពរបស់ម្ចាស់សហគ្រាស
- សេចក្តីសម្រេចរបស់តុលាការ។

នីតិវិធីក្នុងការរំលាយសហគ្រាសឯកបុគ្គលតាមការស្ម័គ្រចិត្តឬមរណភាពរបស់ម្ចាស់សហគ្រាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយមានអនុលោមភាពតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា៥៩ .- ថ្មី

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅតាមទម្រង់បែបបទដែលបានកំណត់និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបោះពុម្ពឬផ្សព្វផ្សាយនៅទីកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀត ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

### មាត្រា៦២ .- ថ្មី

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរំលាយ រហូតដល់រយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ពីពេលដែលជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះ តម្រូវឱ្យទុកជាភស្តុតាង។

### មាត្រា៨៧ .- ថ្មី

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទម្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានចុះបញ្ជីតាមច្បាប់ ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការបោះផ្សាយលក់មូលបត្រជូនសាធារណៈត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មាត្រា១០១ .– ថ្មី**

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរលុះត្រាតែ៖

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្មនិងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី៥១(ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គលឬនីតិបុគ្គលសញ្ជាតិខ្មែរ ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម។

**មាត្រា១០៦ .– ថ្មី**

ក្រុមហ៊ុនឬបុគ្គលម្នាក់ដែលជានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោម ជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជន ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបានឡើយ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ឬបានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួនឬដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ៖

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ។

គ-ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំងឬមិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តនិងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬលេខាធិការរបស់ក្រុមហ៊ុនណាម្នាក់មិនមានសុពលភាពឬមិនយកជាការបានឡើយ។

ច-ប្រាក់ខ្ចីនិងការធានា ឬការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ។

**មាត្រា១១០ .– ថ្មី**

ម្ចាស់ភាគហ៊ុននិងម្ចាស់បំណុលរបស់ក្រុមហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចពិនិត្យគ្រប់ឯកសារដូចដែលបានចែងនៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើ[illegible]យមិនគិតកម្រៃ។

[illegible]ក្រុមហ៊ុនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាច[illegible]ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប។

**មាត្រា១៦១ .- ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងផ្នែកទី២នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១-អ្នកទិញដោយសុទ្ធចិត្ត សំដៅដល់អ្នកទិញដែលបង់ថ្លៃឱ្យត្រឹមត្រូវ និងដោយមិនដឹងថាមានបណ្តឹងទាមទារណាមួយ ហើយជាអ្នកដែលធ្វើការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ជាអ្នកកាន់កាប់ ឬជាអ្នកបញ្ជាដែលទទួលការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ចុះបញ្ជីដែលបានបោះចេញឱ្យ។

២-អ្នកជើងសា សំដៅដល់បុគ្គលជាប់កាតព្វកិច្ចទាំងស្រុងឬមួយភាគនៃពេលវេលារបស់ខ្លួនក្នុងកិច្ចការជួញដូរមូលបត្រ និងជាអ្នកធ្វើសកម្មភាពជំនួសគេ ឬទិញមូលបត្រពីអតិថិជន ឬលក់មូលបត្រទៅឱ្យអតិថិជនក្នុងកិច្ចការជំនួញដែលជាប់ពាក់ព័ន្ធនោះ។

៣-ការប្រគល់ សំដៅដល់ការផ្ទេរកាកាន់កាប់ដោយឆន្ទៈ។

៤-សុទ្ធ សំដៅដល់ពិតប្រាកដមិនក្លែងក្លាយឬក្លែងបន្លំ។

៥-ម្ចាស់មូលបត្រ សំដៅដល់បុគ្គលដែលកាន់កាប់មូលបត្រភាគហ៊ុនក្នុងលក្ខន្តិកៈក្រុមហ៊ុន ដែលត្រូវបានចេញដោយក្រុមហ៊ុនមូលធន។

៦-ចេញបន្ថែម សំដៅដល់ការចេញមូលបត្រលើសពីចំនួនអតិបរមានៃមូលបត្រ ដែលអ្នកចេញមូលបត្រត្រូវផ្តល់សិទ្ធិតាមលក្ខន្តិកៈរបស់ខ្លួន ឬតាមកិច្ចសន្យាច្បាស់លាស់ក្នុងការចេញមូលបត្រ។

៧-អ្នកជាវ សំដៅដល់បុគ្គលដែលទាញរកចំណេញពីមូលបត្រដោយធ្វើការលក់ បញ្ចាំ ផ្ញើហ៊ីប៉ូតែក ចេញប័ណ្ណ ចេញប័ណ្ណសាជាថ្មី ធ្វើអំណោយនូវមូលបត្រនោះ ឬក៏ទាញរកចំណេញតាមកិច្ចការជំនួញណាមួយផ្សេងទៀតដោយឆន្ទៈ។

៨- មូលបត្រ សំដៅដល់លិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែល៖

ក-ស្ថិតក្នុងទម្រង់ទ្រាយចុះបញ្ជី។

ខ-ជាគំរូប័ណ្ណមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬលើទីផ្សារមូលបត្រ ឬបានទទួលស្គាល់នៅក្នុងវិស័យណាមួយដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញឬត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ។

គ-ជាប្រភេទមួយឬស៊េរីមួយនៃមូលបត្រ ដែលចែកនៅក្នុងប្រភេទឬស៊េរីនៃលិខិតស្នាម។

ឃ-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែក ឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗ ក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន។

៩-ការផ្ទេរ សំដៅដល់ជាការផ្ទេរដែលរួមបញ្ចូលទាំងការបញ្ជូនឱ្យដោយប្រតិបត្តិតាមច្បាប់។

១០-គ្មានសិទ្ធិក្នុងការចុះហត្ថលេខា សំដៅដល់មនុស្សម្នាក់ប្រព្រឹត្តដោយគ្មានសិទ្ធិពិតប្រាកដ ហើយរួមទាំងការក្លែងបន្លំផងៗ

**មាត្រា១៧៤ .- ថ្មី**

នៅក្នុងបណ្តឹងពាក់ព័ន្ធលើមូលបត្រ៖

ក-[illegible]ការចុះហត្ថលេខាលើមូលបត្រ ក្នុងករណីចាំបាច់គឺត្រូវបានទទួលស្គាល់ លើកលែងតែ[illegible]ជាក់លាក់។

[illegible]នៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវនិងមានការអនុញ្ញាត។ ប៉ុន្តែប្រសិនបើ[illegible]លេខាត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុតាងគឺស្ថិតនៅលើភាគីប្តឹងតវ៉ា។

គ-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវឬត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្ដល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចម្លើយបង្ហាញភស្តុតាងផ្ទុយឬកង្វះខាតលើសុពលភាពនៃមូលបត្រនោះ។

ឃ-បើភាគីចុងចម្លើយលើកឡើងនូវភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនោះទៅវិញ។

**មាត្រា១៩២ .- ថ្មី**

ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវពីបុគ្គលណាមួយក្នុងមូលហេតុណាក៏ដោយរួមទាំងអសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែចំពោះអ្នកទិញដោយសុទ្ធចិត្តដើម្បី៖

១-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ។

២-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិដូចគ្នាទាំងអស់ឬមួយផ្នែក។

៣-ទាមទារពល់ការខូចខាតទាំងឡាយ។

សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញដើម្បីរង់ចាំបណ្ដឹងតវ៉ា។

**មាត្រា១៩៥ .- ថ្មី**

ពេលណាដែលមូលបត្រនៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិនោះក្នុងករណីដូចតទៅ៖

១-ច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារត្រូវបានអនុវត្ត។

២-ការផ្ទេរកម្មសិទ្ធិនោះគឺស្របតាមច្បាប់ឬផ្ទេរទៅឱ្យអ្នកជាពិតប្រាកដ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជី ការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួលខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ដែលកើតឡើងពីការពន្យារពេលមិនសមហេតុសមផលក្នុងការចុះបញ្ជី ឬពីការខកខាន ឬការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ។

**មាត្រា២២៥ .- ថ្មី**

ម្ចាស់ភាគហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបានដោយមិនគិតថ្លៃ។

**មាត្រា២៣៤ .- ថ្មី**

សវនករត្រូវធ្វើការត្រួតពិនិត្យលើចំណុចដែលខ្លួនយល់ថាចាំបាច់ ដើម្បីរាយការណ៍ជូនម្ចាស់ភាគហ៊ុនទាំងឡាយលើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុនឬអភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុន ត្រូវផ្ដល់ព័ត៌មាន ការបកស្រាយបំភ្លឺ និងបញ្ជី

គណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ។

សវនកររបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាតម្ចាស់ភាគហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករ ដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន។

ប្រសិនបើអភិបាលឬម្ចាស់ភាគហ៊ុន ទោះបីជាម្ចាស់ភាគហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្នឬសវនករពីមុនក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃមុនមហាសន្និបាត សវនករបច្ចុប្បន្នឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ។

**មាត្រា២៥៥ .- ថ្មី**

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវៈ

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន
- បំពេញកាតព្វកិច្ចទាំងឡាយ
- ធ្វើសកម្មភាពផ្សេងទៀតដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី
- តែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់ម្ចាស់ភាគហ៊ុន។ អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយនិងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ទាំងកម្មសិទ្ធិជាសាច់ប្រាក់ឬជាវត្ថុទៅឱ្យម្ចាស់ភាគហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនដែលបានរំលាយ រយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំចាប់ពីកាលបរិច្ឆេទជម្រះបញ្ជីរួច។

**មាត្រា២៦២ .- ថ្មី**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬហេតុការណ៍ពិតដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ។

ក្នុងករណីចាំបាច់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឱ្យក្រុមហ៊ុន[illegible]នូវព័ត៌មានដែលបានចុះបញ្ជីឬដែលបានធ្វើប្រតិវេទន៍ប្រចាំឆ្នាំនៅគ្រប់កាលៈទេសៈ។ [illegible]គ្រប់គ្រងក្រុមហ៊ុនមានសិទ្ធិចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារដែលបានធ្វើប[illegible]ដល់[illegible]ាក់ការរបស់ក្រុមហ៊ុន និងតម្រូវឱ្យក្រុមហ៊ុនផ្ដល់ព័ត៌មានឬឯកសារបន្ថែម ដើម្បី[illegible]ព័ត៌មាននិងឯកសារ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នីតិវិធីនៃការតម្រូវឱ្យក្រុមហ៊ុនធ្វើបច្ចុប្បន្នកម្មនូវព័ត៌មានដែលបានចុះបញ្ជីឬធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងការចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៤ ថ្មី

## សាខាក្រុមហ៊ុនក្នុងស្រុកនិងក្រុមហ៊ុនពាណិជ្ជកម្មបរទេស

### មាត្រា២៧០.- ថ្មី

ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលបានបង្កើតឡើងក្រោមច្បាប់នេះ អាចបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកមួយឬច្រើនបាន។ ក្រុមហ៊ុនដែលបង្កើតសាខា ត្រូវហៅថា "ក្រុមហ៊ុនដើម"។

សាខាក្រុមហ៊ុនក្នុងស្រុកគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

សាខាក្រុមហ៊ុនក្នុងស្រុកអាចធ្វើត្រឹមតែសកម្មភាពដែលមានចែងក្នុងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនដើមតែប៉ុណ្ណោះ។

ទ្រព្យសកម្មរបស់សាខាក្រុមហ៊ុនក្នុងស្រុកគឺជាទ្រព្យសកម្មរបស់ក្រុមហ៊ុនដើម។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើសកម្មភាពនិងកាតព្វកិច្ចរបស់សាខាក្រុមហ៊ុនក្នុងស្រុក។

សាខាក្រុមហ៊ុនក្នុងស្រុកត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូបឬច្រើនរូប ដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម។

នាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុកគឺជានាមករណ៍របស់ក្រុមហ៊ុនដើម។ នៅពីលើឬនៅពីមុខនាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុកនោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុនក្នុងស្រុក"។

សាខាក្រុមហ៊ុនក្នុងស្រុកអាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម ហើយក្រុមហ៊ុនដើមត្រូវស្នើសុំមកក្រសួងពាណិជ្ជកម្មដើម្បីលុបចេញពីបញ្ជីពាណិជ្ជកម្ម។

### មាត្រា២៧១.- ថ្មី

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយមានទីតាំងធ្វើពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមានទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានតាមបែបបទផ្សេងៗ ដូចតទៅៈ

ក-ការិយាល័យតំណាងពាណិជ្ជកម្មឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម។

ខ-សាខាក្រុមហ៊ុនពាណិជ្ជកម្ម។

គ-បុត្រសម្ព័ន្ធ។

ការិយាល័យតំណាងពាណិជ្ជកម្មនិងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ហត្ថលេខា ៖-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ១៤កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២២

នសីហមុនី

នសរ.២២០១.០៥៩

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានថ្លែងថាត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# ព្រះរាជក្រម

## យើង

នស/រកម/០១២២/០០៣

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

លេខ: ០២៥
ថ្ងៃ: ... ទី ២ ខែ កុម្ភៈ ឆ្នាំ២០២២
ម៉ោង: ១១:០០ នាទី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE ... PALAIS ROYAL

# ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្ម សម្រាប់ សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.......០១៣/.១០.គ.ម.ក (ប្រ.ក

# ប្រកាស

## ស្ដីពី

## អភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈ បោះផ្សាយលក់មូលបត្រជាសាធារណៈ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ/បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ/បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមទៅតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសហគ្រាសសាធារណៈ ដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- ការធានាអភិបាលកិច្ចល្អ**

សហគ្រាសសាធារណៈដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ តាមរយៈការបង្កើតយន្តការដើម្បីការពារសិទ្ធិរបស់ភាគហ៊ុនិក ការរៀបចំរចនាសម្ព័ន្ធ

គ្រប់គ្រង និងអភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសសាធារណៈ ការកំណត់សិទ្ធិអំណាច និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតប្រព័ន្ធត្រួតពិនិត្យ ប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ ស្របតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ៤.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ÷

១-ក្រុមប្រឹក្សាភិបាល សំដៅដល់ក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ ដែលមានសមាជិកមួយចំនួនត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ស្ថាប័នពាក់ព័ន្ធ និងសមាជិកមួយចំនួនផ្សេងទៀតត្រូវបោះឆ្នោតជ្រើសតាំងដោយភាគហ៊ុនិក និងសមាជិក ០១ (មួយ) រូបទៀតជាតំណាងនិយោជិតដែលត្រូវបោះឆ្នោតជ្រើសតាំងចេញពីនិយោជិត និងដោយនិយោជិត។

២-គណៈកម្មាធិការសវនកម្ម សំដៅដល់គណៈកម្មាធិការមួយនៃក្រុមប្រឹក្សាភិបាល ដែលទទួលខុសត្រូវក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ នូវរាល់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសបោះផ្សាយ និងការត្រួតពិនិត្យខាងក្នុង និងខាងក្រៅ ព្រមទាំងសវនកម្ម។

៣-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សា-ភិបាល ដែលទទួលខុសត្រូវក្នុងការវិភាគ វាយតម្លៃ តាមដាន និងរាយការណ៍ អំពីហានិភ័យរបស់សហគ្រាសបោះផ្សាយ ព្រមទាំងគ្រប់គ្រងហានិភ័យទាំងនោះ។

៤-គណៈកម្មាធិការតែងតាំង សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាល ដែលទទួលខុសត្រូវក្នុងការពិនិត្យ និងការវាយតម្លៃអំពីគុណវុឌ្ឍិបេក្ខភាពដែលត្រូវតែងតាំងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

៥-បុគ្គលិកជាន់ខ្ពស់ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានរហូតដល់អគ្គនាយក រួមទាំងលេខាធិការសហគ្រាសបោះផ្សាយ និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងសហគ្រាសបោះផ្សាយ។

៦-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច សំដៅដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចំនួនតិចជាង ០៥ (ប្រាំ) ភាគរយនៃភាគហ៊ុនសរុបរបស់សហគ្រាសបោះផ្សាយ។

៧-ភាគហ៊ុនិកសាធារណៈ សំដៅដល់នីតិបុគ្គលសាធារណៈដែលកាន់កាប់ភាគកម្មសាធារណៈនៅក្នុងសហគ្រាសបោះផ្សាយ។

៨-ភាគកម្មសាធារណៈ សំដៅដល់ចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចំរុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬដោយក្រុមហ៊ុនរដ្ឋ។

៩-ភាគហ៊ុនិកឯកជន សំដៅដល់បុគ្គលឯកជនដែលកាន់កាប់ភាគហ៊ុន នៅក្នុងសហគ្រាសបោះផ្សាយ។

១០-សមាជិកគ្រួសារផ្ទាល់ សំដៅដល់ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស បងប្អូនស្រី។

១១-សវនករឯករាជ្យ សំដៅដល់សវនកររបស់ក្រុមហ៊ុនគណនេយ្យជំនាញដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ហើយដែលទទួលស្គាល់ដោយ **គ.ម.ក.**។

១២-សហគ្រាសសាធារណៈ សំដៅដល់សហគ្រាសដែលបង្កើតឡើង ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

១៣-សហគ្រាសបោះផ្សាយ សំដៅដល់សហគ្រាសសាធារណៈដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ។

១៤-សែលហ្វ៍ឌៀលីង (Self-Dealing) សំដៅដល់ទង្វើរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស អ្នកផ្តល់ប្រឹក្សាច្បាប់ បុគ្គលិករបស់សហគ្រាសបោះផ្សាយ ឬក៏បុគ្គលពាក់ព័ន្ធនឹងកិច្ចសន្យាដែលទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួន នៅក្នុងប្រតិបត្តិការណាមួយ។

១៥-អភិបាល សំដៅដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់សហគ្រាសបោះផ្សាយ ដែលអាចជាអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ ឬអភិបាលឯករាជ្យ។

១៦-អភិបាលឯករាជ្យ សំដៅដល់សមាជិកឯករាជ្យដែលមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រង ផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅ ដែលមិនសមស្រប។

១៧-អភិបាលប្រតិបត្តិ សំដៅដល់អភិបាលដែលមានមុខតំណែងជាបុគ្គលិកជាន់ខ្ពស់ក្នុងសហគ្រាសបោះផ្សាយ។

១៨-អភិបាលមិនប្រតិបត្តិ សំដៅដល់អភិបាលដែលមិនប្រតិបត្តិការងារប្រចាំថ្ងៃនៅក្នុងសហគ្រាសបោះផ្សាយ ហើយអភិបាលមិនប្រតិបត្តិនេះ អាចជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកសាធារណៈ។

## ជំពូកទី ២

## ភាគហ៊ុនិក

### ប្រការ ៥.- សិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិកត្រូវបានគោរព និងការពារដោយក្រុមប្រឹក្សាភិបាលរបស់សហគ្រាសបោះផ្សាយ។

ភាគហ៊ុនិកមានសិទ្ធិចុះបញ្ជីកម្មសិទ្ធិ សិទ្ធិលក់ ឬផ្ទេរភាគហ៊ុន សិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធពីសហគ្រាសបោះផ្សាយ សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក និងសិទ្ធិបោះឆ្នោត។

### ប្រការ ៦.- សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច

សិទ្ធិ និងផលប្រយោជន៍របស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច ត្រូវបានការពារដោយក្រុមប្រឹក្សាភិបាលរបស់សហគ្រាសបោះផ្សាយ រួមមាន ÷

- សិទ្ធិស្វែងរកព័ត៌មាន
- សិទ្ធិក្នុងការបញ្ចេញយោបល់
- សិទ្ធិស្នើកែតម្រូវ។

ក្រុមប្រឹក្សាភិបាលត្រូវធានាធ្វើឱ្យប្រសើរឡើង នូវអន្តរកម្មរវាងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច បុគ្គលិកជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

### ប្រការ ៧.- សិទ្ធិទទួលព័ត៌មាន

សហគ្រាសបោះផ្សាយគួរតែមានគេហទំព័រមួយដែលអាចឱ្យភាគហ៊ុនិក និងសាធារណជនអាចទទួលបានព័ត៌មាន។ ភាគហ៊ុនិកអាចទទួលបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ព្រមទាំងព័ត៌មានរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់តាមរយៈគេហទំព័ររបស់សហគ្រាសបោះផ្សាយ និងព័ត៌មានផ្សេងទៀតអំពីសហគ្រាសបោះផ្សាយ។ ប្រសិនបើសហគ្រាសបោះផ្សាយមិនមានគេហទំព័រទេ ភាគហ៊ុនិកអាចធ្វើសំណើសុំថតចម្លងឯកសារដូចរៀបរាប់ខាងលើ ដោយតម្រូវឱ្យបង់ថ្លៃសមរម្យសម្រាប់ការបោះពុម្ព និងការចែកចាយឯកសារទាំងនោះ។

### ប្រការ ៨.- ការផ្តល់នូវសិទ្ធិស្មើគ្នាសម្រាប់ភាគហ៊ុនិក

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដែលមានថ្នាក់ដូចគ្នាត្រូវមានសិទ្ធិដូចគ្នា។ នីតិវិធី និងដំណើរការនៃមហាសន្និបាតភាគហ៊ុនិក ត្រូវរៀបចំឡើងក្នុងលក្ខខណ្ឌដែលអនុញ្ញាតឱ្យភាគហ៊ុនិកទទួលបាននូវសិទ្ធិដូចគ្នា។

ភាគហ៊ុនធម្មតាក្នុងមួយភាគហ៊ុន ត្រូវផ្តល់ឱ្យភាគហ៊ុនិក នូវសិទ្ធិបោះឆ្នោតមួយសម្លេង ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ហើយសិទ្ធិបោះឆ្នោតនេះមិនអាចត្រូវបានរឹតត្បិតដោយបុគ្គលណាឡើយ។

ភាគហ៊ុនិកត្រូវតែទទួលបាននូវព័ត៌មានចាំបាច់ និងទាន់ពេល ពីសហគ្រាសបោះផ្សាយដូចៗគ្នា ដោយគ្មានភាគហ៊ុនិកណាម្នាក់អាចទទួលបានព័ត៌មាន ដែលមិនទាន់បង្ហាញជាសាធារណៈពីសហគ្រាសបោះផ្សាយនោះទេ។

**ប្រការ ៩.- កិច្ចការពារភាគហ៊ុនិក និងទង្វើហាមឃាត់**

អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិក មិនត្រូវមានជាប់ពាក់ព័ន្ធ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬសែលហ្វ៍ដៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយ មិនត្រូវធ្វើការជួញដូរមូលបត្ររបស់សហគ្រាសបោះផ្សាយក្នុងរយៈពេល ÷

- ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ។
- ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

នៅក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រជាសាធារណៈ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ គ.ម.ក. សហគ្រាសបោះផ្សាយត្រូវអនុម័ត និងផ្សព្វផ្សាយគោលនយោបាយគ្រប់គ្រងការជួញដូរមូលបត្ររបស់សហគ្រាសបោះផ្សាយ ដែលធ្វើឡើងដោយអភិបាល និងបុគ្គលិក។

**ប្រការ ១០.- ការទទួលខុសត្រូវរបស់ភាគហ៊ុនិក**

ភាគហ៊ុនិកត្រូវមានការទទួលខុសត្រូវ ចំពោះការប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួន។ ចំពោះភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ត្រូវតែមានកាតព្វកិច្ចផ្តល់ព័ត៌មានដល់សាធារណជន នៅពេលដែលមានការផ្លាស់ប្តូរចំនួនភាគហ៊ុនដែលខ្លួនកាន់កាប់។

## ជំពូកទី ៣
## ក្រុមប្រឹក្សាភិបាល

**ប្រការ ១១.- សមាសភាពក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលរបស់សហគ្រាសបោះផ្សាយត្រូវមានសមាជិកមិនលើសពី ០៧ (ប្រាំពីរ) រូបឡើយ ដោយអនុលោមទៅតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ ក្រុមប្រឹក្សាភិបាល

ត្រូវមានអភិបាលឯករាជ្យយ៉ាងតិចចំនួន ០១ (មួយ) រូប និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនយ៉ាងតិចចំនួន ០១ (មួយ) រូប។

**ប្រការ ១២.- តួនាទីរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលត្រូវបំពេញតួនាទីរបស់ខ្លួន ប្រកបដោយសុចរិត ជំនាញ និងយកចិត្តទុកដាក់ដោយអនុវត្តនូវតួនាទីសំខាន់ៗ ដូចខាងក្រោម ÷

១-ត្រូវមានការទទួលខុសត្រូវពេញលេញ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់សហគ្រាសបោះផ្សាយ និងភាគហ៊ុនិក។

២-ត្រូវតែប្រតិបត្តិដោយស្មោះត្រង់ ប្រកបដោយសុឆន្ទៈ និងដើម្បីផលប្រយោជន៍របស់សហគ្រាសបោះផ្សាយ និងភាគហ៊ុនិក។

៣-ត្រូវធានាថា សហគ្រាសបោះផ្សាយបានធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយភាគហ៊ុនិក និងភាគីពាក់ព័ន្ធដទៃទៀត។

៤-ធ្វើការកំណត់ តាមដាន និងវាយតម្លៃយុទ្ធសាស្ត្រ គោលនយោបាយ លក្ខណៈវិនិច្ឆ័យប្រសិទ្ធភាពគ្រប់គ្រង និងផែនការធុរកិច្ច។

៥-បង្កើត និងតាមដានការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង។

៦-ផ្តល់នូវភាពជាអ្នកដឹកនាំ ដោយដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ព្រមទាំងធានាឱ្យបានថាធនធានត្រូវបានរៀបចំជាស្រេច ដើម្បីឆ្លើយតបចំពោះគោលដៅដែលបានកំណត់។

៧-អភិបាលមិនត្រូវប្រើអំណាចផ្ទាល់ខ្លួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល ទៅគាបសង្កត់បុគ្គលិកជាន់ខ្ពស់ នៅក្នុងការអនុវត្តការងាររបស់គេឡើយ។

៨-ផ្តល់អនុសាសន៍ ដល់ក្រសួងអាណាព្យាបាលបច្ចេកទេស អំពីការផ្លាស់ប្តូរអគ្គនាយកររបស់សហគ្រាសបោះផ្សាយ។

**ប្រការ ១៣.- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងមាត្រា ៨ នៃអនុក្រឹត្យស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ សមាជិកក្រុមប្រឹក្សាភិបាល រួមទាំងអភិបាលឯករាជ្យ ត្រូវចូលរួមដោយផ្ទាល់គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលសហគ្រាសបោះផ្សាយ ទាំងសាមញ្ញ និងវិសាមញ្ញ។

អភិបាលត្រូវមានការទទួលខុសត្រូវច្បាស់លាស់ ក្នុងន័យថា គ្មានបុគ្គលជាអភិបាលណាម្នាក់ ឬបុគ្គលមួយក្រុមតូចណាមួយ អាចគ្របសង្កត់លើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលឡើយ។

**ប្រការ ១៤.- លាភការរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់**

អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ទទួលបានលាភការដូចគ្នាទៅនឹងលាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងភាគហ៊ុនិកសាធារណៈ។

សហគ្រាសបោះផ្សាយត្រូវមានគោលនយោបាយផ្លូវការ និងមានតម្លាភាពស្តីអំពីលាភការ ដោយត្រូវកំណត់កញ្ចប់លាភការ និងប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ឱ្យបានច្បាស់លាស់។

របាយការណ៍ប្រចាំឆ្នាំរបស់សហគ្រាសបោះផ្សាយ ត្រូវបង្ហាញដោយឡែកអំពីព័ត៌មានស្តីពីប្រាក់បំណាច់ និងលាភការផ្ទាល់ ឬប្រយោលសរុបរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ រួមទាំងអគ្គនាយក។

**ប្រការ ១៥.- ការផ្តល់ព័ត៌មានដល់អភិបាល**

អភិបាលត្រូវទទួលបានព័ត៌មានពេញលេញ គ្រប់គ្រាន់ និងទាន់ពេល មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដូចបានកំណត់ក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តជាគោលការណ៍សម្រាប់ការផ្តល់ព័ត៌មានទាំងនោះជូនក្រុមប្រឹក្សាភិបាល។

បុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយមានកាតព្វកិច្ចផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវព័ត៌មានពេញលេញ គ្រប់គ្រាន់ និងទាន់ពេល។ ករណីចាំបាច់ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អ អភិបាលម្នាក់ៗអាចតម្រូវឱ្យបុគ្គលិកជាន់ខ្ពស់ផ្តល់ព័ត៌មានបន្ថែម។

ព័ត៌មានដែលត្រូវផ្តល់ជូនសមាជិកក្រុមប្រឹក្សាភិបាល មានដូចជា សាវតាររឿង សេចក្តីពន្យល់លម្អិតពាក់ព័ន្ធនឹងបញ្ហានានាដែលត្រូវដាក់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ឯកសារផ្តល់ព័ត៌មានថតចម្លងបញ្ជាថវិកាសហគ្រាសបោះផ្សាយ ការព្យាករណ៍ និងរបាយការណ៍ហិរញ្ញវត្ថុ។ ពាក់ព័ន្ធនឹងបញ្ជាថវិកា ករណីដែលមានគំលាតណាមួយរវាងគម្រោង និងលទ្ធផលជាក់ស្តែង គឺត្រូវធ្វើការបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់។

**ប្រការ ១៦.- សិទ្ធិរបស់អភិបាល**

អភិបាលត្រូវមានសិទ្ធិជាអាទិ៍ដូចខាងក្រោម ៖

១- ទទួលបាននូវរបៀបវារៈ និងព័ត៌មានទាន់ពេល ដើម្បីត្រៀមប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

២- ទទួលបានព័ត៌មានបច្ចុប្បន្នកម្មអំពីសហគ្រាសបោះផ្សាយ។

៣- ជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងសកម្មភាព ឬការសម្រេចចិត្តណាមួយរបស់ក្រុមប្រឹក្សាភិបាល ដោយតម្រូវឱ្យកត់ត្រាឱ្យបានច្បាស់លាស់នូវការបោះឆ្នោតជំទាស់។

៤-ស្នើនូវប្រធានបទពាក់ព័ន្ធណាមួយទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

៥-ជួបជាមួយនឹងបុគ្គលិកជាន់ខ្ពស់ណាម្នាក់តាមការចាំបាច់ ដោយឈរលើភាពសមស្របទៅវិញទៅមក។

៦-ទទួលបានយោបល់លើគ្រប់ភារកិច្ច។

៧-ទទួលបានយោបល់ឯករាជ្យ ប្រសិនបើមានការស្នើសុំ។

## ប្រការ ១៧.- ភារកិច្ច និងមុខងាររបស់អភិបាល

អភិបាលត្រូវមានមុខងារ និងភារកិច្ចជាអាទិ៍ ដូចខាងក្រោម ÷

១-អនុម័តលើគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់សហគ្រាសបោះផ្សាយ។

២-ចូលរួមចំណែក និងអនុម័តលើផែនការយុទ្ធសាស្ត្រ។

៣-តាមដាននូវការអនុវត្តគោលនយោបាយ។

៤-ធានាការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

៥-ទទួលខុសត្រូវចំពោះសហគ្រាសបោះផ្សាយ។

៦-ធានាសាធនភាពហិរញ្ញវត្ថុរបស់សហគ្រាសបោះផ្សាយ តាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុបានត្រឹមត្រូវ និងការការពារទ្រព្យសកម្មរបស់ភាគហ៊ុនិក។

៧-ផ្តល់នូវភាពជាអ្នកដឹកនាំ ជួយគាំទ្រ និងលើកទឹកចិត្តដល់និយោជិត។

៨-ធានាថាក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំសហគ្រាសបោះផ្សាយ។

៩-ធានានូវការសម្រេចបានគោលដៅរបស់សហគ្រាសបោះផ្សាយ។

១០-ផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក។

## ប្រការ ១៨.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវចំពោះភាពជោគជ័យរយៈពេលវែងរបស់សហគ្រាសបោះផ្សាយ ព្រមទាំងចីរភាពនៃប្រៀបប្រកួតប្រជែង ដោយធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងការទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួន ហើយត្រូវធ្វើសកម្មភាពណាដែលបម្រើនូវផលប្រយោជន៍ ទាំងស្រុងរបស់សហគ្រាសបោះផ្សាយ និងភាគហ៊ុនិក។

ក្រុមប្រឹក្សាភិបាលត្រូវធានាថា អភិបាលទទួលការបណ្តុះបណ្តាល ដើម្បីធ្វើបច្ចុប្បន្នកម្មអំពីការវិវត្តនៃអភិបាលកិច្ចសាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលមានផលប៉ះពាល់ដល់ដំណើរការធុរកិច្ចសហគ្រាសបោះផ្សាយ។

ក្រុមប្រឹក្សាភិបាលគួរបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំនូវព័ត៌មានស្តីពីការបណ្តុះបណ្តាលអភិបាល។

**ប្រការ ១៩.- សកម្មភាពជាកាតព្វកិច្ចរបស់អភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចធ្វើការវិនិច្ឆ័យ និងធ្វើសកម្មភាពដោយឯករាជ្យ និងប្រកាន់យកជំហានសមស្របនានា ដើម្បីធានាភាពរឹងមាំនៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល។ កាតព្វកិច្ចទាំងនោះ រួមមាន ÷

១-ធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់សហគ្រាសបោះផ្សាយទាំងមូល និងភាគហ៊ុនិក។

២-ប្រើប្រាស់អំណាចឱ្យចំគោលដៅដើម្បីផលប្រយោជន៍របស់សហគ្រាសបោះផ្សាយទាំងមូល។

៣-អនុវត្តការងារដោយប្រុងប្រយ័ត្ន ប្រកបដោយភាពជំនាញ និងភាពវាងវៃ។

៤-ដោះស្រាយរាល់ទំនាស់ផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់សហគ្រាសបោះ-ផ្សាយឱ្យបានត្រឹមត្រូវ។

៥-មិនត្រូវធ្វើប្រតិបត្តិការណាដែលអភិបាលមានផលប្រយោជន៍ លើកលែងតែស្របតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័ត។

៦-មិនត្រូវកេងយកផលប្រយោជន៍ក្នុងមុខតំណែងជាអភិបាល។

៧-មិនត្រូវប្រើប្រាស់ខុសទិសដៅចំពោះព័ត៌មានដែលទទួលបានពីសហគ្រាសបោះផ្សាយ។

៨-មិនត្រូវទទួលយកអំណោយពីតតិយជន ដែលផ្តល់ឱ្យដោយសារតែមុខតំណែងជាអភិបាល។

៩-ធ្វើសេចក្តីប្រកាសអំពីទំនាស់ផលប្រយោជន៍របស់ខ្លួនដែលកើតមានពាក់ព័ន្ធនឹងសហគ្រាសបោះផ្សាយ។

**ប្រការ ២០.- ក្រមសីលធម៌**

ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តក្រមសីលធម៌ សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់សហ-គ្រាសបោះផ្សាយ ហើយត្រូវបង្ហាញជាសាធារណៈ។

**ប្រការ ២១.- ការតែងតាំងលេខាធិការរបស់សហគ្រាសបោះផ្សាយ**

ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងលេខាធិការរបស់សហគ្រាសបោះផ្សាយ ដើម្បីជាជំនួយការក្នុងការអនុវត្តការងារ។ លេខាធិការរបស់សហគ្រាសបោះផ្សាយត្រូវមានលក្ខណសម្បត្តិល្អ មានសញ្ជាតិខ្មែរ ជាបុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយ ដោយអនុវត្តការងារល្អ ស្មោះត្រង់ និងមានគោលជំហរនឹងនរពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន។

**ប្រការ ២២.- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់លេខាធិការសហគ្រាសបោះផ្សាយ**

លេខាធិការសហគ្រាសបោះផ្សាយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាភិបាល ហើយត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

១-ត្រូវបង្កើតទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់នានារបស់សហគ្រាសបោះផ្សាយ។

២-ត្រូវគាំទ្រដល់កិច្ចដំណើរការការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

៣-ត្រូវធ្វើបច្ចុប្បន្នកម្មនូវរាល់ការវិវត្តនៃច្បាប់ និងបទប្បញ្ញត្តិ ដែលអាចមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាភិបាល និងប្រតិបត្តិការរបស់សហគ្រាសបោះផ្សាយ។

៤-ត្រូវធ្វើបច្ចុប្បន្នកម្មអំពីអភិបាលកិច្ចសាជីវកម្ម និងការវិវត្តនៃការទទួលខុសត្រូវសង្គម។

៥-ត្រូវបង្កលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ដើម្បីគាំទ្រដល់ដំណើរការនៃការសម្រេចចិត្ត។

៦-ត្រូវចាត់ចែង រៀបចំ នីតិវិធី និងរក្សាទុក កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក។

## ជំពូកទី ៤

## ការជ្រើសរើស និងការបញ្ចប់តំណែងសមាជិកក្រុមប្រឹក្សាភិបាល

**ប្រការ ២៣.- ការជ្រើសតាំងអភិបាលឯករាជ្យ**

អភិបាលឯករាជ្យត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល និងបោះឆ្នោតអនុម័តដោយមហាសន្និបាតភាគហ៊ុនិក លើបេក្ខភាពយ៉ាងតិចចំនួន ០២ (ពីរ) រូប ដែលបានស្នើឡើង។

ករណីអភិបាលឯករាជ្យជាជនបរទេស អភិបាលនេះត្រូវមានបទពិសោធន៍ការងារនៅកម្ពុជាយ៉ាងហោចណាស់រយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលក្លាយជាអភិបាលឯករាជ្យរបស់សហគ្រាសបោះផ្សាយ។

**ប្រការ ២៤.- ការជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

បេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនត្រូវបានស្នើឡើង និងបោះឆ្នោតជ្រើសតាំងដោយភាគហ៊ុនិកឯកជន។ ប្រធានក្រុមប្រឹក្សាភិបាលត្រូវមាននីតិវិធី និងរៀបចំចាត់ចែង ព្រមទាំង

បង្គុលក្ខណៈងាយស្រួលដើម្បីឱ្យភាគហ៊ុនិកឯកជនស្នើបេក្ខភាព និងបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន។

**ប្រការ ២៥.- អាណត្តិរបស់អភិបាលឯករាជ្យ និងអាណត្តិរបស់អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ត្រូវមានអាណត្តិ ០៣ (បី) ឆ្នាំ។ ក្នុងករណីចាំបាច់អាណត្តិនេះ អាចបន្តបានម្តង។

**ប្រការ ២៦.- គុណវុឌ្ឍិបេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

បេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយត្រូវបំពេញលក្ខណៈវិនិច្ឆ័យជាអាទិ៍ ដូចខាងក្រោម ៖

១-និត្យានុកូលភាព ទេពកោសល្យ សមត្ថភាព និងសុចរិតភាព។

២-មានការប្តេជ្ញាចិត្តខ្ពស់ដើម្បីបម្រើផលប្រយោជន៍របស់សហគ្រាសបោះផ្សាយ និងភាគហ៊ុនិក។

៣-មានពេលវេលា ថាមពល និងការគាំទ្រដើម្បីបំពេញគ្រប់ភារកិច្ច រួមមាន ការជួបប្រជុំ និងការចូលរួមសន្និសីទ។

៤-មានលទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព។

៥-មានលទ្ធភាពអាចធ្វើការប្រកបដោយប្រសិទ្ធភាព ឆ្ពោះទៅរកគោលដៅរួមរបស់សហគ្រាសបោះផ្សាយ និងភាគហ៊ុនិក ។

៦-យល់អំពីតួនាទីរបស់ខ្លួនជាអភិបាលក្នុងធុរកិច្ច។

៧-មានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ ក្នុងវិស័យពាក់ព័ន្ធជាមួយនឹងមុខតំណែងរបស់ខ្លួន។

៨-បង្ហាញអំពីភាពជាអ្នកដឹកនាំ។

៩-មានលទ្ធភាពដើរតួនាទីយ៉ាងសកម្មនៅពេលដែលសហគ្រាសបោះផ្សាយជួបប្រទះស្ថានភាពវិកវរ។

**ប្រការ ២៧.- បេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនដែលមិនមានគុណវុឌ្ឍិក្នុងការជ្រើសតាំង**

បេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនក្នុងស្ថានភាពដូចខាងក្រោម ត្រូវចាត់ទុកថាមិនមានគុណវុឌ្ឍិសម្រាប់ការជ្រើសតាំង ៖

១-បុគ្គលនោះធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ។

២-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការមានសមត្ថកិច្ច ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ពន្ធ័នឹងការបំភាន់ ការគេបន្លំ ការក្លែងបន្លំ ការសូកប៉ាន់ ការរំលោភលើសេចក្តីទុកចិត្ត ការញុះញង់ ការសមគំនិត ឬការចូលរួមក្នុងការប្រព្រឹត្តអំពើល្មើសណាមួយផ្សេងទៀត។

៣-បុគ្គលដែលតុលាការបានប្រកាសក្ស័យធនក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ ចុងក្រោយ។

៤-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការបរទេស ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស។

៥-បុគ្គលដែលជាប់ពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ២៨.- ការបញ្ឈប់តំណែងសមាជិកក្រុមប្រឹក្សាភិបាល**

អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន មិនត្រូវបានបញ្ឈប់ពីតំណែង ឬត្រូវបានបណ្តេញចេញ ដោយគ្មានមូលហេតុត្រឹមត្រូវ និងសមស្របឡើយ និងត្រូវជូនដំណឹងជាមុនទៅអភិបាលនោះដើម្បីជ្រាបជាព័ត៌មាន។

មូលដ្ឋានសម្រាប់ការបញ្ឈប់ ឬការបណ្តេញចេញពីតំណែង រួមមាន ÷

១-ការមិនបង្ហាញព័ត៌មានពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។

២-ករណីអវត្តមាន ឬមិនបានចូលរួមទាំងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក លើសពី ៥០ (ហាសិប) ភាគរយឡើងទៅ ក្នុង ០១ (មួយ) ឆ្នាំសារពើពន្ធ ទោះបីក្នុងហេតុផលអ្វីក៏ដោយ។

៣-ករណីត្រូវបានព្យួរ បញ្ឈប់ ឬបណ្តេញចេញពីតំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត។

៤-អភិបាលឯករាជ្យបានក្លាយជាបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតរបស់សហគ្រាសបោះផ្សាយ។

៥-អភិបាលឯករាជ្យមានភាគហ៊ុនរបស់សហគ្រាសបោះផ្សាយលើសពី ០១ (មួយ) ភាគរយឡើងទៅ។

៦-ត្រូវបានផ្តន្ទាទោសពីបទល្មើសណាមួយដូចមានចែងក្នុងប្រការ ២៧ នៃ ប្រកាសនេះ។

ករណីដែលអភិបាលតំណាងភាគកម្មសាធារណៈ ស្ថិតក្នុងស្ថានភាពណាមួយក្នុងចំណោមស្ថានភាពទាំង ០៦ (ប្រាំមួយ) ខាងលើ អភិបាលឯករាជ្យ ឬអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន មានសិទ្ធិស្នើសុំបញ្ឈប់ ឬផ្លាស់ប្តូរទៅក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងសម្រេចទៅតាមនីតិវិធីច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈជាធរមាន។

## ជំពូកទី ៥

## អភិបាលឯករាជ្យ

### ប្រការ ២៩.- លក្ខខណ្ឌជាអភិបាលឯករាជ្យ

អភិបាលឯករាជ្យត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ÷

១-មិនត្រូវបានជួលដោយសហគ្រាសបោះផ្សាយ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ ចុងក្រោយ។

២-មិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដ៏សំខាន់របស់សហគ្រាសបោះផ្សាយ។

៣-មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយសហគ្រាសបោះផ្សាយ ឬជាមួយបុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយ។

៤-មិនជាប់ទាក់ទងជាមួយអង្គការ ឬសមាគមមិនស្វែងរកប្រាក់ចំណេញណាមួយដែលធ្លាប់ទទួលមូលនិធិពីសហគ្រាសបោះផ្សាយ។

៥-មិនមែនជាសមាជិកក្រុមគ្រួសាររបស់បុគ្គលដែលធ្លាប់ធ្វើជាអភិបាលឱ្យសហគ្រាសបោះផ្សាយ ឬធ្លាប់បានជួលដោយសហគ្រាសបោះផ្សាយ ឱ្យធ្វើជាអគ្គនាយក ឬបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

៦-មិនធ្លាប់ធ្វើជាសវនករ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ ឬកំពុងធ្វើជាសវនករឱ្យសហគ្រាសបោះផ្សាយ។

៧-មិនមែនជានិយោជិតរបស់សហគ្រាសបោះផ្សាយ ឬជាមន្ត្រីរាជការ។

### ប្រការ ៣០.- ការចូលរួមធ្វើការសម្រេចចិត្តរបស់អភិបាលឯករាជ្យ

អភិបាលឯករាជ្យត្រូវមានកាតព្វកិច្ចចូលរួមនៅគ្រប់ការសម្រេចចិត្តសំខាន់ៗរបស់សហគ្រាសបោះផ្សាយ ព្រមទាំងត្រូវតាមដាន ត្រួតពិនិត្យ និងគាំទ្រដល់បុគ្គលិកជាន់ខ្ពស់។ ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ថា អភិបាលឯករាជ្យមិនមានទំនាក់ទំនងសំខាន់ជាមួយបុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកដទៃទៀតដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យ ដើម្បីបម្រើផលប្រយោជន៍របស់សហគ្រាសបោះផ្សាយ និងបំពេញនូវតួនាទី ដូចខាងក្រោម ÷

១-ចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយនាំមកនូវការសម្រេចចិត្តឯករាជ្យ ទៅលើបញ្ហានានា ដូចជា យុទ្ធសាស្ត្រ គោលនយោបាយ គណនេយ្យភាព ធនធាន ការជ្រើសតាំងបុគ្គលិក និងការអនុវត្តតាមលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការដឹកនាំ។

២-ត្រូវឈានមុខគេក្នុងការដោះស្រាយ និងទប់ស្កាត់នូវទំនាស់ផលប្រយោជន៍ជាសក្ដានុពល ដែលនឹងអាចកើតឡើង។

៣-បម្រើការងារក្នុងគណៈកម្មាធិការនានា ដូចជា គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង ប្រសិនបើមាន ព្រមទាំងគណៈកម្មាធិការផ្សេងៗទៀត។

៤-ត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវការអនុវត្តរបស់សហគ្រាសបោះផ្សាយ ដើម្បីសម្រេចបានតាមគោលបំណង និងគោលដៅដែលបានឯកភាព និងតាមដានការអនុវត្តការងារ។

**ប្រការ ៣១.- ផលប្រយោជន៍របស់អភិបាលឯករាជ្យក្នុងសហគ្រាសបោះផ្សាយ**

អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ដែលនាំឱ្យរារាំងដល់ឯករាជ្យភាពរបស់ខ្លួនឡើយ។

អភិបាលឯករាជ្យ ÷

១-មិនត្រូវកាន់កាប់ភាគហ៊ុនលើសពី ០១ (មួយ) ភាគរយ នៃភាគហ៊ុនសរុបរបស់សហគ្រាសបោះផ្សាយឡើយ។

២-ត្រូវដាក់លិខិតបញ្ជាក់ថា មិនមានផលប្រយោជន៍សំខាន់ណាមួយនៅក្នុងសហគ្រាសបោះ-ផ្សាយ នៅពេលត្រូវបានតែងតាំង។

អភិបាលឯករាជ្យត្រូវបាត់បង់គុណវុឌ្ឍិ ប្រសិនបើអភិបាលឯករាជ្យរូបនោះ ឬសមាជិកគ្រួសារផ្ទាល់ ÷

១-ត្រូវបានជួលឱ្យធ្វើការ ដោយ/ជាបុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយនោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

២-កំពុងបម្រើការងារជាសវនករផ្ទៃក្នុងរបស់សហគ្រាសបោះផ្សាយ ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុនគណនេយ្យជំនាញ ដែលចូលរួមធ្វើសវនកម្មសហគ្រាសបោះផ្សាយនោះ។

៣-ធ្លាប់បម្រើការងារជាសវនករផ្ទៃក្នុងរបស់សហគ្រាសបោះផ្សាយ ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុនគណនេយ្យជំនាញ ដែលចូលរួមធ្វើសវនកម្មសហគ្រាសបោះផ្សាយនោះ ឬធ្លាប់បានធ្វើសវនកម្មផ្ទាល់លើសហគ្រាសបោះផ្សាយនោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

៤-កំពុងបម្រើការងារជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនធានាភ័ណ្ឌរង ដែលកំពុងធានាភ័ណ្ឌរងឱ្យសហគ្រាសបោះផ្សាយនោះ។

៥-ត្រូវបានជួលឱ្យធ្វើការ ដោយ/ជាបុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយ ដែលបុគ្គលិកជាន់ខ្ពស់នោះធ្លាប់ជាសមាជិកគណៈកម្មាធិការតបស្នងរបស់សហគ្រាសបោះផ្សាយនោះ។

៦-បម្រើការងារជាបុគ្គលិកជាន់ខ្ពស់របស់អង្គភាព ឬអង្គការដែលទទួលបានវិភាគទានពីសហ-គ្រាសបោះផ្សាយ។

## ជំពូកទី ៦
## គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល

**ប្រការ ៣២.- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល**

ដើម្បីធានានូវអភិបាលកិច្ចសាជីវកម្មល្អ ក្រុមប្រឹក្សាភិបាលត្រូវបង្កើតនូវគណៈកម្មាធិការមួយចំនួនដូចខាងក្រោម ÷

- គណៈកម្មាធិការសវនកម្ម

- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ករណីទ្រព្យសកម្មរបស់សហគ្រាសបោះផ្សាយមានចំនួនចាប់ពី ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល។ ចំពោះសហគ្រាសបោះផ្សាយដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល អាចបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ទៅតាមការចាំបាច់។

ដោយឡែក ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការផ្សេងទៀតទៅតាមការចាំបាច់ និងតាមការណែនាំរបស់ **គ.ម.ក.**។

**ប្រការ ៣៣.- គណៈកម្មាធិការសវនកម្ម**

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងសមាជិកដទៃទៀតត្រូវមានការយល់ដឹងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវតួនាទី និងភារកិច្ចជាអាទិ៍ ដូចខាងក្រោម ÷

- ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
- ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មខាងក្រៅ
- រាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន។

**ប្រការ ៣៤.- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវមានតួនាទីគន្លឹះ ក្នុងការគ្រប់គ្រងហានិភ័យនៅក្នុងកិច្ចប្រតិបត្តិការរបស់សហគ្រាសបោះផ្សាយ។ គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិច ០៣ (បី) រូប។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ ឬគ្រប់គ្រងហានិភ័យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល។ តួនាទី និងភារកិច្ចអាចមានជាអាទិ៍ ដូចខាងក្រោម ៖

- ការវិភាគហានិភ័យ (Risk Analysis) រួមមាន ការពិពណ៌នាហានិភ័យ (Risk Description) ការកំណត់អត្តសញ្ញាណហានិភ័យ (Risk Identification) ការប៉ាន់ស្មានអំពីហានិភ័យ (Risk Estimation)
- ការវាយតម្លៃអំពីហានិភ័យ (Risk Evaluation)
- ការរាយការណ៍អំពីហានិភ័យ (Risk Reporting)
- ការលើកវិធានការទប់ទល់ហានិភ័យ (Risk Treatment)
- ការតាមដានអំពីហានិភ័យ (Risk Monitoring)

ចំពោះសហគ្រាសបោះផ្សាយដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យអាចអនុវត្តដោយគណៈកម្មាធិការសវនកម្ម។

**ប្រការ ៣៥.- គណៈកម្មាធិការតែងតាំង**

ករណីដែលមានគណៈកម្មាធិការតែងតាំង គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលសមាជិកទាំងអស់ត្រូវតែជាអភិបាលមិនប្រតិបត្តិ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវការពិនិត្យ និងការវាយតម្លៃអំពីគុណវឌ្ឍិបេក្ខភាពដែលត្រូវតែងតាំង តាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការតែងតាំងអាចមានការទទួលខុសត្រូវផងដែរ ចំពោះការរៀបចំនីតិវិធី ឬការពិនិត្យឡើងវិញ និងការផ្តល់អនុសាសន៍ សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។

## ជំពូកទី ៧
## ការធ្វើសវនកម្ម

**ប្រការ ៣៦.- តួនាទីក្រុមប្រឹក្សាភិបាលលើផ្នែកសវនកម្មផ្ទៃក្នុង**

ក្រុមប្រឹក្សាភិបាលត្រូវមានគណនេយ្យភាពចំពោះភាគហ៊ុនិក ហើយបុគ្គលិកជាន់ខ្ពស់ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ជូនភាគហ៊ុនិក នូវការវាយតម្លៃប្រចាំឆមាស ឬការកំណត់ផ្សេងទៀតដោយ **គ.ម.ក.** ឬវិធាននៃការចុះបញ្ជីលក់មូលបត្រដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់សហគ្រាសបោះផ្សាយ។ បុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវការវាយតម្លៃប្រចាំត្រីមាសដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់សហគ្រាសបោះផ្សាយ ហើយគួរតែរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ជារៀងរាល់ខែ អំពីហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗរបស់សហគ្រាសបោះផ្សាយ។

**ប្រការ ៣៧.- ភារកិច្ចរបស់សវនករផ្ទៃក្នុង**

សហគ្រាសបោះផ្សាយត្រូវមានសវនកម្មផ្ទៃក្នុង។

សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ ជូនគណៈកម្មាធិការសវនកម្ម និងត្រូវមានការទទួលខុសត្រូវ និងភារកិច្ច ដូចខាងក្រោម ÷

១-បង្ហាញពីការវាយតម្លៃដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់សហគ្រាសបោះផ្សាយ។

២-រាយការណ៍អំពីដំណើរការធុរកិច្ចរបស់សហគ្រាសបោះផ្សាយ និងបញ្ហាជាសក្តានុពល។

៣-រក្សាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីការពារផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធ និងទ្រព្យសកម្មរបស់សហគ្រាសបោះផ្សាយ។

៤-អនុវត្តការស៊ើបអង្កេតសវនកម្មផ្ទៃក្នុងគ្របដណ្តប់ទៅលើការវាយតម្លៃពីភាពសមស្រប និងប្រសិទ្ធភាពនៃអភិបាលកិច្ច ប្រតិបត្តិការ និងប្រព័ន្ធព័ត៌មាន ដោយរាប់បញ្ចូល ទាំងការការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ។

៥-ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់ នូវរបាយការណ៍ប្រចាំឆ្នាំ ស្តីអំពីសកម្មភាពពាក់ព័ន្ធនឹងផែនការសវនកម្ម និងយុទ្ធសាស្ត្រដែលបានទទួលការយល់ព្រមពីគណៈកម្មាធិការ

សវនកម្ម។ របាយការណ៍ប្រចាំឆ្នាំនេះត្រូវរាប់បញ្ចូលទាំងការប្រឈមហានិភ័យ បញ្ហាត្រួតពិនិត្យ បញ្ហាអភិបាលកិច្ចសាជីវកម្ម និងបញ្ហាដទៃទៀតដែលស្នើដោយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។ គណៈកម្មាធិការសវនកម្មត្រូវតែផ្តល់របាយការណ៍ ឱ្យភាគហ៊ុនិករបស់សហគ្រាសបោះផ្សាយ ដែលជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការសវនកម្មត្រូវធានាថា សវនករផ្ទៃក្នុងមានសិទ្ធិទទួលបានព័ត៌មានទាំងស្រុងអំពីកំណត់ត្រាទ្រព្យ និងបុគ្គលិកពាក់ព័ន្ធនឹងសកម្មភាពសវនកម្ម និងធានាថា សកម្មភាពសវនកម្មផ្ទៃក្នុងមិនទទួលរងការជ្រៀតជ្រែកក្នុងការកំណត់ពីវិសាលភាពនៃការត្រួតពិនិត្យ ការអនុវត្តការងារ និងការបញ្ជូនលទ្ធផលនៃការត្រួតពិនិត្យ។

**ប្រការ ៣៨.- គុណវុឌ្ឍិប្រធានសវនកម្មផ្ទៃក្នុង**

ប្រធានសវនកម្មផ្ទៃក្នុងត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម ÷

១-មានសញ្ញាបត្រកម្រិតឧត្តមសិក្សាឡើងទៅដោយមានការបណ្តុះបណ្តាល ព្រមទាំងបទពិសោធន៍ខាងសវនកម្ម។

២-មានចំណេះដឹងស្តីពីបទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការរបស់សហគ្រាសបោះផ្សាយ។

៣-មានសមត្ថភាពក្នុងការដឹកនាំ និងចាត់ចែងបុគ្គលិកសវនកម្ម។

៤-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមស្តង់ដារពាក់ពន្ធ័នឹងសវនកម្ម។

៥-មានជំនាញទំនាក់ទំនងល្អក្នុងការងារ។

៦-មានភាពស្មោះត្រង់ និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ ៣៩.- ការទទួលខុសត្រូវរបស់ប្រធានសវនកម្មផ្ទៃក្នុង**

ប្រធានសវនកម្មផ្ទៃក្នុងមិនត្រូវអនុវត្តការងារដែលបង្កើតឱ្យមានទំនាស់ផលប្រយោជន៍។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ÷

១-របាយការណ៍សវនកម្មដែលធ្វើដោយសវនករផ្ទៃក្នុង ត្រូវផ្ញើទៅឱ្យគណៈកម្មាធិការសវនកម្ម ព្រមទាំងបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ និងបុគ្គលិកជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងផ្នែកដែលត្រូវបានធ្វើសវនកម្ម។

២-រាល់ការរកឃើញនានាដែលអាចមានផលប៉ះពាល់ដល់ដំណើរការរបស់សហគ្រាសបោះផ្សាយ ត្រូវបញ្ជូនទៅឱ្យគណៈកម្មាធិការសវនកម្ម។

៣-ត្រូវជួបជាមួយគណៈកម្មាធិការសវនកម្មយ៉ាងហោចណាស់ ០១ (មួយ) ដង ក្នុង ០១ (មួយ) ឆ្នាំ ដោយពុំចាំបាច់មានវត្តមានរបស់បុគ្គលិកជាន់ខ្ពស់ ។

៤-អនុវត្តការងារផ្សេងទៀតដែលគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាលប្រគល់ជូន។

**ប្រការ ៤០.- សវនកម្មខាងក្រៅ**

សវនកម្មហិរញ្ញវត្ថុត្រូវអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុនគណនេយ្យជំនាញ ដែលទទួលស្គាល់ដោយ **គ.ម.ក.**។ ក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញតាមសំណើរបស់គណៈកម្មាធិការសវនកម្ម។ អន្តរកម្មរវាងសហគ្រាសបោះផ្សាយរងសវនកម្ម និងសវនករឯករាជ្យត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការសវនកម្ម។ ដើម្បីកម្រិតហានិភ័យនៃទំនាស់ផលប្រយោជន៍ រាល់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម និងកម្រៃដែលត្រូវបង់ទៅឱ្យសវនករឯករាជ្យសម្រាប់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម ត្រូវតែទទួលបានការយល់ព្រមជាមុនពីគណៈកម្មាធិការសវនកម្ម ដោយបញ្ជាក់ច្បាស់លាស់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៤១.- ការផ្លាស់ប្ដូរក្រុមហ៊ុនគណនេយ្យជំនាញ**

សហគ្រាសបោះផ្សាយត្រូវផ្លាស់ប្ដូរក្រុមហ៊ុនគណនេយ្យជំនាញដែលធ្វើសវនកម្មក្នុងរយៈពេលមិនលើសពី ០៣ (បី) ឆ្នាំ។ សហគ្រាសបោះផ្សាយមិនត្រូវប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញដដែលឡើងវិញក្នុងរយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីកិច្ចសន្យាប្រើប្រាស់សេវាកម្មមុនត្រូវបានបញ្ចប់។ ក្នុងគោលបំណងជៀសវាងនូវទំនាស់ផលប្រយោជន៍ សហគ្រាសបោះផ្សាយមិនត្រូវប្រើប្រាស់សេវាបន្ថែមទៀតរបស់ក្រុមហ៊ុនគណនេយ្យជំនាញ ដូចជា សេវាសវនកម្មផ្ទៃក្នុង សេវាបញ្ជិកាគណនេយ្យ ការបង្កើតនិងអនុវត្តន៍ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ សេវាវាយតម្លៃ សេវាពាក់ព័ន្ធនឹងការកំណត់សោធននិវត្តន៍បុគ្គលិករបស់សហគ្រាសបោះផ្សាយ និងសេវាដទៃទៀតដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

**ប្រការ ៤២.- ការផ្អាក ឬបញ្ឈប់ក្រុមហ៊ុនគណនេយ្យជំនាញ**

រាល់ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកសេវាសវនកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញ ត្រូវមាន ការបញ្ជាក់នូវហេតុផលឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងត្រូវជូនដំណឹងជាសាធារណៈ ហើយ-

លក្ខណ៍អក្សរមក **គ.ម.ក.** ភ្លាមក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ របាយការណ៍ប្រចាំឆ្នាំត្រូវបញ្ចូលការពិភាក្សាអំពីការមិនយល់ស្របរបស់អតីតក្រុមហ៊ុនគណនេយ្យជំនាញទៅលើបញ្ហាគោលការណ៍ និងការអនុវត្តគណនេយ្យ ទៅលើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងវិសាលភាពនៃសវនកម្ម ឬលើនីតិវិធីសវនកម្មដែលមិនមានដំណោះស្រាយធ្វើឱ្យពេញចិត្តអតីតក្រុមហ៊ុនគណនេយ្យជំនាញ។

**ប្រការ ៤៣.- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់សវនករឯករាជ្យ**

សវនករឯករាជ្យត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

១-ត្រូវផ្តល់នូវទស្សនៈឯករាជ្យ និងប្រាកដនិយមថា របាយការណ៍ហិរញ្ញវត្ថុបង្ហាញត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់សហគ្រាសបោះផ្សាយ ស្របទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវអនុវត្តតាមស្តង់ដារសវនកម្មដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី ៨**

**ភាគីពាក់ព័ន្ធ**

**ប្រការ ៤៤.- ការការពារសិទ្ធិភាគីពាក់ព័ន្ធ**

ឥណទាយក បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ឬមានកិច្ចសន្យាជាមួយសហគ្រាសបោះផ្សាយ ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធរបស់សហគ្រាសបោះផ្សាយ។ រាល់ភាគីពាក់ព័ន្ធទាំងអស់របស់សហគ្រាសបោះផ្សាយត្រូវទទួលបាននូវការការពារសិទ្ធិ។ សហគ្រាសបោះផ្សាយត្រូវធានាការការពារសិទ្ធិដល់ភាគីពាក់ព័ន្ធ ជាអាទិ៍ដូចខាងក្រោម ÷

១-ត្រូវមានគោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីគាំទ្រ និងការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ។

២-ត្រូវធានាការអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

៣-មិនត្រូវធ្វេសប្រហែសចំពោះការទទួលខុសត្រូវសង្គម ដូចជា ការការពារអ្នកប្រើប្រាស់ និងការការពារបរិស្ថាន។

៤-ទទួលស្គាល់ និងការពារសិទ្ធិដាច់ចេញពីគ្នានៅពេលដែលបុគ្គលជាភាគីពាក់ព័ន្ធ និងជាភាគហ៊ុនិក។

**ប្រការ ៤៥.- ព័ត៌មាន និងការតាមដានរបស់ភាគីពាក់ព័ន្ធ**

សហគ្រាសបោះផ្សាយត្រូវផ្តល់ឱ្យភាគីពាក់ព័ន្ធ ដូចជា ឥណទាយក និងនិយោជិត នូវព័ត៌មានពាក់ព័ន្ធដែលចាំបាច់ ដើម្បីតាមដាននូវដំណើរការរបស់សហគ្រាសបោះផ្សាយ ព្រមទាំងត្រូវការពារសិទ្ធិរបស់ពួកគេ។

## ជំពូកទី ៩
## ការបង្ហាញព័ត៌មាន និងតម្លាភាព

**ប្រការ ៤៦.- ការត្រួតត្រាសហគ្រាសបោះផ្សាយតាមរយៈយន្តការទីផ្សារ**

សហគ្រាសបោះផ្សាយត្រូវមានយន្តការប្រកបដោយយុត្តិធម៌ និងមានតម្លាភាព នៅពេលដែលមានសកម្មភាពនាំឱ្យមានការផ្លាស់ប្តូរក្នុងការត្រួតត្រាសហគ្រាសបោះផ្សាយ ដូចជា ការទទួលកាន់កាប់បន្ត (Takeovers) ការរួមបញ្ចូលឬការរំលាយបញ្ចូលគ្នា (Mergers) ការទិញយក (Acquisitions) ការផ្ទេរអាជីវកម្ម (Transfers of business) ឬការជំរះបញ្ជី ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអនុក្រឹត្យស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

**ប្រការ ៤៧.- ការបង្ហាញព័ត៌មាន និងតម្លាភាព**

សហគ្រាសបោះផ្សាយត្រូវបង្ហាញព័ត៌មានទាន់ពេល និងមានប្រសិទ្ធភាពដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ និងពត៌មានផ្សេងទៀតដែលអាចមានផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគហ៊ុនិក និងភាគីពាក់ពន្ធ័ដទៃទៀត។

ព័ត៌មានសំខាន់ៗដែលទាក់ទងនឹងអភិបាលកិច្ចសាជីវកម្ម ដែលសហគ្រាសបោះផ្សាយត្រូវបង្ហាញរួមមាន ÷

១- សមាសភាពក្រុមប្រឹក្សាភិបាល រួមទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ អភិបាលឯករាជ្យ រចនាសម្ពន្ធ័ក្រុមប្រឹក្សាភិបាល រចនាសម្ពន្ធ័គ្រប់គ្រង គោលនយោបាយលើកទឹកចិត្ត គោលនយោបាយពាក់ព័ន្ធទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

២- សិទ្ធិ តួនាទី និងភារកិច្ច និងសកម្មភាពនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

៣- សកម្មភាពរបស់អភិបាលម្នាក់ៗ និងក្រុមប្រឹក្សាភិបាល។

**ប្រការ ៤៨.- ទម្រង់នៃការបង្ហាញព័ត៌មាន**

សហគ្រាសបោះផ្សាយត្រូវរៀបចំព័ត៌មានដើម្បីធ្វើការបង្ហាញក្នុងទម្រង់ងាយយល់ដោយជៀសវាងការប្រើប្រាស់ពាក្យដែលមានន័យមិនច្បាស់លាស់ និងពាក្យបច្ចេកទេសស្មុគស្មាញ។ ការបង្ហាញព័ត៌មានជាសាធារណៈត្រូវធ្វើយ៉ាងណាងាយទទួលបាន និងមានតម្លៃទាប។ ចំពោះពាក្យបច្ចេកទេសស្មុគស្មាញទាំងនោះ សហគ្រាសបោះផ្សាយត្រូវរៀបចំឱ្យមានការពន្យល់ភ្ជាប់មកជាមួយដើម្បីឱ្យសាធារណជនទូទៅបានយល់។

ករណីឯកសារដែលត្រូវបង្ហាញធ្វើឡើងជាភាសាបរទេស សហគ្រាសបោះផ្សាយត្រូវតែរៀបចំបកប្រែឯកសារទាំងនោះមកជាភាសាខ្មែរដោយភ្នាក់ងារបកប្រែដែលទទួលស្គាល់ដោយ **គ.ម.ក.**។

សហគ្រាសបោះផ្សាយត្រូវចាត់តាំងបុគ្គលិក ដើម្បីទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន រួមទាំងការរាយការណ៍ទៅទីផ្សារ និង **គ.ម.ក.** ដោយក្រុមប្រឹក្សាភិបាល និងត្រូវមានប្រពន្ធ័ត្រួតពិនិត្យព័ត៌មានផ្ទៃក្នុង (Internal Information Control System) ដែលអាចបញ្ជូនព័ត៌មានសំខាន់ៗរបស់សហគ្រាសបោះផ្សាយឱ្យបានឆាប់រហ័សដល់បុគ្គលិកនោះ។ ដើម្បីបញ្ជូនព័ត៌មានដល់សាធារណជនឱ្យបានទាន់ពេល ត្រឹមត្រូវ និងមានប្រសិទ្ធភាព បុគ្គលិកដែលទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានត្រូវមានសិទ្ធិទទួលបានព័ត៌មានភ្លាមៗរបស់សហគ្រាសបោះផ្សាយ។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**ប្រការ ៤៩.- វិធានការរដ្ឋបាល**

ការប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយនៃប្រកាសនេះ ត្រូវទទួលរងនូវវិធានការរដ្ឋបាល ដូចខាងក្រោម ÷

- ការព្រមាន
- ការណែនាំឱ្យកែតម្រូវកំហុស
- ការព្យួរ ឬការលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន
- ការព្យួរ ឬការបញ្ឈប់ការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។
- ការចាត់វិធីតិវិធីតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីព្យួរជាបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អភិបាល និង/ឬ បុគ្គលិកជាន់ខ្ពស់របស់សហគ្រាសបោះផ្សាយ។

**ប្រការ ៥៣.- បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៤.- ការអនុវត្ត**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា សហគ្រាសបោះផ្សាយ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ[illegible] ឆ្នាំ ២០១០

**គាត ឈន់**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ប្រការ ៥០.- ពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា សហគ្រាសបោះផ្សាយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល។

## ជំពូកទី ១១

## អន្តរប្បញ្ញត្តិ

**ប្រការ ៥១.- រយៈពេលនៃការរៀបចំក្រុមប្រឹក្សាភិបាលឡើងវិញ**

សហគ្រាសបោះផ្សាយត្រូវរៀបចំក្រុមប្រឹក្សាភិបាលឡើងវិញដូចបានកំណត់ក្នុងប្រការ ១១ នៃប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ ក្រោយពីចុះបញ្ជីលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

ដោយឡែក សហគ្រាសបោះផ្សាយត្រូវបំពេញឱ្យបាននូវលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មផ្សេងទៀតក្នុងរយៈពេលយ៉ាងយូរ ១៨ (ដប់ប្រាំបី) ខែ គិតពីថ្ងៃចុះបញ្ជីលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

ដោយផ្អែកលើការចាំបាច់ និងទៅតាមសំណើរបស់សហគ្រាសបោះផ្សាយ អគ្គនាយកនៃ **គ.ម.ក.** អាចផ្តល់រយៈពេលបន្ថែមសមស្របណាមួយ ដើម្បីឱ្យសហគ្រាសបោះផ្សាយអនុវត្តតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកថាខណ្ឌទាំងពីរខាងលើនៃប្រការនេះ។

## ជំពូកទី ១២

## អវសានប្បញ្ញត្តិ

**ប្រការ ៥២.- ការកែប្រែ និងការចេញគោលការណ៍ណែនាំ**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសនេះ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់សហគ្រាសបោះផ្សាយលក់មូលបត្រជាសាធារណៈ ភាគីឬបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងសាធារណជន។

# ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពីការ ដាក់ឲអនុវត្តនូវការកែប្រែ វិធាន ចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ: 00៤ /១៨ គ.ម.ក./ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវការកែប្រែ

## វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៥/១៥ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ០០៦/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ ៨ ថ្មី នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ៨ នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០៦/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១២ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម [illegible] ឧបនាយករដ្ឋមន្ត្រី
- "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
- "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០០៤/១៨

ចុះថ្ងៃទី ១៤ ខែ ៥ ឆ្នាំ២០១៨

ស្តីពី

## ការកែប្រែចំណានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

### ប្រការ ៨ ថ្មី.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក-ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ-ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ផ.ម.ក.។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក-ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ-ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយដូចខាងក្រោម÷

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (positive Operating Cash Flow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

ក្នុងអំឡុងពេល ៣ (បី) ឆ្នាំដំបូងបន្ទាប់ពីការដាក់ឱ្យអនុវត្តប្រការ ៨ ថ្មីនេះ គ.ម.ក. អាចសម្រេចលើកលែងលក្ខខណ្ឌដូចបានចែងនៅក្នុងចំណុចទី២ នៃប្រការ ៨ ថ្មីនេះ តាមការចាំបាច់។

* * *

# ឧបសម្ព័ន្ធទី៤៖ គំរូពាក្យសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
Law on Commercial Rules and Register
មាត្រា៖ ១២, ១៣, ១៧ ថ្មី, ១៨, ៤២ ថ្មី, ៤៤ ថ្មី
Articles : 12, 13, 17 new, 18, 42 new, 44 new
ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
Company Registration

គំរូ ក
Form A

## បង្កាន់ដៃទទួលតម្កល់ទុក
Receipt For Filing

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម Commercial Registration Department
ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម Commercial Registration Office
បានទទួលតម្កល់ទុកនូវសំណុំលិខិតស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
Have received the documents for commercial registration

នាមករណ៍របស់ក្រុមហ៊ុន (Name of company) ៖ ................................................
ទម្រង់ទ្រាយ (Form of company) ៖ ................................................
ទីស្នាក់ការក្រុមហ៊ុន (Registered office) ៖ ................................................

ឈ្មោះរបស់ស្ថាបនិក ☐ Name of Promoter | អភិបាល ☐ Director | អាណត្តិគាហក ☐ Proxy

### ប្រភេទនិងចំនួនឯកសារតម្កល់
Documentation

| | | | |
|---|---|---|---|
| ១- ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម<br>Registration Application Form | ☐ | ៥- ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន<br>Copy of Identity card or Passport | ☐ |
| ២- លក្ខន្តិកៈក្រុមហ៊ុន<br>Memorandum and Articles of Association | ☐ | ៦- រូបថត ៤x៦<br>Photos 4x6 cm | ☐ |
| ៣- ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម<br>Application Form for Publication in the Bulletin | ☐ | ៧- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ<br>Bank certificate of registered capital depositing | ☐ |
| ៤- សេចក្តីប្រកាសពុំមែនជាមន្ត្រីរាជការនិងពុំមានជាប់ទោសពៃរ៍<br>Declaration of non-civil servants and non-guilty | ☐ | | |

សាម៉ីជនអ្នកស្នើសុំត្រូវបំពេញសំណុំលិខិតដែលមិនទាន់គ្រប់គ្រាន់ក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយឺតចាប់ពីថ្ងៃចេញបង្កាន់ដៃនេះ។
This applicant must submit all the above documents within 15 days after the date of issuance of this receipt.

សាម៉ីជនអ្នកស្នើសុំតម្កល់ទុក សូមធានាអះអាងថា រាល់ឯកសារដែលបានយកមកតម្កល់ទុក ពិតជាត្រឹមត្រូវ មិនមានក្លែងបន្លំលើប្រការណាមួយឡើយ និងបានទទួលវិញមួយច្បាប់ដើម តម្កល់ទុកនៅក្រុមហ៊ុន ។
The applicant hereby confirm that all documents to be filed are correct complete and no false representation, and has received one copy of submitted documents for filing at the company.

ធ្វើនៅភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០
ប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម
Chief of Commercial Registration Office

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០
បានទទួលបង្កាន់ដៃ Having received the Receipt

ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

Law on Commercial Rules and Register

មាត្រា ៖ ១២, ១៣, ១៧ ថ្មី, ១៨, ៤២ ថ្មី, ៤៤ ថ្មី

Articles : 12, 13, 17 new, 18, 42 new, 44 new

ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

Company Registration

គំរូ ក.១

Form A.1

## ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម

## Application for Company Registration

តម្កល់ទុកនៅថ្ងៃទី......ខែ......ឆ្នាំ......នៅម៉ោង ......

Filed on ... at ...

លេខចុះក្នុងបញ្ជីកាលប្បវត្តិ ៖ ......

Order in chronological registration number

លេខចុះក្នុងបញ្ជីវិភាគ ៖ ......

Order in analytical registration number

នាមត្រកូលនិងនាមខ្លួន ៖ ......

Name and Surname

សញ្ជាតិ ៖ ......

Nationality

អាសយដ្ឋានបច្ចុប្បន្ន ៖ ......

Current address

អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនលេខ៖ ...... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ......

Identity Card/Passport number ... Issued on

ធ្វើក្នុងនាមជា ៖ ស្ថាបនិក ☐ អភិបាល ☐ អាណត្តិគាហក ☐

In the name of: Promoter ☐ Director ☐ Proxy ☐

នៃក្រុមហ៊ុន ៖ ......

of the company

លិខិតប្រគល់សិទ្ធិចុះថ្ងៃទី ខែ ឆ្នាំ (បើជាអាណត្តិគាហក) ៖ ......

Date of Issuing Power of Attorney (If Proxy)

សុំចុះឈ្មោះក្រុមហ៊ុនដូចបានពោលខាងលើនៅក្នុងបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយធ្វើសេចក្តីបញ្ជាក់

Request for registering the above company in the commercial Register of the Ministry of Commerce with following

ដែលជាការអះអាងជាត្រឹមត្រូវ ដូចតទៅ ៖

due declarations :

១- នាមករណ៍ក្រុមហ៊ុន ៖ ......

Company's Name

សញ្ជាតិក្រុមហ៊ុន ៖ ......

Company's Nationality

គំរូហត្ថលេខារបស់អ្នកស្នើសុំ ៖ ......

Specimen Signature of the applicant

គំរូត្រារបស់ក្រុមហ៊ុន ៖ ......

Specimen Seal of the company

២- អភិបាល ☐

Director

| ល.រ<br>No. | នាមត្រកូល និង នាមខ្លួន<br>Name and Surname | សញ្ជាតិ<br>Nationality | លេខ និង កាលបរិច្ឆេទនៃ អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន<br>Identity card or passport number<br>Issued and expiry date | អាសយដ្ឋាន<br>Address | ហត្ថលេខាគំរូ<br>Sample of Signature |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| តតិយជនមានអំណាចចុះហត្ថលេខាទទួលខុសត្រូវជូនក្រុមហ៊ុន<br>Third person authorized to sign on behalf of the company | | | | | |
| ១ | | | | | |
| ២ | | | | | |

៣- កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន ៖

Business Objective

<u>សកម្មភាពធ្វើអាជីវកម្មចម្បង</u> ៖ ................................................................

Main activities

................................................................

<u>សកម្មភាពបន្ទាប់បន្សំ</u> ៖ អាហរណកម្ម នីហរណកម្ម ☐ ទិញ-លក់ក្នុងប្រទេស ☐ ហាង ☐ ឃ្លាំងទុក ☐

Secondary Objective : Import Export, Domestic Sell-Purchase, Shop, Warehouse

សេវាកម្ម ☐ អាជីវកម្មកសិកម្ម ☐ រ៉ែ ☐ រោងចក្រ ☐ សិប្បកម្ម ☐ ការដំឡើង ☐ ការជួសជុល ☐ សំណង់ ☐

Service, Agriculture, Mine, Factory, Handicraft, Installation, Repairing, Construction

ដឹកជញ្ជូន ☐ ទេសចរណ៍ ☐ សណ្ឋាគារ ☐ ភោជនីយដ្ឋាន ☐ ក្លឹបកម្សាន្ត ☐

Transportation, Tourism, Hotel, Restaurant, Resort

ផ្សេងទៀត ៖ (បញ្ជាក់) ................................................................

Others (List)

៤- ទ្រង់ទ្រាយក្រុមហ៊ុន (Form of Company)

- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ □ មានកម្រិត □ — កាលបរិច្ឆេទចុះបញ្ជី ៖
  General Partnership — Limited — Date of registration
- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត □ — កាលបរិច្ឆេទរំលាយ ៖
  Private Limited Company — Date of dissolution
- សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត □
  Single Member Private Limited Company
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត □
  Public Limited Company
- គ្រឹះស្ថានសាធារណៈ □
  Public Institute
- ក្រុមហ៊ុនរដ្ឋ □
  State Enterprise
- ក្រុមហ៊ុនចម្រុះ □
  Joint Venture

៥- អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ៖ លេខ.............. ផ្លូវ.............. ឃុំ/សង្កាត់..............
Address of Registered Office — No. — Street — Commune
ស្រុក/ខណ្ឌ.............. ខេត្ត/ក្រុង..............
District — Province/City
ទូរស័ព្ទ (Tel).............. ទូរសារ (Fax)..............

៦- សាខានៅកម្ពុជា ៖ មាន □ គ្មាន □
Branches in Cambodia — Yes — No
អាសយដ្ឋានសាខា (Address) ៖ .............. ទូរស័ព្ទ (Tel)..............

៧- សាខាឬទីភ្នាក់ងារនៅបរទេស ៖ មាន □ គ្មាន □
Foreign branch or agent — Yes — No
អាសយដ្ឋានសាខា (Address) ៖ .............. ទូរស័ព្ទ (Tel)..............

៨- ចំនួនទឹកប្រាក់នៃដើមទុនចុះបញ្ជី ៖ ..............
Amount of registered capital
ជាអក្សរ (In words) ៖ ..............

៩- ប្រភពដើមនៃដើមទុនចុះបញ្ជី ៖
Source of registered capital

- ភាគទុនជាសាច់ប្រាក់ ៖ មាន □ គ្មាន □ តម្លៃ ៖ ..............
  Contribution in Cash — Yes — No — Amount
- ភាគទុនជាវត្ថុ ៖ មាន □ គ្មាន □ តម្លៃ ៖ ..............
  Contribution in Kind — Yes — No — Amount
- ភាគទុនខាងជំនាញ ៖ មាន □ គ្មាន □ តម្លៃ ៖ ..............
  Contribution in Expertise — Yes — No — Amount

១០- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជី ៖ លេខ.............. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ..........
Bank Certificate of Registered Capital Depositing — No. — Date
តម្កល់នៅធនាគារ ៖ ..............
Deposited at the Bank

១១- ភាគទុនរបស់សមាជិក □ សហកម្មសិទ្ធិករ □ ហត្ថលេខា

Contribution of members Partners Signature

១- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

២- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៣- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៤- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៥- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៦- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៧- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៨- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

៩- លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

១០-លោក-លោកស្រី................................................ដាក់ភាគទុនចំនួន ..................................

Mr./Mrs. Contribution

១២- ប្រកាសនីយបត្រតក្កកម្មដែលធ្វើអាជីវកម្ម (Patent) ៖ មាន Yes □ គ្មាន No □ ..................................

(បញ្ជាក់) List : ..........................................................................................

១៣- សញ្ញាសម្គាល់ពាណិជ្ជកម្ម ឬសញ្ញាផលិតកម្ម ដែលបានតម្កល់ទុកនិងប្រើប្រាស់ ៖ មាន Yes □ គ្មាន No □

Trade mark or Production mark filled and used

(បញ្ជាក់) ៖ លេខតម្កល់ទុក Filing Number : ................ ថ្ងៃទី (Date) ........ ខែ ........ ឆ្នាំ ២០

ទីកន្លែងតម្កល់ទុក Place of Filing : ..........................................................

ធ្វើនៅភ្នំពេញ (Phnom Penh) ថ្ងៃទី (Date)........ ខែ........ ឆ្នាំ ២០

ហត្ថលេខា

Signature

ប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ដែលចុះហត្ថលេខាខាងក្រោម

The Chief of Commercial Registration Office with the signature below

បញ្ជាក់ថាសេចក្តីដែលមានចែងក្នុងពាក្យសុំនេះត្រូវបានចុះបញ្ជីពាណិជ្ជកម្ម

certify that the statement in this application is registered in the analytical

..........................................................

company registration under the number of

ចុះថ្ងៃទី (Date) ..........................................................

ធ្វើនៅភ្នំពេញ (Phnom Penh) ថ្ងៃទី (Date) ខែ ឆ្នាំ ២០

ប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម

Chief of Commercial Registration Office

**ច្បាប់ស្តីពី វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម**
Law on the Commercial Rules and Registration
**មាត្រា ៖ ១២, ១៣, ១៧, ១៨, ៤២, ៤៤**
Article: 12, 13, 17, 18, 42, 44
**ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម**
COMPANY REGISTRATION

**គំរូ ក.២**
**Form A.2**

ក្រុមហ៊ុន Company..................................................................................................

**ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម**
Application for Publication in the Bulletin
អភិបាលក្រុមហ៊ុន The Director of.............................................
សូមជម្រាបមក Hereby inform
លោកប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម
សូមលោកនាយកមេត្តាចាត់ចែងចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម
We would like you to organize publication in The Weekly Business Roundup
នូវសេចក្តីប្រកាសផ្សាយស្តីពីការបង្កើតក្រុមហ៊ុន..................................................................
of the setting up of company

**D/STI**

អត្ថបទនៃសេចក្តីប្រកាសមានដូចខាងក្រោម The publication will be as follow

**សេចក្តីប្រកាសស្តីពីការបង្កើតក្រុមហ៊ុន** Publication of Setting up of Company

នាមករណ៍ក្រុមហ៊ុន :..................................................................................................
Name of Company: ..................................................................................................
ទម្រង់ (Form of Company): ..................................................................................................
ទីស្នាក់ការលេខ (Address): ....................ផ្លូវ....................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ..........................
ខេត្ត/ក្រុង..............................លេខទូរស័ព្ទ..........................អ៊ីម៉ែល......................................
កម្មវត្ថុអាជីវកម្មសង្ខេប :..................................................................................................
Objective of Business in brief: ..................................................................................................
ថេរវេលា (Duration): គិតចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម (From the date of registration) ចំនួន........................ឆ្នាំ
ចំនួនដើមទុនចុះបញ្ជី (Registered Capital): ..............................បែងចែកជា (Divided into)...................ភាគហ៊ុន (Shares)
ភាគហ៊ុននីមួយៗមានតម្លៃ (Value of Share): ..................................................................................................
ឈ្មោះរបស់អភិបាល (Name of Director): ..............................មុខរបរ (Occupation)..............សញ្ជាតិ (Nationality)........
អាសយដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ.................ផ្លូវ............ ឃុំ/សង្កាត់...................... ស្រុក/ខណ្ឌ ..............................
Current Address ខេត្ត/ក្រុង ........................ លេខទូរស័ព្ទ...................... អ៊ីម៉ែល..........................................
ក្រុមហ៊ុននឹងត្រូវបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។
The Company will be registered in the commercial registration at the Ministry of Commerce.
លោក/លោកស្រី (Mr. /Mrs.)..................................................................................

សូមលោកនាយកទទួលនូវការគោរពនិងរាប់អានអំពីខ្ញុំ ។
Please, Dear Director, Accept my highest consideration
អភិបាលក្រុមហ៊ុន
Director of Company

បានទទួលនិងយល់ព្រមចុះផ្សាយ (Received and Agreed to publish)
ក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម លេខ No....................................
ចុះផ្សាយ ថ្ងៃទី...................ខែ ...................ឆ្នាំ.....................
រាជធានីភ្នំពេញ. ថ្ងៃទី................ខែ...............ឆ្នាំ........
**ប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម**

| ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម<br>Law on Commercial Rules and Register<br>មាត្រា ៖ ១២, ១៣, ១៧ ថ្មី, ១៨, ៤២ ថ្មី, ៤៤ ថ្មី<br>Articles : 12, 13, 17 new, 18, 42 new, 44 new<br>ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម<br>Company Registration |
|---|

| គំរូ ក.៣<br>Form A.3 |
|---|

# សេចក្តីប្រកាសពុំមែនជាមន្ត្រីរាជការ និងពុំមានជាប់ទោសពៃរ៍
Declaration of non-civil servant and non-guilty

ខ្ញុំបាទ-នាងខ្ញុំ ជាអភិបាលនៃក្រុមហ៊ុន ..................................................................
We, as the directors of the Company
ដែលមានឈ្មោះដូចខាងក្រោម ៖
which name below

| ល.រ<br>No. | ឈ្មោះ<br>Name | ល.រ<br>No. | ឈ្មោះ<br>Name |
|---|---|---|---|
| ១ | លោក-លោកស្រី..............................<br>Mr./Mrs.<br>អាយុ..........ឆ្នាំ មុខរបរ..............................<br>Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន<br>Identity Card/Passport<br>លេខ....................ចុះថ្ងៃទី....................<br>Number Issued on | ៤ | លោក-លោកស្រី..............................<br>Mr./Mrs.<br>អាយុ..........ឆ្នាំ មុខរបរ..............................<br>Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន<br>Identity Card/Passport<br>លេខ....................ចុះថ្ងៃទី....................<br>Number Issued on |
| ២ | លោក-លោកស្រី..............................<br>Mr./Mrs.<br>អាយុ..........ឆ្នាំ មុខរបរ..............................<br>Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន<br>Identity Card/Passport<br>លេខ....................ចុះថ្ងៃទី....................<br>Number Issued on | ៥ | លោក-លោកស្រី..............................<br>Mr./Mrs.<br>អាយុ..........ឆ្នាំ មុខរបរ..............................<br>Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន<br>Identity Card/Passport<br>លេខ....................ចុះថ្ងៃទី....................<br>Number Issued on |
| ៣ | លោក-លោកស្រី..............................<br>Mr./Mrs.<br>អាយុ..........ឆ្នាំ មុខរបរ..............................<br>Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន<br>Identity Card/Passport<br>លេខ....................ចុះថ្ងៃទី....................<br>Number Issued on | ៦ | លោក-លោកស្រី..............................<br>Mr./Mrs.<br>អាយុ..........ឆ្នាំ មុខរបរ..............................<br>Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន<br>Identity Card/Passport<br>លេខ....................ចុះថ្ងៃទី....................<br>Number Issued on |

## សូមប្រកាស និងអះអាងចំពោះមុខច្បាប់ថា៖

Hereby have the honor to declare that :

ខ្ញុំបាទ-នាងខ្ញុំ ពុំមែនជាមន្ត្រីរាជការបម្រើក្នុងក្រសួង ឬស្ថាប័នរដ្ឋណាមួយឡើយ ហើយមិនដែលត្រូវបានជាប់ទោសពៃរ៍
We are not the civil servant in any State Ministry or Institution and have never been convicted for criminal, civil or
ណាមួយទោះបីទោសព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាលក្តី ដែលទាក់ទងដល់ការហាមឃាត់សកម្មភាពវិស័យពាណិជ្ជកម្មរបស់
administration liabilities related to our business activities or prohibited by law from doing business or being the manager of any
ខ្ញុំបាទ-នាងខ្ញុំឬហាមឃាត់ខ្ញុំបាទ-នាងខ្ញុំ ក្នុងនាទីជាអ្នកចាត់ចែងគ្រប់គ្រងសហគ្រាសពាណិជ្ជកម្មណាមួយឡើយ ។
commercial enterprise.

ក្នុងករណី ដែលសេចក្តីប្រកាសនេះមិនត្រឹមត្រូវតាមការពិត ខ្ញុំបាទ-នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងនៅចំពោះមុខច្បាប់ជាធរមាន ។

In the case there is any falsification we will be responsible infront of the applicable laws.

ធ្វើឡើងចំនួន .......... ច្បាប់ដើម នៅ........................ ថ្ងៃទី.......... ខែ.......... ឆ្នាំ ២០

ហត្ថលេខា

**ពាក្យស្នើសុំចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម**
Application for Publication in the Bulletin
អភិបាលក្រុមហ៊ុន The Director of................................................
សូមជម្រាបមក Hereby inform
លោកប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម
សូមលោកនាយកមេត្តាចាត់ចែងចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម
We would like you to organize publication in The Weekly Business Roundup

| គំរូ ក ៣ |
| --- |
| Form B.3 |

D/STI

**សេចក្តីប្រកាស**
**ស្តីពី**
**ការរំលាយក្រុមហ៊ុន**

ក្រុមហ៊ុន :...............................................................(ស្ថិតក្នុងការជំរះបញ្ជី)
:...............................................................
ទុនចំរាយ : ...............................................................
ដើមទុន : ...............................................................
ទីស្នាក់ការ :ផ្ទះលេខ ..........ផ្លូវ........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ..........ខេត្ត/ក្រុង ..........
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម:.............................. ចុះថ្ងៃទី ..............ខែ ..................ឆ្នាំ ..........
ប្រកាសរំលាយមុនកាលកំណត់: ចាប់ពីថ្ងៃទី ...........ខែ ..........ឆ្នាំ ...............................
សេចក្តីរំលាយ :អង្គប្រជុំថ្ងៃទី ........ ខែ ................ឆ្នាំ ...............................
អ្នកជំរះបញ្ជី :លោក/លោកស្រី ...............................................
:អាសយដ្ឋានផ្ទះលេខ.....ផ្លូវ .....ឃុំ/សង្កាត់.........ស្រុក/ខណ្ឌ .............ខេត្ត/ក្រុង ........
ទីកន្លែងជំរះបញ្ជី :ទីស្នាក់ការក្រុមហ៊ុន ...............................................
អាសយដ្ឋានផ្ទះលេខ........ផ្លូវ ..... ឃុំ/សង្កាត់ ........ស្រុក/ខណ្ឌ ........ .ខេត្ត/ក្រុង .........
ទីកន្លែងទាក់ទងព័ត៌មាន :ទីស្នាក់ការក្រុមហ៊ុន...............................................
អាសយដ្ឋានផ្ទះលេខ ........ផ្លូវ ........ ឃុំ/សង្កាត់ ........ស្រុក/ខណ្ឌ .......... ខេត្ត/ក្រុង ..........
លេខទូរស័ព្ទ.....................អ៊ីម៉េល...............................................
រាល់សំណុំលិខិតដែលទាក់ទងនឹងការរំលាយក្រុមហ៊ុននិងការជំរះបញ្ជីនឹងត្រូវយកទៅតំកល់ទុក
នៅក្រសួងពាណិជ្ជកម្ម ។

ធ្វើនៅ...............ថ្ងៃទី ខែ ឆ្នាំ ២០
**អ្នកជំរះបញ្ជី**

សូមលោកនាយកទទួលនូវការគោរពនិងរាប់អានអំពីខ្ញុំ ។
Please, Dear Director, Accept my highest consideration
អភិបាលក្រុមហ៊ុន
Director of Company

បានទទួលនិងយល់ព្រមចុះផ្សាយ(Received and Agreed to publish)
ក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម លេខ No..............................
ចេញផ្សាយ ថ្ងៃទី...............ខែ ................ឆ្នាំ......................
រាជធានីភ្នំពេញ. ថ្ងៃទី...............ខែ..............ឆ្នាំ...........
**ប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម**

ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
Law on the Commercial Rules and Registration
មាត្រា : ១២, ១៣, ១៧, ១៨, ៤២, ៤៤
Article :12, 13, 17, 18, 42, 44
ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
COMPANY REGISTRATION

លំ ក.២
Form A.2

# ប្រតិទេយ្យនៃអនុលោមភាព
Statement of Conformity

យើងខ្ញុំមានរាយនាមដូចខាងក្រោម :
We are listing below

១-លោក-អ្នកស្រី [illegible] មុខរបរ [illegible] សញ្ជាតិ [illegible] អាស័យដ្ឋាន [illegible] 325 [illegible]
Mr /Ms Occupation Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន N.0102632 ចុះថ្ងៃទី 14 ខែ 01 ឆ្នាំ 00
Identity and Passport Issued on

២-លោក-អ្នកស្រី John Brins[illegible] មុខរបរ [illegible] សញ្ជាតិ [illegible] អាស័យដ្ឋាន [illegible]
Mr /Ms Occupation Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន 740099864 ចុះថ្ងៃទី 02 ខែ [illegible] ឆ្នាំ 97
Identity and Passport Issued on

៣-លោក-អ្នកស្រី Peter Kool មុខរបរ [illegible] សញ្ជាតិ NEDERLAND[illegible] អាស័យដ្ឋាន [illegible] NETHERLANDS
Mr /Ms Occupation Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន N.60720570 ចុះថ្ងៃទី 07 ខែ 1 ឆ្នាំ 98
Identity and Passport Issued on

៤-លោក-អ្នកស្រី Rauf Khala[illegible] មុខរបរ [illegible] សញ្ជាតិ [illegible] អាស័យដ្ឋាន [illegible] (LIVERPOO[illegible]
Mr /Ms Occupation Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន 5293122640.3 ចុះថ្ងៃទី [illegible] ខែ 03 ឆ្នាំ 98
Identity and Passport Issued on

៥-លោក-អ្នកស្រី Emile Hubert Josephus Grof មុខរបរ [illegible] សញ្ជាតិ NEDERLAND[illegible] អាស័យដ្ឋាន [illegible] NETHERLANDS
Mr /Ms Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន Z00175410 ចុះថ្ងៃទី 9 ខែ 1 ឆ្នាំ 96
Identity and Passport Issued on

៦-លោក-អ្នកស្រី Jean Gilson មុខរបរ [illegible] សញ្ជាតិ [illegible] អាស័យដ្ឋាន [illegible]
Mr /Ms Occupation Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន 27206412 ចុះថ្ងៃទី 18 ខែ [illegible] ឆ្នាំ 92
Identity and Passport Issued on

៧-លោក-អ្នកស្រី Jacoba Helena Maria Barendse មុខរបរ [illegible] សញ្ជាតិ NEDERLAND[illegible] អាស័យដ្ឋាន [illegible] NETHERLANDS
Mr /Ms Occupation Nationality Address
អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន N.67035693 ចុះថ្ងៃទី 5 ខែ [illegible] ឆ្នាំ 96
Identity and Passport Issued on

៨-លោក-អ្នកស្រី [illegible] មុខរបរ [illegible] សញ្ជាតិ [illegible] អាស័យដ្ឋាន 209 [illegible]
Mr /Ms Occupation Nationality Address
[illegible] អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន 374270[illegible] ចុះថ្ងៃទី 4 ខែ 4 ឆ្នាំ 92
Identity and Passport Issued on

9 - [illegible]

[illegible] N 0064875 [illegible] 03-2-95

# ឧបសម្ព័ន្ធទី៥៖ គំរូលក្ខន្តិកៈ ក្រុមហ៊ុន និងការណែនាំ (ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)

# ឧបសម្ព័ន្ធ ១
# គំរូលក្ខន្តិកៈក្រុមហ៊ុន និងការណែនាំ
# (ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)

**ប្រការ ១** : នាមករណ៍ក្រុមហ៊ុន......................................................................

**ប្រការ ២** : កម្មវត្ថុអាជីវកម្ម............................................................................

ISIC code : សូមជ្រើសរើស កូដ ដែលបញ្ជាក់ពីសកម្មភាពចំបងរបស់ក្រុមហ៊ុន

.............................................................................................................

.............................................................................................................

.............................................................................................................

ប្រសិនបើម្ចាស់ហ៊ុនដាក់ការរឹតត្បិតណាមួយ ទៅលើសកម្មភាពអាជីវកម្ម សូមបញ្ជាក់ខាងក្រោម :

.............................................................................................................

.............................................................................................................

.............................................................................................................

**ប្រការ ៣** : អាសយដ្ឋានទីស្នាក់ការក្រុមហ៊ុនចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា :

.............................................................................................................

អាសយដ្ឋានទំនាក់ទំនងរបស់ក្រុមហ៊ុនចុះបញ្ជី បើមានផ្សេង......................................

ឈ្មោះភ្នាក់ងារចុះបញ្ជីរបស់ក្រុមហ៊ុន.......................................................................

**ប្រការ ៤** : ថិរវេលានៃសកម្មភាពក្រុមហ៊ុនគឺ មានរយៈពេល...................................

**ប្រការ ៥** : ដើមទុន និងភាគហ៊ុនដែលអនុញ្ញាត

ដើមទុនរបស់ក្រុមហ៊ុនគឺ.........................................................................រៀល ។

ដើមទុននេះត្រូវបានបែងចែកជា..........................................................ភាគហ៊ុន

ដែលភាគហ៊ុននីមួយៗ មានតម្លៃចារឹក ......................................................រៀល ។

**ប្រការ ៦** : ក្នុងករណីប្រភេទភាគហ៊ុនបន្ថែមត្រូវបានអនុញ្ញាតបោះចេញ មានប្រភេទ ចំនួន និងតម្លៃចារឹក ។ សូមបញ្ជាក់ពី សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទនៃភាគហ៊ុននីមួយៗ ។ ប្រសិនបើមានភាគហ៊ុនតែមួយ ប្រភេទ ត្រូវបានបោះចេញ សូមបញ្ជាក់ថា "**មិនមាន**"

............................................................................................................................

**ប្រការ ៧** : ក្នុងករណីមានការរឹតត្បិតពិសេសណាមួយទៅលើការផ្ទេរភាគហ៊ុន ដែល បានបញ្ជាក់ដោយម្ចាស់ហ៊ុន សូមចែង អោយបានច្បាស់ ។ ប្រសិនបើគ្មានការរឹតត្បិតទេ សូមបញ្ជាក់ថា "**គ្មាន**"

............................................................................................................................

ប្រការ ៨ : ក្នុងករណីមានការរឹតត្បិតពិសេសណាមួយទៅលើការប្រកាស និងការបែង ចែកភាគលាភ ដែលបានបញ្ជាក់ដោយ ម្ចាស់ហ៊ុន សូមចែង អោយបានច្បាស់ ។ ប្រសិន បើគ្មានការរឹតត្បិតទេ សូមបញ្ជាក់ថា "**គ្មាន**"

............................................................................................................................

**ប្រការ ៩** : អភិបាលក្រុមហ៊ុនត្រូវបានតម្រូវអោយផ្តល់អោយម្ចាស់ហ៊ុននូវទិន្នន័យ ហិរញ្ញវត្ថុ និងរបាយការណ៍សវនករ និងព័ត៌មានបន្ថែមទៀត ទាក់ទិននឹងស្ថានភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលប្រតិបត្តិការក្រុមហ៊ុន ។

**ប្រការ ១០** : ក្រោយពេលឯកភាពអោយធ្វើការជម្រះបញ្ជី និងរំលាយក្រុមហ៊ុនដោយ សេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន ក្រុមហ៊ុនត្រូវផ្ញើនូវសេចក្តីថ្លែងហេតុដើម្បីរំលាយ ក្រុមហ៊ុន ទៅអភិបាលក្រុមហ៊ុន ។

មរណភាព ឬអសមត្ថភាពរបស់ម្ចាស់ហ៊ុនណាម្នាក់មិនបណ្តាលអោយមានការ រំលាយក្រុមហ៊ុនឡើយ ។ ក្រុមហ៊ុនអាចបន្ត សកម្មភាពរបស់ខ្លួនរវាងកម្មសិទ្ធិករ ស្របច្បាប់ ឬទាយាទរបស់ម្ចាស់ហ៊ុនដែលទទួលមរណភាព ឬអសមត្ថភាព និងម្ចាស់ហ៊ុន ដទៃទៀត ។

**ប្រការ ១១** : បុគ្គលដែលមានឈ្មោះ និងអាសយដ្ឋានដូចខាងក្រោមត្រូវបានតែងតាំងជាអភិបាលក្រុមហ៊ុន សម្រាប់អាណតិកំណត់ ដូចខាងក្រោម :

| ឈ្មោះអភិបាល/អាសយដ្ឋាន | អាណត្តិ |
|---|---|
| ................................................ | ........................................ |
| ................................................ | ........................................ |
| ................................................ | ........................................ |
| ................................................ | ........................................ |

**ប្រការ ១២** : យើងទាំងអស់គ្នាដែលមានឈ្មោះ អាជីព សញ្ជាតិ អាសយដ្ឋាន និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដូចមាននៅក្នុងបញ្ជីខាងក្រោម បានសម្រេចចិត្តបង្កើតក្រុមហ៊ុន ដូចមានចែងក្នុងលក្ខន្តិកៈនេះ ហើយយើងទាំងអស់គ្នាយល់ ព្រមទទួលយកចំនួនភាគហ៊ុននៅក្នុងដើមទុនរបស់ក្រុមហ៊ុនដូចបានបញ្ជាក់ :

| ឈ្មោះរបស់ម្ចាស់ហ៊ុន/អាជីព/សញ្ជាតិ/អាសយដ្ឋាន/អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងកាលបរិច្ឆេទ | ចំណែក |
|---|---|
| ...................................................................................... | .................. |
| ...................................................................................... | .................. |
| ...................................................................................... | .................. |

តាមរយៈការចុះហត្ថលេខាលើលក្ខន្តិកៈ ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ ទទួលស្គាល់កាតព្វកិច្ច ដើម្បីអនុវត្តតាម វិធានគ្រប់គ្រង ក្រុមហ៊ុន ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចកែប្រែលក្ខន្តិកៈរបស់ខ្លួន ផ្អែកតាមសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន ។ ក្រោយពេលបង្កើតក្រុមហ៊ុន ការបោះពុម្ពផ្សាយ នូវការចុះបញ្ជី ក្រុមហ៊ុនត្រូវធ្វើឡើងក្នុងរាជកិច្ច និងព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ។

| ហត្ថលេខាម្ចាស់ហ៊ុន | កាលបរិច្ឆេទ |
|---|---|
| ................................................ | ........................................ |
| ................................................ | ........................................ |
| ................................................ | ........................................ |

## សេចក្ដីណែនាំ

គំរូលក្ខន្តិកៈនេះនឹងត្រូវយកមកប្រើសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ។ ចំណុចបន្ថែមនានាអាចត្រូវ បានបញ្ចូលក្នុងលក្ខន្តិកៈក្រុមហ៊ុន អាស្រ័យលើចំណង់ចំណូល ចិត្តរបស់ម្ចាស់ហ៊ុន ។ គំរូនេះផ្ដល់អោយនូវខ្លឹមសារមួយចំនួនតូចដែលត្រូវបានតម្រូវសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត :

(ក) ក្រុមហ៊ុនអាចមានម្ចាស់ហ៊ុនពី ២ ទៅ ៣០ នាក់ ។ ប៉ុន្តែ បុគ្គលម្នាក់អាចបង្កើតក្រុមហ៊ុនមួយបាន ហៅថា សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។ លក្ខខណ្ឌតម្រូវសម្រាប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត គឺមានលក្ខណៈដូចគ្នាជាមួយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែទំនាក់ទំនងរវាងម្ចាស់ហ៊ុន ចេញ ។

(ខ) ក្រុមហ៊ុនមិនអាចបោះចេញភាគហ៊ុន ឬមូលបត្រអោយទៅសាធារណៈជនទូទៅឡើយ ប៉ុន្តែអាចផ្ដល់ភាគហ៊ុន ឬមូលបត្រទាំងនោះអោយទៅម្ចាស់ហ៊ុន សមាជិកក្រុមគ្រួសារ និងអ្នកគ្រប់គ្រង ។

(គ) ក្រុមហ៊ុនអាចមានការរឹតត្បិតមួយ ឬច្រើនលើការផ្ទេរប្រភេទភាគហ៊ុននីមួយៗរបស់ខ្លួន ។

**ប្រការ ១ :** នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបញ្ចូលពាក្យ "ក្រុមហ៊ុនឯកជនទទួលខុស ត្រូវមានកម្រិត ។ នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ។ នាមករណ៍ក្រុមហ៊ុនត្រូវសរសេរ ជាភាសាខ្មែរ ហើយការបកប្រែនាមករណ៍ពីភាសាមួយទៅ ភាសាមួយទៀត ត្រូវហាមឃាត់ ។

**ប្រការ ២ :** សូមមើលតារាងក្នុងឧបសម្ព័ន្ធ និងជ្រើសរើសអ្វីដែលសមហេតុផលបំផុត ។ ជ្រើសរើសកូដ ដែលបញ្ជាក់ពី សកម្មភាពចំបងរបស់ក្រុមហ៊ុន ។

**ប្រការ ៣ :** ផ្ដល់អាសយដ្ឋានស្នាក់ការក្រុមហ៊ុនពិតប្រាកដ និងអាសយដ្ឋាន ទំនាក់ទំនង ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្ដូរ ទីតាំងរបស់ទីស្នាក់ការចុះបញ្ជី ត្រូវផ្ញើទៅមន្ត្រីទទួល

បន្ទុក គ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ ។ ភ្នាក់ងារចុះបញ្ជីសំដៅលើរូបវន្តបុគ្គលដែលមានសមត្ថភាពផ្លូវច្បាប់ ជាបុគ្គល ដែលមានសិទ្ធិអំណាចទទួលលិខិតស្នាម និងឯកសារផ្លូវការ រួមមានដូចជាដីកាកោះ និងដីកាកោះសាក្សី ពីតុលាការ តាងនាម អោយក្រុមហ៊ុន ។ ភ្នាក់ងារចុះបញ្ជីរបស់ក្រុមហ៊ុន ត្រូវតែជាបុគ្គលដែលមាន សមត្ថភាពតាមផ្លូវច្បាប់ ដែលអនុញ្ញាត អោយទទួលនូវ លិខិតស្នាម ឬឯកសារផ្លូវការ រួមមាន ដីកា និងការកោះអញ្ជើញរបស់តុលាការក្នុងនាមក្រុមហ៊ុន ។

**ប្រការ ៤ :** រយៈពេលនៃក្រុមហ៊ុនអាចកំណត់ដោយអ្នកស្ថាបនិក ។ រយៈពេលនៃក្រុមហ៊ុនអាចមិនមានពេលកំណត់ ។

**ប្រការ ៥ :** លក្ខន្តិកៈក្រុមហ៊ុនត្រូវ ចែងពីចំនួនភាគហ៊ុនដែលត្រូវបានអនុញ្ញាត អោយបោះចេញដោយក្រុមហ៊ុន និងតម្លៃ ចារឹក នៃភាគហ៊ុននីមួយៗ ។

**ប្រការ ៦ :** ក្នុងករណីក្រុមហ៊ុនបោះចេញភាគហ៊ុនលើសពីមួយប្រភេទ នោះត្រូវបញ្ជាក់ពីសិទ្ធិឯកសិទ្ធិការរឹតត្បិតនិងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅ នឹងប្រភេទភាគហ៊ុននីមួយៗ ។

**ប្រការ ៧ :** ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មអនុញ្ញាត អោយធ្វើអនុប្បទានទៅសមាជិកភាគហ៊ុនសមាជិកគ្រួសារ និងអ្នក គ្រប់គ្រងបានដោយសេរី ។ ក្នុងករណីធ្វើអនុប្បទានទៅអោយតតិយជនត្រូវ មានការយល់ព្រមពីសមាជិកភាគហ៊ុន ដទៃទៀត តាមសម្លេងភាគច្រើន ។ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា ការរឹតត្បិតបន្ថែមទៀតលើការធ្វើអនុប្បទាន ត្រូវចែង ក្នុងលក្ខន្តិកៈ ។

**ប្រការ ៨ :** អភិបាលអាចប្រកាសចេញនូវ ភាគលាភសល់ ឬ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន ដើម្បីចែកជូនម្ចាស់ហ៊ុន ។ ការរឹតត្បិតអាចចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ មាត្រា ១៥៧ - ១៥៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានចែងពីវិធាននិងការរឹតត្បិតលើការបែងចែកភាគលាភ ។

**ប្រការ ៩ :** ផ្អែកតាមមាត្រា ២២៤-២៣៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាលក្រុមហ៊ុនត្រូវមានកាតព្វកិច្ចផ្តល់ អោយម្ចាស់ហ៊ុននូវរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនករ និងព័ត៌មានបន្ថែមទៀតណាមួយទាក់ទិននឹងស្ថានភាពហិរញ្ញវត្ថុ ក្រុមហ៊ុននិងលទ្ធផលនៃប្រតិបត្តិការរបស់ខ្លួនដែលតម្រូវដោយលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆ័នរបស់ ម្ចាស់ហ៊ុនណាមួយ ។

**ប្រការ ១០ :** មាត្រា ២៥១-២៥៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បញ្ជាក់អំពីលក្ខខណ្ឌតម្រូវអោយម្ចាស់ភាគហ៊ុននិងអភិបាលដាក់ស្នើនិងអនុម័តការរំលាយក្រុមហ៊ុន ព្រមទាំងលក្ខខណ្ឌតម្រូវសម្រាប់រៀបចំសេចក្តីថ្លែងហេតុ និងលិខិតជូនដំណឹង អំពីការរំលាយក្រុមហ៊ុន ។ មាត្រាទាំងនេះក៏រួមមានបញ្ញត្តិស្តីពីការជម្រះបញ្ជី និងលក្ខខណ្ឌតម្រូវអោយ ក្រុមហ៊ុនដាក់នូវសេចក្តី-សម្រេចរំលាយក្រុមហ៊ុន ផងដែរ ។បញ្ញត្តិស្តីពីការរំលាយ និងការជម្រះបញ្ជីមិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលបានដាក់ពាក្យសុំ ក្ស័យធនទៅតុលាការឡើយ ។

**ប្រការ ១១ :** មាត្រា១២១នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានចែងថាអាណត្តិអភិបាលម្នាក់ៗត្រូវមានអាណត្តិ០២(ពីរ)ឆ្នាំហើយបានបញ្ជាក់ថាលក្ខន្តិកៈអាចចែងផ្សេងពីនេះ ។ មាត្រា ១១៦ ចែងថា អភិបាលដំបូងត្រូវកាន់តំណែង ចាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកដំបូង ។មាត្រា១២៤ចែងថាអភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបាន ដោយសម្លេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ ។ មាត្រា ១១៦ - ១៤២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានចែងពីតួនាទី ការទទួលខុសត្រូវ និងការជ្រើសរើសអភិបាល ។ សិទ្ធិអំណាចរបស់អភិបាលមានចែងក្នុងមាត្រា ១១៩ នៃច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម លក្ខន្តិកៈក្រុមហ៊ុនចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ :

១. តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២. កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣. កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំ សេចក្ដីសម្រេច ។

៤. ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាមដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនោះ ។

៥. ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦. ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧. ស្នើសុំម្ចាស់ហ៊ុន ដើម្បីលក់ទ្រព្យសកម្មរបស់ក្រុមហ៊ុនទាំងអស់ ឬមួយភាគ ។

៨. ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន ។

៩. ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុនប្រភេទនីមួយៗដែលមានសិទ្ធិ ទទួលភាគលាភ ។

១០. ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

១១. ខ្ចីប្រាក់ ។

១២. បោះចេញសាជាថ្មី ឬលក់មូលបត្ររបស់ក្រុមហ៊ុន ។

១៣. ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន ។

១៤. ធ្វើអ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បី ធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥. រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូន មហាសន្និបាតនៃម្ចាស់ហ៊ុន ។

**ប្រការ ១៧**:បញ្ចាក់ឈ្មោះរបស់ម្ចាស់ហ៊ុន អាជីពសញ្ជាតិ អាសយដ្ឋាន លេខលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ ។ផ្តល់អោយ ចំនួនភាគហ៊ុនកំណត់សម្រាប់ម្ចាស់ហ៊ុននីមួយៗ ។

តាមរយៈការចុះហត្ថលេខាលើលក្ខន្តិកៈ ម្ចាស់ហ៊ុន និងអភិបាលទាំងអស់យល់ព្រម ទទួលស្គាល់កាតព្វកិច្ច ដើម្បីអនុវត្តតាមវិធានគ្រប់គ្រងក្រុមហ៊ុន ដែលមានចែងក្នុងច្បាប់ ស្តីពី សហគ្រាស ពាណិជ្ជកម្ម ។ ម្ចាស់ហ៊ុនទាំងអស់ត្រូវចុះហត្ថលេខាលើលក្ខន្តិកៈ ។ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន តម្រូវអោយមាននូវសេចក្តីសម្រេចពិសេស របស់ម្ចាស់ហ៊ុន ដែលអ្នកកាន់កាប់ប្រភេទ ឬស៊េរីនៃភាគ ហ៊ុននីមួយៗត្រូវបោះឆ្នោតផ្សេងពីគ្នាតាម ប្រភេទ ឬស៊េរីភាគហ៊ុន ។ ដោយចុះហត្ថលេខាលើលក្ខន្តិកៈក្រុមហ៊ុន ម្ចាស់ហ៊ុន និង អភិបាលយល់ព្រមគោរពតាមមាត្រា ២៣៥-២៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលមានចែងអំពីនីតិវិធី និងលក្ខណៈ នៃការកែប្រែនោះ ។

## លក្ខខណ្ឌតម្រូវបន្ថែមដែលចែងដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

១. ក្រុមហ៊ុននីមួយៗ មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹង ស្ថានភាពរបស់ក្រុមហ៊ុននៅ ក្រសួង ពាណិជ្ជកម្ម ។

២. ការជ្រើសរើសសវនករ-ម្ចាស់ហ៊ុនត្រូវតែងតាំងសវនករមួយរូបដោយសេចក្តីសម្រេច សាមញ្ញនៅក្នុង មហាសន្និបាតម្ចាស់ហ៊ុន ប្រចាំឆ្នាំលើកដំបូង និងនៅមហាសន្និបាត ប្រចាំឆ្នាំនីមួយៗ ។ សវនករត្រូវកាន់តំណែងរហូតដល់ការបិទមហាសន្និបាតនៃ ឆ្នាំបន្ទាប់ ។ប្រសិនបើសវនករថ្មីមិនបានតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុន ទេសវនករដែលកំពុងកាន់តំណែងត្រូវបន្តរហូតដល់សវនករថ្មី ត្រូវបានតែងតាំង ។

៣. តាមរយៈការតម្កល់លក្ខន្តិកៈ ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចអនុវត្តតាមវិធានទាំង ឡាយដែលមានចែងក្នុងមាត្រា ១២៨-១៣២ និងមាត្រា ២០៥ - ២២៣ នៃច្បាប់ ស្តីពីសហគ្រាស ពាណិជ្ជកម្ម ដែលពាក់ពន្ធ័ដល់កិច្ចប្រជុំរបស់អភិបាល និងម្ចាស់ហ៊ុន។

៤. តាមរយៈការតម្កល់លក្ខន្តិកៈ ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចរៀបចំ និងរក្សាទុក ទិន្នន័យក្រុមហ៊ុន ហើយត្រូវផ្តល់ទិន្នន័យ ទាំងនោះអោយទៅម្ចាស់ហ៊ុននិងឥណទាន

យកដោយមិនគិតកម្រៃ ដោយយោងតាមមាត្រា ១០៩-១១០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

៥. ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន ។ប៉ុន្តែ មិនចាំបាច់តម្កល់បទបញ្ជាផ្ទៃក្នុងមួយនៅក្រសួងពាណិជ្ជកម្មដែលធ្វើឡើង ក្នុងគោលបំណងដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុន និងអភិបាលក្រុមហ៊ុន ។

៦. ក្រុមហ៊ុនមិនត្រូវប្រកប កិច្ចការអាជីវកម្មណាមួយ ឬ អនុវត្តសិទ្ធិណាមួយ ដែលលក្ខន្តិកៈ របស់ខ្លួនបានហាមឃាត់ឡើយ ។

៧. ផ្អែកទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងរាល់សិទ្ធិដែលអាច ទិញមុនគេរបស់ម្ចាស់ហ៊ុន ភាគហ៊ុន និង មូលបត្រ អាចអនុញ្ញាតអោយបោះចេញទៅតាមពេលវេលា និងចំពោះបុគ្គលទាំងឡាយដែលអភិបាលក្រុមហ៊ុនកំណត់អោយ ។ អភិបាលត្រូវកំណត់តម្លៃរបស់ប័ណ្ណភាគហ៊ុន និងតម្លៃមូលបត្រដែលត្រូវលក់ចេញ។ តម្លៃភាគហ៊ុនមិនត្រូវបោះចេញទេ រហូតដល់ ការបង់ថ្លៃសម្រាប់ភាគហ៊ុន ត្រូវបានបំពេញ ចប់សព្វ គ្រប់ជា សាច់ប្រាក់ ជាវត្ថុ ឬ ជាសេវាពីមុនទៅក្នុងក្រុមហ៊ុន ។ អភិបាល ទាំងឡាយកំណត់តម្លៃនៃការដាក់ភាគទុនជាវត្ថុ ឬជាសេវាកម្មពីមុននោះ ហើយសេចក្តីសម្រេច របស់ អភិបាលទាំងនេះចាត់ទុក ជាបានការប្រសិនបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ ។

៨. មាត្រា ១៦៤ - មាត្រា ១៩៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម គ្រប់គ្រងការចេញមូលបត្រ ការចុះបញ្ជី និងការផ្ទេរ មូលបត្រ ។

៩. តាមមាត្រា ២៨៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម លក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងអាចចែងថា ជម្លោះណាមួយ ដែលកើតមានរវាងអភិបាល និងម្ចាស់ហ៊ុនត្រូវដោះស្រាយដោយ មជ្ឈត្តករ ។

# ឧបសម្ព័ន្ធទី៦៖ លក្ខន្តិកៈរបស់ ធនាគារអេស៊ីលីដា

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ACLEDA Bank Plc.

# លក្ខន្តិកៈ

# Articles of Association

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត
ដើមទុនចុះបញ្ជី ១៣លានដុល្លារអាមេរិក

អាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ
ថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៣

# លក្ខន្តិកៈធនាគារអេស៊ីលីដា ភីអិលស៊ី

ក្រសួងពាណិជ្ជកម្ម
ការិយាល័យចុះបញ្ជី ពាណិជ្ជកម្ម
ចុះបញ្ជីលេខ...៨អ/៤២....
ថ្ងៃទី..៤៦..០៧....៤២....ម៉ោង..
...

## ជំពូកទី១ ប្រការទូទៅ

**មាត្រាទី ១.** នាម :

ធនាគារនេះ មាននាមជាភាសាខ្មែរថា ធនាគារអេស៊ីលីដា ភីអិលស៊ី និងជាភាសាអង់គ្លេសថា ACLEDA Bank Public Limited Company (ACLEDA Bank Plc ចាប់ពីនេះតទៅហៅថា ធនាគារ ។

**មាត្រាទី ២.** លក្ខណៈច្បាប់ :

ធនាគារ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ក្រោមច្បាប់ និងការអនុវត្តនៃព្រះរាជាណាចក្រកម្ពុជា ។ បំណុលរបស់ភាគទុនិកៈនិមួយៗត្រូវបាន កំណត់ត្រឹមមូលធនភាគហ៊ុនរបស់ខ្លួនដែលបានចុះបញ្ជីរួចហើយ និង ពុំទាន់បានបង់ប្រាក់ ចូលធនាគារ លើកលែងតែករណី ដូចមានចែងក្នុងមាត្រាទី៤៥ ខាងក្រោម ។

**មាត្រាទី ៣.** គោលដៅ :

ធនាគារ ត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការជាធនាគារពាណិជ្ជកម្ម តាមរយៈការិយាល័យកណ្តាលនៅភ្នំពេញ និងសាខានានានៅតាមបណ្តាខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតយកចិត្តទុកដាក់ជាពិសេសលើការផ្តល់សេវាកម្មឥណទាន និង សេវាកម្មផ្សេងទៀតរបស់ធនាគារ ជូនស្រទាប់ទីផ្សារជាន់ទាប ព្រមទាំងចូលរួម ក្នុងសកម្មភាពដទៃទៀតដែល ក្រុមប្រឹក្សាភិបាល យល់ឃើញថាស្របនឹងគោលដៅ ។

**មាត្រាទី ៤.** **ការិយាល័យដែលចុះបញ្ជី :**

ការិយាល័យ ធនាគារ ចុះបញ្ជីនៅផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់ បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអាច បើកការិយាល័យបន្ថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅក្នុងប្រទេសដទៃទៀត ហើយអាចផ្លាស់ប្តូរការិយាល័យដែលបានចុះបញ្ជី បន្ទាប់ពីបានចុះបញ្ជី ក្រសួងពាណិជ្ជកម្ម និងបានទទួលការយល់ព្រមពីធនាគារជាតិនៃកម្ពុជា អោយផ្លាស់ប្តូរផងដែរ ។

**មាត្រាទី ៥.** **ត្រានិងផ្លាកសញ្ញា :**

ក) ធនាគារ ត្រូវបង្កើតត្រាការណ៍តាមតម្រូវអោយមាន ។

ខ) ផ្លាកសញ្ញានៃធនាគារ គឺរូបហង្សពណ៌មាសឈរនៅចំកណ្តាលរង្វង់មូលពណ៌ខៀវ។

## ជំពូកទី ២ ភាគហ៊ុន និងមូលធនភាគហ៊ុន

**មាត្រាទី ៦.** **ភាគហ៊ុន និងមូលធនភាគហ៊ុនដែលចុះបញ្ជី :**

មូលធនសរុបរបស់ធនាគារ ដែលចុះបញ្ជី មានចំនួន ១៣.០០០.០០០ដុល្លារអាមេរិក (ដប់បីលានដុល្លារអាមេរិក) ចែកជា ១៣.០០០.០០០ (ដប់បីលាន) ភាគហ៊ុន តម្លៃភាគហ៊ុននិមួយៗ គឺស្មើនឹង ១.០០ដុល្លារ (មួយដុល្លារអាមេរិក) ។ ភាគហ៊ុននិមួយៗ មានសម្លេងឆ្នោតមួយ (១) សំលេង ហើយនឹងបានទទួលភាគលាភ និងរាល់ការបែងចែកផ្សេងៗទៀតរបស់ធនាគារស្មើភាពគ្នា ។ ការបែងចែងនៃភាគហ៊ុន មិនត្រូវបោះផ្សាយទេ ។

**មាត្រាទី ៧.** **ភាគទុនិក :**

៧.១ ACLEDA NGO ជាអង្គការក្រៅរដ្ឋាភិបាល ដែលមានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ព្រះរាជាណាចក្រកម្ពុជា ក្នុងអាសយដ្ឋាន នៅផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ចាប់ពីពេលនេះទៅហៅថា "ACLEDA NGO") ។

ក.២ *អេ អេស អេ អ៊ិញ* ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង និង ចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានអាសយដ្ឋាន ផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់ បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ចាប់ពីនេះ តទៅហៅថា "ASA, Inc") ។

ក.៣ <u>DEG</u>: Deutsche Investitions-und Entwicklungsgesellschaft mb: ដែលជាក្រុមហ៊ុនទទួល ខុសត្រូវមានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃសាធារណរដ្ឋសហព័ន្ធ អាល្លឺម៉ង់ ក្នុងអាសយដ្ឋាន Belvederestr. 40, D-50933, Cologne, Germar (ចាប់ពីនេះតទៅហៅថា "DEG") ។

ក.៤ Nederlandse Financierings-Maatschappij voor Ontwikkelingslandc N.V. ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង ក្រោមច្បាប់នៃប្រទេសហូឡ ដែលបានចុះបញ្ជីក្នុងអាសយដ្ឋាន Anna Van Saksenlaan 71, 2593 HW, Tl Hague, the Netherlands (ចាប់ពីនេះតទៅហៅថា "FMO") ។

ក.៥ International Finance Corporation បង្កើតឡើងក្រោមមាត្រានៃកិច្ចព្រមព្រៀងដែល ចុះហត្ថលេខារវាងប្រទេសជាសមាជិក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ ដែលមាន អាសយដ្ឋាន ការិយាល័យកណ្តាលនៅ 2121 Pennsylvania Avenue; N.W Washington D.C. 20433, U.S.A (ចាប់ពីនេះតទៅហៅថា "IFC") .

---

ក.៦ Stichting Triodos Doen ជាមូលនិធិមួយដែលបានកសាងឡើងក្រោមច្បាប់នៃប្រទេសហូល ដែលមាន ការិយាល័យធំនៅ Utrechtseweg 60, P.O Box 55, 3700 AB Zei the Netherlands (ចាប់ពីនេះតទៅហៅថា "TRIODOS") និង

ក.៧ Triodos Custody B.V ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ដែលបានបង្កើតឡើង ក្រោមច្បាប់នៃប្រទេសហូឡង់ ក្នុងនាមជាក្រុមហ៊ុន Triodos Fair Share Fund ជាមូលនិធិដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសហូឡង់ ដែលមាន ការិយាល័យធំ Utrechtseweg 60, P.O Box 55, 3700 AB Zeist, the Netherlai (ចាប់ពីនេះតទៅហៅថា "TC") ។

*li*

**មាត្រាទី ៨.** **ការទិញភាគហ៊ុន :**

ភាគទុនិកៈទាំងអស់ នឹងទិញភាគហ៊ុន តាមចំនួនដូចខាងក្រោមនេះ :

| ភាគទុនិកៈ | ភាគរយនៃកម្មសិទ្ធិ | មូលធនភាគហ៊ុន (US$) | ចំនួនភាគហ៊ុន |
|---|---|---|---|
| ACLEDA NGO | 40.07% | $5,208,457 | 5,208,457 |
| ASA, Inc | 10.93% | $1,421,543 | 1,421,543 |
| DEG | 12.25% | $1,592,500 | 1,592,500 |
| FMO | 12.25% | $1,592,500 | 1,592,500 |
| IFC | 12.25% | $1,592,500 | 1,592,500 |
| TRIODOS | 10.33% | $1,342,500 | 1,342,500 |
| TC | 1.92% | $250,000 | 250,000 |
| <u>TOTAL</u> | 100.00% | $13,000,000 | 13,000,000 |

**មាត្រាទី ៩.** **មូលបត្រភាគហ៊ុន :**

ភាគទុនិកៈនិមួយៗ មានសិទ្ធិទទួលពីធនាគារនូវមូលបត្រភាគហ៊ុនមួយឬច្រើន ដែលបញ្ជាក់ភាគហ៊ុនរបស់ខ្លួននៅក្នុងធនាគារ ។ មូលបត្រភាគហ៊ុននេះ ត្រូវបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំ ឬក្រុមប្រឹក្សាភិបាលនៃធនាគារចំនួនពីររូប ដោយបញ្ជាក់នាម និងអាស័យដ្ឋានរបស់ធនាគារ បោះត្រាធនាគារ មានចុះលេខរៀង និងចុះកាលបរិច្ឆេទចេញមូលបត្រភាគហ៊ុន មូលបត្រភាគហ៊ុននិមួយៗ ត្រូវសរសេរការហាមឃាត់រាល់ការផ្លាស់ប្តូរ ដែលមានចែងក្នុង មាត្រាទី១៣ទាំងស្រុង ។ ធនាគារនឹងថែរក្សាបញ្ជីផ្ទេរស្តុកដែលកត់ត្រាការបញ្ចេញ, ការបញ្ជូនត្រឡប់មកវិញ, ការលុបចោល ឬកិច្ចការផ្សេងៗទៀតអំពីមូលបត្រភាគហ៊ុន។

**មាត្រាទី ១០.** **ហត្ថលេខីដែលបានទទួលការអនុញ្ញាត :**

មានតែអ្នកដែលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាភិបាលទេ ដែលមានសិទ្ធិចុះហត្ថលេខាលើឯកសារធនាគារ ដើម្បីដាក់កាតព្វកិច្ចលើធនាគារ។ ហត្ថលេខាដែលគ្មានការអនុញ្ញាត ត្រូវចាត់ទុកជាមោឃៈ ។ ក្រុមប្រឹក្សាភិបាលអាចប្រគល់សិទ្ធិជូនអគ្គនាយកធនាគារ ដែលបានតែងតាំងក្រោមមាត្រាទី ៤២ ។

**មាត្រាទី ១១–** **ការបង្កើនមូលធនដែលបានចុះបញ្ជី :**

ធនាគារ អាចបង្កើនមូលធនដែលបានចុះបញ្ជីរួចហើយ ដោយបញ្ចេញភាគហ៊ុននៅក្នុងធនាគារ បន្ថែមទៀត ដោយមានការយល់ព្រមជាមុនដោយសំលេងឆ្នោតគាំទ្រយ៉ាងតិចចំនួន ៧៥ ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការងារ និងពីភាគទុនិកៈដែលកាន់កាប់ភាគហ៊ុន ៧៥ភាគរយ ឬច្រើនជាងនេះ នៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។

**មាត្រាទី ១២–** **ការទិញភាគហ៊ុនវិញ :**

តាមច្បាប់ដែលបានអនុញ្ញាត ធនាគារ អាចទិញភាគហ៊ុនរបស់ខ្លួនវិញ ដោយត្រូវមានការយល់ព្រមជាមុន ដោយមានសំលេងឆ្នោតគាំទ្រយ៉ាងតិចចំនួន ៧៥ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការងារ និងពីភាគទុនិកៈដែលកាន់កាប់ភាគហ៊ុន៧៥ភាគរយ ឬច្រើនជាងនេះនៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។

**មាត្រាទី ១៣–** **ការហាមឃាត់លើការផ្ទេរភាគហ៊ុន :** ភាគហ៊ុននៃធនាគារ ត្រូវស្ថិតក្រោមការហាមឃាត់លើការផ្ទេរភាគហ៊ុន ដូចតទៅ :

១៣.១ ភាគទុនិកៈ *អង្គការអេស៊ីលីដា* មិនអាចបន្ថយភាគរយនៃភាគហ៊ុនរបស់ខ្លួនតិចជាង ២៨ ភាគរយ នៃមូលធនភាគហ៊ុនធនាគារដែលបានចុះបញ្ជីរួចហើយ ។

១៣.២ ប្រសិនភាគទុនិកៈ *អង្គការអេស៊ីលីដា* លក់ ឬ ប្រកាសលក់ភាគហ៊ុនណាមួយរបស់ខ្លួន ទៅអោយនរណាម្នាក់ "ក្នុងនេះហៅថាអ្នកទិញ" តាមការទូទាត់ម្តង ឬច្រើនដង ភាគទុនិកៈផ្សេងៗទៀតទាំងអស់ ក៏មានសិទ្ធិលក់ភាគហ៊ុនរបស់ខ្លួនទៅអ្នកទិញនោះក្នុងតម្លៃ និងលក្ខខណ្ឌដូចគ្នា ដែល *អង្គការអេស៊ីលីដា* លក់ ឬ ប្រកាសលក់ដែរ ។ កិច្ចព្រមព្រៀងទាំងឡាយណាដែលភាគទុនិក *អង្គការអេស៊ីលីដា* ធ្វើឡើង ដើម្បីលក់ភាគហ៊ុនរបស់ខ្លួនដែលផ្ទុយពីមាត្រា១៣.២នេះ គឺចាត់ទុកជាមោឃភាព ។ មាត្រាទី១៣.២នេះ មិនត្រូវអនុវត្តលើការផ្ទេរភាគហ៊ុនពី *អង្គការអេស៊ីលីដា* ទៅ ASA, Inc. ទេ ដរាបណា *អង្គការអេស៊ីលីដា* នៅតែកាន់កាប់ភាគហ៊ុន ២៨ ភាគរយ ឬច្រើនជាងនេះនៃមូលនិធិភាគហ៊ុនដែលបានចុះបញ្ជី របស់ធនាគារ ។

## ជំពូកទី ៣ សន្និបាតភាគទុនិកៈ

**មាត្រាទី ១៤.** **សន្និបាតភាគទុនិកៈប្រចាំឆ្នាំ និងសន្និបាតផ្សេងៗ :**

ភាគទុនិកៈ ត្រូវកោះសន្និបាតប្រចាំឆ្នាំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ តែមិនឱ្យលើសពី១៥ខែ ក្រោយពីសន្និបាតលើកមុនឡើយ ។ ក្រុមប្រឹក្សាភិបាល ត្រូវកំណត់កាលបរិច្ឆេទ និង ពេលវេលាសន្និបាត ។ សន្និបាតភាគទុនិកៈវិសាមញ្ញ អាចប្រព្រឹត្តិទៅបានក្នុងករណី :

ក. មានការសំរេចពីក្រុមប្រឹក្សាភិបាល ឬ

ខ. មានការស្នើសុំជាលាយលក្ខណ៍អក្សរពីភាគទុនិកៈទាំងឡាយដែលមានភាគហ៊ុនសរុប មិនតិចជាង ភាគរយនៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។ ក្រុមប្រឹក្សាភិបាល "ឬ ភាគទុនិកៈ ណាដែលជាអ្នកកោះសន្និបាត " នឹងកំណត់របៀបវារៈសន្និបាត ។ សមាជិកក្រុមប្រឹក្សា ២រូប ភាគទុនិកៈណាដែលកាន់កាប់ភាគហ៊ុនចាប់ពី ២០ភាគរយឡើងទៅនៃភាគហ៊ុន ដែលនៅសល់ធនាគារ អាចស្នើបន្ថែមរបៀបវារៈទៅក្នុងសន្និបាតបាន ។

**មាត្រាទី ១៥.** **ការសំរេចរបស់ភាគទុនិកៈដោយគ្មានការធ្វើសន្និបាត :**

ការសំរេចណាមួយដែលតម្រូវឱ្យសន្និបាតរបស់ភាគទុនិកៈសំរេច អាចអនុវត្តបានដោយគ្មានការសន្និបាត ក្នុងករណីមានការយល់ព្រមជាលាយលក្ខណ៍អក្សរអោយអនុវត្ត ដោយភាគទុនិកៈទាំងឡាយដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានេះ ។ ឯកសារចម្លងច្រើនច្បាប់នៃសេចក្តីសំរេចបញ្ហាទាំងទូរសារថតចម្លង ដែលសមាជិកមួយរូប ឬច្រើនរូបបានចុះហត្ថលេខា ត្រូវចាត់ទុកថា សេចក្តីជាលាយលក្ខណ៍អក្សរនេះ ត្រូវរក្សាទុកក្នុងសៀវភៅកំណត់ហេតុ ដោយចាត់ទុកជាកំណត់ហេតុសន្និបាតរបស់ភាគទុនិកៈ ។

**មាត្រាទី ១៦.** **ទីកន្លែងសន្និបាតភាគទុនិកៈ :**

រាល់សន្និបាតភាគទុនិកៈ ត្រូវតែរៀបចំឡើងនៅការិយាល័យធនាគារដែលបានចុះបញ្ជី ឬនៅកន្លែងផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬដោយភាគទុនិកៈដែលជាអ្នកកោះអង្គប្រជុំនោះ ។

**មាត្រា ២១.** **ការដឹកនាំនៃសន្និបាតភាគទុនិក :**

សន្និបាតនៃភាគទុនិកនីមួយៗ ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីអវត្តមានប្រធានក្រុមប្រឹក្សាភិបាល ភាគទុនិកដែលមាន ឬដែលបានទទួលសិទ្ធិប្រទានត្រូវបោះឆ្នោតជ្រើសរើសតាំងប្រធានក្រុមប្រឹក្សាភិបាលស្តីទី ដើម្បីដឹកនាំសន្និបាតភាគទុនិកដោយមានសំលេងឆ្នោតគាំទ្រភាគច្រើន ។ រាល់សេចក្តីសំរេចរបស់ភាគទុនិក ត្រូវតែកត់ត្រាជាលាយលក្ខណ៍អក្សរក្នុងកំណត់ហេតុនៃសន្និបាត ដែលសេចក្តីសំរេច ត្រូវបានធ្វើឡើងក្នុងសន្និបាតនោះ ហើយកំណត់ហេតុនោះត្រូវបានផ្តល់ការយល់ព្រមដោយភាគទុនិកទាំងអស់ ។ ការបោះឆ្នោតក្នុងសន្និបាតភាគទុនិកត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែករណីដែលមានការណែនាំពីប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ២២.** **ការបោះឆ្នោតដោយភាគទុនិក, ករណីពិសេស :**

ភាគហ៊ុនដែលនៅសល់នីមួយៗ មានសំលេងឆ្នោតមួយសំលេង ។ រាល់សេចក្តីសំរេចរបស់ភាគទុនិដែលធ្វើឡើងអនុលោមទៅតាមមាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ត្រូវតែធ្វើឡើងដោយការបោះឆ្នោដោយមានសំលេងគាំទ្រយ៉ាងតិច ហាសិបមួយភាគរយ (៥១ភាគរយ) នៃភាគហ៊ុនដែលនៅសល់ រៀងរាល់សន្និបាតដែលមានកូរ៉ុមគ្រប់ចំនួន លើកលែងតែករណីដូចខាងក្រោមនេះ ដែលតម្រូវអោយមានសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ ឬច្រើនជាងនេះ នៃភាគហ៊ុនដែលនៅសល់ៈ

២២.១ ការកែប្រែមាត្រាទាំងឡាយនៃលក្ខន្តិកៈ

២២.២ ការផ្លាស់ប្តូរគោលដៅ ឬកិច្ចការជំនួញរបស់ធនាគារ

២២.៣ ការផ្លាស់ប្តូរអាជ្ញាប័ណ្ណរបស់ធនាគារ

២២.៤ ការផ្លាស់ប្តូរមូលធនជាភាគហ៊ុនរបស់ធនាគារដែលបានចុះបញ្ជី

២២.៥ ការចូលរួមគ្នា, ការដាក់បញ្ចូលគ្នា, ការរៀបចំឡើងវិញ ឬតាមវិធីណាក៏ដោយ ដែលតម្រូវអោយផ្ទេរទ្រព្យសម្បត្តិធនាគារភាគខ្លះ ឬក៏ទាំងអស់ ទៅអោយអង្គភាពផ្សេងទៀត ។

២២.៦ ការអនុម័តលើគោលនយោបាយទូទៅរបស់ធនាគារ ទាក់ទិននឹងការធ្វើប្រតិបត្តិ និងការទូទាត់ភាគលាភ និងការផ្លាស់ប្តូរទាំងនេះ ។

២២.៧ ការរំលាយដោយស្ម័គ្រចិត្ត និងការជំរះបញ្ជីធនាគារ ក្រោមមាត្រាទី ៤៤

២២.៨ ការកែប្រែរបៀបវារៈសន្និបាតភាគទុនិក ក្រោមមាត្រាទី ១៨ .

២២.៩ ការទិញភាគហ៊ុនវិញ ដោយអនុលោមទៅតាមមាត្រាទី ១២ និង

២២.១០ ការអនុមតិលើការតែងតាំង ឬការផ្លាស់ប្តូរផែនស្នងការគណនីរបស់ធនាគារ ។

**មាត្រាទី ២៣. ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល :**

ភាគទុនិកៈម្នាក់ៗ មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលដោយខ្លួនឯង ឬដោយសិទ្ធិប្រទានបានមួយសំលេងក្នុងមួយភាគហ៊ុនដែលភាគទុនិកៈនោះកាន់កាប់ហើយ ក៏អាចបោះឆ្នោតទាំងអស់ឱ្យសមាជិកក្រុមប្រឹក្សាណាម្នាក់ ឬច្រើននាក់ដែលឈរឈ្មោះបោះឆ្នោត ។

## ជំពូកទី ៤ ក្រុមប្រឹក្សាភិបាល

**មាត្រាទី ២៤. សិទ្ធិអំណាច និងភារកិច្ច ប្រធាន :**

ក. ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវកំណត់យុទ្ធសាស្ត្រនៃធនាគារ និងត្រួតពិនិត្យដំណើរការកិច្ចការជំនួញ ។ សមាជិកក្រុមប្រឹក្សាត្រូវធ្វើកិច្ចការណា ដែលផ្តល់ផលប្រយោជន៍ដល់ធនាគារ ។

ខ. អំណាចរបស់ក្រុមប្រឹក្សាភិបាល ត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ មានអំណាចចាត់ចែងមន្ត្រី ឬនិយោជិតរបស់ធនាគារ ចុះហត្ថលេខាលើកិច្ចសន្យាណាមួយ ឬចាត់ចែងប្រតិបត្តិការរបស់ធនាគារ លុះត្រាតែបានទទួលអំណាចពិសេស ដើម្បីចាត់ចែងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល។

គ. សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ អាចពិនិត្យមើលដោយគ្មានកំរិត នូវបញ្ជី ឬរបាយការណ៍របស់ធនាគារនៅក្នុងពេលម៉ោងធ្វើការធម្មតា ។

ឃ. ក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវជ្រើសតាំងក្នុងចំណោមសមាជិករបស់ខ្លួនមួយរូប ដើម្បីធ្វើជាប្រធានដោយសំលេងឆ្នោតគាំទ្រភាគច្រើន ។ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ។ សំលេងឆ្នោតគាំទ្រភាគច្រើននៃសមាជិកក្រុមប្រឹក្សាភិបាលដែលកំពុង[illegible]ការងារនៅការិយាល័យអាចផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាលបាន ប៉ុន្តែមិនអាចដកហូតតួនាទីសមាជិកក្រុមប្រឹក្សាបានឡើយ ។

**មាត្រាទី ២៥. សមាជិកក្រុមប្រឹក្សាភិបាល :**

ក្រុមប្រឹក្សាភិបាល មានសមាជិក ៥រូប ។

**មាត្រា ២៦.** **សមាសភាពក្រុមប្រឹក្សាភិបាលលើកដំបូង:**

ក្រុមប្រឹក្សាភិបាលដំបូង រួមមានសមាជិកដូចតទៅនេះ សមាជិកម្នាក់ៗ ត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ :

១ លោក ជា សុខ

២ Mr. John Brinsden

៣ Mr. Peter Kooi

៤ Ms. Jutta Wagenseil

៥ Mr. Emile Hubert Joseph Groot

៦ Mr. Deepak C. Khanna

៧ Ms. Femke Bos

៨ លោក ឡុញ ថុល

៩ អ្នកស្រី សុខ វណ្ណនី

**មាត្រា ២៧.** **ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាល :**

ភាគទុនិកៈ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល សំរាប់អាណត្តិ ៣ ឆ្នាំ ដូចមានចែង ក្នុងមាត្រាទី២៣ ខាងលើ ។

**មាត្រា ២៨.** **អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល :**

អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំចន្លោះពីអង្គប្រជុំមួយទៅអង្គប្រជុំមួយមិនលើសពី៤ខែឡើយ ។ យ៉ាងហោចណាស់ អង្គប្រជុំក្រុមប្រឹក្សាភិបាលចំនួន២លើកក្នុងចំណោមអង្គប្រជុំក្រុមប្រឹក្សាភិបាលទាំង៤លើក ត្រូវតែមានមនុស្សចូលរួមប្រជុំពេញអង្គ អង្គប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល អាចធ្វើឡើងនៅពេលណាក៏បាន ដោយតែមានសំណូមពរសមាជិកក្រុមប្រឹក្សាភិបាលចំនួន ៣រូប ។

**មាត្រា ២៩.** **កិច្ចប្រជុំតាមអ៊ីមែល ឬ តាមទូរស័ព្ទ :**

លើកលែងតែអង្គប្រជុំក្រុមប្រឹក្សាភិបាលចំនួន២លើក ដូចដែលបានរៀបរាប់ក្នុងមាត្រាទី ២៨ ចំណុចទី២ អង្គប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាលអាចប្រជុំពិភាក្សា

[illegible] ឬតាមទូរសព្ទ ។ ចំពោះការប្រជុំតាមទូរសព្ទ មានប្រសិទ្ធិភាព ក្នុងករណីដែល អ្នកចូលរួមប្រជុំទាំងអស់បញ្ជាក់ថាអាចស្តាប់ឮទៅវិញទៅមកទាំងអស់គ្នាបាន ។ ការប្រជុំដែល ធ្វើឡើងតាម អ៊ីម៉ែល មានប្រសិទ្ធិភាព ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ បានបញ្ជាក់អំពីគោលបំណងនៃអង្គប្រជុំនោះ ដោយផ្តល់ក្រឡប់នូវការទទួលស្គាល់ តាម អ៊ីម៉ែល និងមានពេលវេលាពិនិត្យវិចារណ៏ដែលបានផ្តល់ដោយសមាជិកក្រុមប្រឹក្សាភិបាលណាមួយ ហើយ កំណត់ហេតុនៃរាល់អង្គប្រជុំ ត្រូវបញ្ជាក់ថា អង្គប្រជុំធ្វើឡើងដោយ អ៊ីម៉ែល និង សង្ខេបចុះ អ៊ីម៉ែល ដែលវិចារណ៏ផ្តល់ដោយក្រុមប្រឹក្សាភិបាល ។

មាត្រាទី ៣០- **សេចក្តីជូនដំណឹងពីអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល :**

សេចក្តីជូនដំណឹងអង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើជូនទៅ សមាជិកក្រុមប្រឹក្សាទាំងអស់ចូលរួមប្រជុំយ៉ាងហោចណាស់៣០ថ្ងៃមុនកាលបរិច្ឆេទប្រជុំចាប់ផ្តើម

លិខិតជូនដំណឹង ត្រូវចុះកាលបរិច្ឆេទ, ពេលវេលា, និងទីកន្លែងប្រជុំ ព្រមទាំងរបៀបវារៈដែល ត្រូវពិភាក្សា និងសំរេចផងដែរ ។

មាត្រាទី ៣១- **របៀបវារៈ :**

សមាជិកក្រុមប្រឹក្សា ដែលមានចំនួន៣រូប អាចស្នើបន្ថែម របៀបវារៈអង្គប្រជុំក្រុមប្រឹក្សាភិបាល ណាមួយក៏បាន ដោយគ្រាន់តែជូនដំណឹងអំពីរបៀបវារៈនោះដល់ប្រធាន និងសមាជិកក្រុមប្រឹក្សា ដទៃទៀត អោយបានយ៉ាងហោចណាស់ ១៥ថ្ងៃមុនពេលអង្គប្រជុំចាប់ផ្តើម។ ប្រសិនបើសមាជិក ក្រុមប្រឹក្សាទាំងអស់ ដែលកំពុងបំពេញការងារ វត្តមានក្នុងអង្គប្រជុំ - ឬដោយសិទ្ធិប្រទាន សមាជិក ក្រុមប្រឹក្សាទាំងអស់នោះ អាចយល់ព្រមជាឯកច្ឆន្ទដើម្បីបន្ថែមរបៀបវារៈ ។

មាត្រាទី ៣២- **ទីកន្លែងប្រជុំ :**

គ្រប់អង្គប្រជុំដោយផ្ទាល់ ត្រូវរៀបចំឡើងនៅការិយាល័យកណ្តាលនៃធនាគារ ដែលបានចុះ ដូចបានចែងក្នុងមាត្រាទី៤ ឬនៅកន្លែងណាមួយផ្សេងទៀត. ដែលក្រុមប្រឹក្សាភិបាលបានសំរេច

មាត្រាទី ៣៣- កូរ៉ុម :

កូរ៉ុមនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលជាចំនួនភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាភិបាល ដែលកំពុងបំពេញការងារ លើកលែងតែកិច្ចប្រជុំតាមអ៊ីម៉ែល ដែលសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវតែបំពេញកូរ៉ុម ។ សិទ្ធិប្រទានដែលចូលរួមប្រជុំ អាចរាប់បញ្ចូលជាវត្តមាននៃកូរ៉ុម ។

មាត្រាទី ៣៤- ការបោះឆ្នោតដោយក្រុមប្រឹក្សាភិបាល, ករណីពិសេស :

សមាជិកក្រុមប្រឹក្សាមួយរូបៗ មានសំលេងឆ្នោតមួយសំលេង ។ រាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ដែលធ្វើឡើងដោយអនុលោមទៅតាមមាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ត្រូវមានសំលេងឆ្នោតគាំទ្រយ៉ាងហោចណាស់ ៥១ភាគរយ នៃក្រុមប្រឹក្សាភិបាលចូលរួម រាល់អង្គប្រជុំដែលមានកូរ៉ុមគ្រប់ចំនួន លើកលែងតែ ការសំរេចដែលទាក់ទងករណីដូចខាងក្រោមនេះ ដែលតម្រូវការសំលេង ឆ្នោតគាំទ្រយ៉ាងហោចណាស់ ៧៥ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការ :

៣៤.១ ការកែប្រែមាត្រាទាំងឡាយនៃលក្ខន្តិកៈ

៣៤.២ ការអនុម័តលើ ថវិកាប្រចាំឆ្នាំ ឬការផ្លាស់ប្ដូរថវិកាប្រចាំឆ្នាំ ដែលអគ្គនាយកបានដាក់ជូន ក្នុងនោះរាប់បញ្ចូលទាំងថវិកា ដែលចំណាយលើមូលធន

៣៤.៣ ការចំណាយលើមូលធនលើសពីថវិកា ដែលត្រូវបានអនុម័តពីមុនរួចមកហើយ សំរាប់សារពើពន្ធនោះ

៣៤.៤ ការតែងតាំង ឬ ដកតំណែងអគ្គនាយកធនាគារ ក្រោមមាត្រាទី ៤២

៣៤.៥ ការធ្វើប្រតិវេទ ឬការទូទាត់ភាគលាភ ឬការបែងចែកទ្រព្យសកម្មផ្សេងៗទៀតទៅឱ្យភាគហ៊ុននៃធនាគារ ។

៣៤.៦ ការរំលាយដោយស្ម័គ្រចិត្ត ឬ ការជំរះបញ្ជីធនាគារ ក្រោមមាត្រា ៤៤

៣៤.៧ ការអនុម័តលើការទូទាត់ភាគលាភរបស់ធនាគារ ត្រូវធ្វើទៅតាមគោលនយោបាយទាក់ទិននឹងការប្រតិវេទ និងការទូទាត់ភាគលាភស់ធនាគារ ។

៣៤.៨ ការទិញភាគហ៊ុនវិញ ដោយអនុលោមទៅតាមមាត្រាទី ១២

**មាត្រាទី ៣៥-** **សេចក្តីសំរេច និង កំណត់ហេតុ :**

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែបង្ហាញអោយឃើញច្បាស់ ដោយការកត់ត្រាសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលជាលាយល័ក្ខអក្សរ ឬដោយកំណត់ហេតុនៃអង្គប្រជុំ ដែលសេចក្តីសំរេចបានធ្វើឡើង កំណត់ហេតុនោះ នឹងត្រូវបានអោយសច្ចានុម័តដោយអង្គប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល។ ការបោះឆ្នោតនៅរៀងរាល់អង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយការលើកដៃ ឬដោយវិធីផ្សេងៗទៀត ដែលអធិបតីក្រុមប្រឹក្សាជាអ្នកសំរេច ។

**មាត្រាទី ៣៦-** **ការសំរេចជាឯកច្ឆន្ទជាលាយល័ក្ខអក្សរ :**

សមាជិកក្រុមប្រឹក្សាភិបាល អាចធ្វើសកម្មភាពនៅចន្លោះកិច្ចប្រជុំក្រុមប្រឹក្សាភិបាលតាមរយសេចក្តីសំរេចជាឯកច្ឆន្ទជាលាយល័ក្ខអក្សរដែលមានចុះហត្ថលេខា ដោយសមាជិកក្រុមប្រឹក្សាទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានោះ។ ឯកសារថតចំលងច្រើនច្បាប់នៃសេចក្តីសំរេចនោះរួមទាំងទូរសារថតចម្លងដែលសមាជិកក្រុមប្រឹក្សាមួយរូបឬច្រើនរូបបានចុះហត្ថលេខានឹងត្រូវចាត់ទុកថាជាផ្នែកនៃសេចក្តីសំរេចមួយជាលាយល័ក្ខអក្សរតាមគោលបំណងនៃមាត្រានេះ ។

**មាត្រាទី ៣៧-** **ការបោះឆ្នោតដោយសិទ្ធិប្រទាន :**

សមាជិកក្រុមប្រឹក្សាម្នាក់ ដែលមិនអាចចូលរួមក្នុងអង្គប្រជុំ ក្រុមប្រឹក្សាភិបាលបាន អាចតែងតាំងអ្នកទទួលសិទ្ធិប្រទានម្នាក់ ដើម្បីធ្វើការបោះឆ្នោត ក្នុងអង្គប្រជុំនោះជំនួសខ្លួនអោយតែ :

១- សិទ្ធិប្រទានដែលបានតែងតាំងនោះ គឺជាសមាជិកក្រុមប្រឹក្សាដទៃទៀត និង

២- សិទ្ធិប្រទាននោះ ត្រូវបានតែងតាំងសំរាប់តែអង្គប្រជុំមួយនោះទេ ។ សិទ្ធិប្រទានត្រូវរាប់បញ្ចូលបង្គ្រប់ កូរ៉ុម។ សិទ្ធិប្រទាន ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ហើយប្រគល់ជូនប្រធានក្រុមប្រឹក្សាភិបាល អោយបានមុនពេលប្រជុំចាប់ផ្តើម ហើយត្រូវបញ្ជាក់ពីព្រំដែននៃសមត្ថកិច្ច ឬក៏សិទ្ធិអំណាច។ សិទ្ធិប្រទានលែងមានសិទ្ធិ ឬក៏ចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលតទៅទៀតហើយ នៅពេលណាសមាជិកក្រុមប្រឹក្សា ដែលបានផ្តល់សិទ្ធិប្រទានមានវត្តមានជាក់ស្តែងក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ដោយខ្លួនឯងផ្ទាល់ ។

**មាត្រាទី ៣៨-** **សមាជិកក្រុមប្រឹក្សាដែលមានផលប្រយោជន៍ផ្ទាល់ខ្លួន :**

សមាជិកក្រុមប្រឹក្សាណាម្នាក់ដែលមានផលប្រយោជន៍ហិរញ្ញវត្ថុ ទោះផ្ទាល់ ឬដោយប្រយោលក៏ដោយ (ឬបើមានសមាជិកក្រុមគ្រួសារផ្ទាល់មានផលប្រយោជន៍បែបនេះ) មុនពេលក្រុមប្រឹក្សាភិបាលធ្វើការសំរេច លើសំណើណាក៏ដោយ សមាជិកក្រុមប្រឹក្សារូបនោះត្រូវតែជំរាបសមាជិកក្រុមប្រឹក្សាដទៃទៀតពីផលប្រយោជន៍នោះ មុនពេលអង្គប្រជុំក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត ហើយសមាជិកក្រុមប្រឹក្សាទាំងអស់ មិនត្រូវចូលរួមពិភាក្សាលើសំណើនោះទេ លុះត្រាណាតែគាត់ត្រូវអោយចូលរួមពិភាក្សាដោយមានសំលេងឆ្នោតគាំទ្រភាគច្រើន ពីសមាជិកក្រុមប្រឹក្សាដទៃទៀតដែលចូលរួមក្នុងអង្គប្រជុំនោះ ។ សមាជិកក្រុមប្រឹក្សានោះ មិនត្រូវបោះឆ្នោតលើករណីបែបនោះ ទេ ប៉ុន្តែវត្តមានរបស់សមាជិកក្រុមប្រឹក្សាទាំងអស់ នឹងត្រូវបានរាប់បញ្ចូលក្នុងកូរ៉ុមនៃអង្គប្រជុំ ។

**មាត្រាទី ៣៩-** **ការដកតំណែងសមាជិកក្រុមប្រឹក្សា :**

មានតែភាគទុនិកៈដែលបានជ្រើសរើស ឬតែងតាំងសមាជិកក្រុមប្រឹក្សាទេ ដែលអាចដកសមាជិកក្រុមប្រឹក្សាបាន ។ ការដកតំណែងនេះ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាដោយគ្រាន់តែមានការជូនដំណឹងសមស្របដល់ប្រធានក្រុមប្រឹក្សាប៉ុណ្ណោះ ។

**មាត្រាទី ៤០-** **ការបំពេញកន្លែងទំនេរក្នុងក្រុមប្រឹក្សាភិបាល :**

បើអាសនៈណាមួយទំនេរក្នុងក្រុមប្រឹក្សាភិបាល មុនពេលផុតអាណត្តិធម្មតារបស់សមាជិកក្រុមប្រឹក្សា ដោយមូលហេតុមរណភាព សុំលាឈប់ ចូលនិវត្តន៍ ឬត្រូវបានដកចេញពីសមាជិកក្រុមប្រឹក្សាភិបាល ភាគទុនិកៈ ដែលជ្រើសតាំង ឬតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលថ្មី ដើម្បីបំពេញអាណត្តិដែលនៅសល់របស់អតីតសមាជិកក្រុមប្រឹក្សាភិបាលមុននោះ ។

**មាត្រាទី ៤១-** **គណៈកម្មាធិការនានានៃក្រុមប្រឹក្សាភិបាល :**

ក្រុមប្រឹក្សាភិបាល ត្រូវបង្កើតគណៈកម្មាធិការសវនកម្ម, គណៈកម្មាធិការឥណទាន, គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តច្បាប់ និងគណៈកម្មាធិការត្រួតពិនិត្យទ្រព្យសម្បត្តិ និងបំណុល ហើយអាចបង្កើត គណៈកម្មាធិការដទៃផ្សេងៗទៀត ដែលយល់ថាចាំបាច់ក្នុងការដឹកនាំកិច្ចការជំនួញ និងប្រតិបត្តិការរបស់ធនាគារ ។ គណៈកម្មាធិការទាំងនេះបង្កើតឡើង តាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ហើយសមាជិកទាំងអស់នៃគណៈកម្មាធិការទាំងនេះ ត្រូវតែអនុវត្តទៅតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ៤២-** **អគ្គនាយក :**

ក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងអគ្គនាយកមួយរូបសំរាប់ដឹកនាំកិច្ចការធនាគារ ហើយអាចដក ដំណែងអគ្គនាយក ដោយអនុលោមទៅតាមមាត្រាទី៣៤.៤។ អគ្គនាយក ត្រូវទទួលខុសត្រូវរួម ក្នុងការអនុវត្ត និង ប្រកាន់យកយុទ្ធសាស្ត្រ និងការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវមាន ភារៈកិច្ចទទួលខុសត្រូវផ្សេងៗទៀត ដូចដែលក្រុមប្រឹក្សាភិបាលកំណត់អោយនៅពេលណាមួយ អគ្គនាយកត្រូវផ្តល់របាយការណ៍តាមពេលកំណត់ ជូនដល់ក្រុមប្រឹក្សាភិបាល រាប់ទាំងរបាយការណ៍ ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ។

**មាត្រាទី ៤៣-** **ថ្នាក់ដឹកនាំផ្សេងៗទៀត :**

អគ្គនាយក ត្រូវតែងតាំងនាយក នាយកដ្ឋាននានារបស់ធនាគារ និងថ្នាក់ដឹកនាំមន្ត្រីដទៃផ្សេង ទៀត ដែលអគ្គនាយកគិតថា វាជាតំរូវការចាំបាច់ សំរាប់ធនាគារ ។ អគ្គនាយក ត្រូវរៀប តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំទាំងនោះ។ អគ្គនាយក ឬក្រុមប្រឹក្សា ភិបាល អាចដកហូតថ្នាក់ដឹកនាំទាំងនោះបាន។

## ជំពូកទី-៦-ប្រការសំខាន់ៗដទៃទៀត

**មាត្រាទី ៤៤-** **ការរំសាយដោយស្ម័គ្រចិត្ត និងការជំរះបញ្ជី :**

ធនាគារ អាចត្រូវរំសាយ ហើយចំណូលពីការលក់ (បន្ទាប់ពីបានដោះបំណុលរបស់ធនាគាររួចរាល់ ហើយ) ត្រូវបែងចែកអោយភាគទុនិកៈតាមសមាមាត្រនៃចំនួនភាគហ៊ុន ដែលភាគទុនិកៈម្នាក់ៗ នៅក្នុងស្តុក នៅពេលធ្វើការរំសាយធនាគារនោះ។ ជាបឋមការរំសាយ ត្រូវបានស្នើឡើងដោយ សំលេងឆ្នោតគាំទ្រ៧៥ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការ ហើយបានទទួលសច្ចានុម័តយល់ព្រមពីភាគទុនិកៈដោយសំលេងឆ្នោតគាំទ្រ៧៥ភាគរយ ឬច្រើន នេះ នៃភាគហ៊ុនដែលនៅសល់ ។ ប្រសិនបើការរំសាយ មានសំលេងឆ្នោតគាំទ្រពីភាគទុនិក ៥៩ភាគរយនៃភាគហ៊ុនដែលនៅសល់ ដោយមិន គ្រប់តាមសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ

ត្រូវដោយឃ្លាខាងលើ ការសំរេចរំលាយ ឬមិនរំលាយធនាគារ ត្រូវតែបញ្ជូនទៅដោះស្រាយតាមរយៈមជ្ឈត្តវិនិច្ឆ័យ ដោយយោងទៅតាមច្បាប់មជ្ឈត្តវិនិច្ឆ័យរបស់ សភាពាណិជ្ជកម្មអន្តរជាតិ (ICC) ដែលប្រតិបត្តិដោយមជ្ឈត្តករមួយ ឬច្រើនរូប ដែលបានតែងតាំងទៅតាមច្បាប់ ទីកន្លែងធ្វើមជ្ឈត្តវិនិច្ឆ័យនោះ គឺនៅប្រទេសសិង្ហបុរី។ សមាសភាពតុលាការមជ្ឈត្តកម្ម មានមជ្ឈត្តករបីរូប ដែលជ្រើសតាំងដោយសភាពាណិជ្ជកម្មអន្តរជាតិ។ ភាសាអង់គ្លេសគឺជាភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងដំណើរការមជ្ឈត្តវិនិច្ឆ័យ។ ប្រសិនបើតុលាការមជ្ឈត្តកម្មយល់ព្រមអោយរំលាយធនាគារនោះ ត្រូវដាក់ក្នុងការរំលាយដោយមិនស្ម័គ្រចិត្ត ហើយតែងតាំងនាយក មួយរូប ឬច្រើនរូប ឬអ្នកជំរះបញ្ជីដើម្បីត្រួតពិនិត្យការរំលាយ និងការជំរះបញ្ជីនោះ ។

**មាត្រាទី ៤៥-** **ភាគទុនិកមានឥទ្ធិពល :**

*អង្គការអេស៊ីលីដា* គឺជាភាគទុនិកដែលមានឥទ្ធិពលតែមួយគត់នៃធនាគារ ក្រោមច្បាប់របស់ធនាគារ និងបញ្ញត្តិនានា ដែលមានស្រាប់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលចុះបញ្ជីធនាគារ ឬដែលត្រូវអនុម័ត និងមានប្រសិទ្ធភាពក្នុងពេលអនាគត ហើយគ្មានភាគទុនិកណាផ្សេងនៃធនាគារ ដែលអាចចាត់ទុកថាជាភាគទុនិកដែលមានឥទ្ធិពល ឬ មានស្ថានភាពដែលអាចបង្ខំអោយ *អង្គការអេស៊ីលីដា* ទទួលខុសត្រូវបន្ថែមលើសពីមូលធនដែលបានចុះបញ្ជីហើយមិនទាន់បានបង់ឡើយ ។ *អង្គការអេស៊ីលីដា* ត្រូវបានទទួលស្គាល់ថាជាភាគទុនិកដែលមានឥទ្ធិពលតាមច្បាប់ បទបញ្ញត្តិ និងការអនុវត្តជាក់ស្តែង នៅកម្ពុជា ហើយម្យ៉ាងវិញទៀត មិនអាចទទួលខុសត្រូវលើសពីចំនួនមូលធនចុះបញ្ជី មិនទាន់បានបង់នោះឡើយ ។

**មាត្រាទី ៤៦-** **គោលនយោបាយដឹកនាំទូទៅ :**

ធនាគារត្រូវដឹកនាំ និងចាត់ចែងកិច្ចការជំនួញ និងអាជីវកម្មរបស់ខ្លួនទៅតាមគោលនយោបាយដឹកនាំទូទៅដើម្បីធ្វើប្រតិបត្តិការធនាគារ ដែលបានអនុម័តយល់ព្រមដោយមានសំលេងឆ្នោតចាប់ពី ៧៥ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សាភិបាល ដែលកំពុងបំពេញការងារ ។

**មាត្រាទី ៤៧-** ការទូទាត់ភាគលាភ ក្រោមគោលនយោបាយទូទាត់នៃភាគលាភ :

ធនាគារ នឹងមិនទូទាត់ភាគលាភទៅអោយភាគទុនិកៈទាំងអស់របស់ខ្លួន លើកលែងតែអនុលោម ទៅតាមគោលនយោបាយទូទៅដែលពាក់ព័ន្ធទៅនឹងការធ្វើប្រតិបត្តិ និងការទូទាត់ភាគលាភ ហើយមានការអនុម័តពីភាគទុនិកដែលកំពុងកាន់កាប់ភាគហ៊ុន ដោយសំលេងឆ្នោតគាំទ្រមិនតិចជាង ៧៥ ភាគរយ នៃភាគទុនិកដែលនៅសល់ ។

**មាត្រាទី ៤៨-** សវនករពីខាងក្រៅ :

ធនាគារ ត្រូវតែងតាំងសវនករខាងក្រៅមួយ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងមានសច្ចានុមតិយល់ព្រមដោយភាគទុនិក ។

**មាត្រាទី ៤៩-** ឆ្នាំសារពើពន្ធ :

ក្រុមប្រឹក្សាភិបាល ត្រូវតែកំណត់ឆ្នាំសារពើពន្ធនៃធនាគារទៅតាមសេចក្ដីសំរេច ។

**មាត្រាទី ៥០-** ការកំណត់ការទទួលខុសត្រូវ :

គ្មានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ជាប់ជំពាក់ផ្ទាល់ខ្លួន ដោយសារការបំពេញភារកិច្ច ឬការកើតមានការខកខានមិនបានសំរេចជាមួយធនាគារឡើយ លើកលែងតែការបំពេញភារកិច្ច ឬការខកខានមិនបំពេញភារកិច្ច បណ្ដាលអោយមានកំហុសដែលពាក់ព័ន្ធទៅនឹងការកេងបន្លំ ឬ រំលោភច្បាប់ ប្រព្រឹត្តខុសដោយចេតនា ឬកិច្ចការជំនួញដែលសមាជិកក្រុមប្រឹក្សារូបនោះបានទទួល ផលប្រយោជន៍ជាទ្រព្យសម្បត្តិមិនសមស្រប ឬសេវាកម្មដែលសមាជិកក្រុមប្រឹក្សារូបនោះ ត្រូវ នឹងទទួលដោយស្របច្បាប់ ។

**មាត្រាទី ៥១-** ការធានាសំណង :

យោងតាមមាត្រាទី៥០ បានចែងថាក្រុមប្រឹក្សាភិបាល ដែលបានបំពេញការងារដោយស្មោះត្រង់ និងសុចរិតភាព, ធនាគារ នឹងធានាទទួលខុសត្រូវជួសសមាជិកក្រុមប្រឹក្សាភិបាលរូបនោះ នូវរាល់ការចំណាយ (រួមទាំងថ្លៃមេធាវី) ការវិនិច្ឆ័យ (លើបណ្ដឹង)ណាមួយ និងការពិន័យ ជាប្រាក់ដែលកើតឡើង និងចំនួនទឹកប្រាក់ដែលបង់ ក្នុងការដោះស្រាយដែលក្រុមប្រឹក្សាភិបាល រូបនោះជាប់ពាក់ព័ន្ធជាមួយនឹង ឬក្នុងដំណើរការ រួមបញ្ចូលទាំង អំពើតំរាមកំហែង ទោះជារឿងរដ្ឋប្បវេណី, ព្រហ្មទណ្ឌ, រដ្ឋបាល ឬការស៊ើបអង្កេត តាមហេតុផលជាក់ស្ដែង ដែលក្រុមប្រឹក្សារូបនោះ កំពុងបំពេញ ភារកិច្ចជាសមាជិកក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ៥២- វិសោធនកម្ម :**

**៥២.១ អ្នកមានសិទ្ធិលើកសំណើរធ្វើវិសោធនកម្ម :**

ការធ្វើវិសោធនកម្មទៅលើមាត្រាទាំងឡាយនៃលក្ខន្តិកៈ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល និង ភាគទុនិកៈ ដើម្បីធ្វើការសំរេច ប្រសិនបើសំណើនោះត្រូវបានធ្វើឡើងដោយ សមាជិកក្រុមប្រឹក្សាភិបាលដែលកំពុងបំពេញការងារយ៉ាងតិចចំនួន ១/៣ ឬពីភាគទុនិកៈដោយសំលេងឆ្នោតគាំទ្រ ចំនួន ៣៣-១/៣៖ ឬច្រើន ជាងនេះ នៃភាគហ៊ុនដែលនៅសល់ ។

**៥២.២ សំលេងឆ្នោតចាំបាច់ :**

រាល់ការធ្វើវិសោធនកម្មរបស់មាត្រាទាំងឡាយនៃលក្ខន្តិកៈ តម្រូវឲ្យមាន :

ក- សំលេងឆ្នោតគាំទ្រយ៉ាងតិច ៧៥ភាគរយនៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលកំពុងបំពេញការងារ ដោយមានភ្ជាប់ជាមួយនូវ

ខ- សំលេងឆ្នោតគាំទ្ររបស់ភាគទុនិកយ៉ាងតិច ៧៥ភាគរយ ឬច្រើនជាងនេះនៃភាគហ៊ុនដែលនៅសល់ ។

សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែលហៅកាត់ថា *អង្គការអេស៊ីលីដា* ជាអង្គការក្រៅរដ្ឋាភិបាល ដែលបាន ចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

លោក អ៊ិន ចាន់នី

ក្រុមហ៊ុន អេ អេស អេ អ៊ីស្ស ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង និងចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

លោក រ៉ុត យុម៉េង

**Deutsche Investitions- und Entwicklungsgesellschaft mbH,** ក្រុមហ៊ុនទទួលខុសត្រូវ មានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

តំណាងដោយ ______________________

**Ms. Jutta Wagenseil**

**Nederlandse Financierings-Maatschappij voor Ontwikkelingslanden N.V,** ក្រុមហ៊ុនទទួលខុសត្រូវ មានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃប្រទេសហូឡង់

តំណាងដោយ ______________________

**Ms. Els Boerhof**

**International Finance Corporation,** ជាអង្គការអន្តរជាតិ បានបង្កើតឡើងក្រោមមាត្រានៃកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងប្រទេសជាសមាជិក រួមទាំងព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

EDWARD NICHOLAS

**Mr. Deepak Khanna**

**Stichting Triodos Doen,** ជាមូលនិធិមួយ បានកសាងឡើងក្រោមច្បាប់នៃប្រទេសហូឡង់

តំណាងដោយ ______________________

**Ms. Femke Bos**

**Triodos Custody B.V,** ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានកសាងឡើងក្រោមច្បាប់នៃប្រទេសហូឡង់ ក្នុងនាមជាក្រុមហ៊ុន **Triodos Fair Share Fund** ដែលជាមូលនិធិបានកសាងឡើងក្រោមច្បាប់នៃប្រទេសហូឡង់

តំណាងដោយ ______________________

**Ms. Femke Bos**

ក្រសួងពាណិជ្ជកម្ម
ការិយាល័យចុះបញ្ជី ពាណិជ្ជកម្ម

<u>ក្រុមប្រឹក្សាភិបាល</u>

១. លោក ជា សុខ (តតិយជន) ____________

២- Mr. John Brinsden (តតិយជន) ____________

៣- Mr. Peter Kooi (តតិយជន) ____________

៤- Ms. Jutta Wagenseil (តតិយជន) ____________

៥- Mr. Emile Hubert Joseph Groot (តតិយជន) ____________

៦. Mr. Deepak C. Khenna (តតិយជន) ____________

៧. Ms. Femke Bos (តតិយជន) ____________

៨. លោក ឡុញ ថុល (តតិយជន) ____________

៩. អ្នកស្រី សុខ ចណ្ណរី (តតិយជន) ____________

បានឃើញនិងទទួលទុកជាឯកសារ
រាជធានីភ្នំពេញ, ថ្ងៃទី............ខែ............ឆ្នាំ.....
ធនាគារជាតិ នៃ កម្ពុជា
អគ្គទេសាភិបាល